ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- សេចក្តីប្រកាសព័ត៌មានស្តីពីការរចនាប្លង់គោលស្រុកអន្លង់វែង
- ការស្តារឡើងវិញនូវសម្បត្តិវប្បធម៌ និង សហគមន៍ចាម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២១០ ខែមិថុនា ឆ្នាំ២០១៧

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២១០ ខែមិថុនា ឆ្នាំ២០១៧

## មាតិកា

◆ សេចក្តីប្រកាសព័ត៌មានស្តីពីការរចនាប្លង់គោលស្រុកអន្លង់វែង...............១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព ហ៊ាក វ៉ន អនុលេខាវរសេនាតូច២១៧....................៨

◆ តាំង អាន ហៅ អេន ប្រធានយោធាវរសេនាតូច៧០៩ ................១៣

◆ យុវជន-យុវនារីបដិវត្តន៍យើង រំភើបរីករាយឥតឧបមាចំពោះ ...........២០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ បានជួបត្រឹមសាកសព ..........................................................២៣

◆ ស្ម័គ្រចិត្តទៅសមរភូមិប្រសើរជាងឲ្យអង្គការសម្លាប់ .........................២៥

◆ ការសិក្សាអំពីរបបខ្មែរក្រហមធ្វើឲ្យយើងស្គាល់ពីទុក្ខលំបាករបស់...........២៧

◆ គ្មានជម្រើសទេ សម្រាប់ខ្ញុំ.......................................................៤០

◆ ភាពឈឺចាប់ជំរុញឲ្យខ្ញុំចូលបម្រើយោធា........................................៤២

◆ អតីតមេភូមិនៅក្នុងតំបន់រំដោះខ្មែរក្រហម .....................................៤៤

**ផ្នែកច្បាប់**

◆ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានបិទ...........៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ការស្តារឡើងវិញនូវសម្បត្តិវប្បធម៌ និង សហគមន៍ចាម....................៥១

◆ ការពង្រឹងនីតិរដ្ឋតាមរយៈការអប់រំផ្នែកច្បាប់.................................៥៤

◆ ទស្សកិច្ចសិក្សារបស់និស្សិតច្បាប់នៅសាលាក្តីខ្មែរក្រហម...................៥៦

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ “សារភាណីយ” ........................................................................៦៨



សិស្សវិទ្យាល័យជ្រោយ ឡើងសួរសំណួរទាក់ទងការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩)

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** ម៉ែន ពិចិត្រ, គង់ បូរ៉ាន, ហ៊ិន សុចិត្រា, ដារារដ្ឋ មេត្តា, រ៉ូនិត អារី, រ៉េនែល គីលៀន, រ៉ូប៊ីន ហិកគី, លូក ម៉ូហ្វេត, ផាន់ សុផល **អ្នកនិពន្ធនិងស្រាវជ្រាវ :** ទាវ សារៈមុនិន្ទ និង ឆេង វ៉េង **អ្នកបកប្រែ :** លន់ សុចិត្រា **និពន្ធនាយកទូទៅ :** ឆាំង យុ **ជំនួយការនិពន្ធនាយក :** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ :** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ :** សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org, www.truthcambodia.com**

# សេចក្តីប្រកាសព័ត៌មានស្តីពីការរចនាប្លង់គោលស្រុកអន្លង់វែង

*មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមហ៊ុនរចនាប្លង់ ដេវ៉ា កាង*

មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការជាមួយនឹងវិចិត្រសាលនៅទីក្រុងឡុងដ៍ របស់ក្រុមហ៊ុនរចនាប្លង់ ដេវ៉ា កាង ដើម្បីបង្កើតជាចក្ខុវិស័យថ្មីមួយសម្រាប់ស្រុកអន្លង់វែង ដែលជាតំបន់កាន់កាប់ចុងក្រោយនៃចលនាខ្មែរក្រហម ។ គម្រោងនេះ មានគោលបំណងបង្កើតជាទីក្រុងសន្តិភាព ការផ្សះផ្សា និងការបង្កើតជីវិតថ្មី នៅក្នុងទីតាំងដែលល្បីល្បាញមកដល់សព្វថ្ងៃពីអំពើហិង្សា និងការប៉ះទង្គិចផ្លូវចិត្ត ។

ស្ថិតនៅឯជើងភ្នំដងរែក ក្នុងទីដាច់ស្រយាលនៃព្រំដែនភាគខាងជើងជាប់នឹងប្រទេសថៃ ស្រុកអន្លង់វែងមានទំនាក់ទំនងយ៉ាងស៊ីជម្រៅ ជាមួយនឹងអតីតកាលដ៏ខ្លោចផ្សាលរបស់ប្រទេសកម្ពុជា ។ បន្ទាប់ពីការគ្រប់គ្រងរយៈពេលខ្លីដ៏ព្រៃផ្សៃ ដែលត្រូវបានស្គាល់ថាជា "វាលពិឃាត" និងការបាត់បង់ជីវិតរបស់ប្រជាជនកម្ពុជារហូតដល់ជាង២លាននាក់ ខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាច ដោយសារការលុកលុយរបស់កងកម្លាំងវៀតណាម ។ ប៉ុល ពត និងរបបខ្មែរក្រហម បានគេចទៅកាន់តំបន់ភ្នំ និងព្រៃស្រុកអន្លង់វែង ហើយប្រើប្រាស់ទីតាំងនេះដើម្បីបន្តសង្គ្រាមទ័ពព្រៃប្រមាណជាង២០ឆ្នាំបន្តមកទៀត ។ ទីបំផុត នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ក្រុមខ្មែរក្រហមចុងក្រោយបំផុត យល់ព្រមទម្លាក់អាវុធរបស់ខ្លួន និងវិលត្រឡប់ចូលសង្គមវិញ ។ យ៉ាងណាមិញ សន្តិភាពនារយៈពេល២០ឆ្នាំចុងក្រោយនេះ មិនបានលុបបំបាត់ចោលប្រវត្តិសាស្ត្រនៃទីតាំងនេះ ឬទីតាំងសំខាន់ៗនៃអំពើហិង្សា ពលកម្មដោយបង្ខំ ការសម្លាប់យ៉ាងឃោរឃៅ ក៏ដូចជាផ្ទះឃុំខ្លួន ទីតាំងដុតសព និងផ្នូររបស់ប៉ុល ពត ។

៨៥ភាគរយនៃប្រជាជនអន្លង់វែងសព្វថ្ងៃ គឺជាអតីតខ្មែរក្រហម ដោយភាគច្រើននៃអ្នកទាំងនេះ រស់នៅដោយប្រកបរបរកសិកម្មទ្រុឌទ្រោមយកដីដែលបង្កជាបាតុភូតភ្លើងឆេះព្រៃដ៏អាណោច



ប្លង់គោលអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រក្នុងអន្លង់វែង ដែលគូរដោយក្រុមហ៊ុនរចនាប្លង់ ដេវ៉ា កាង មានមូលដ្ឋាននៅប្រទេសអង់គ្លេស សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងទេសចរណ៍ ។

អាជ័មមួយចំនួន នៅក្នុងប្រទេសកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្តើមដំណើរការនៃការផ្សះផ្សា ការចូលរួម និងការអប់រំ ដោយប្រែក្លាយផ្ទះនៅលើជម្រាលភ្នំដែលត្រូវបានប្រើប្រាស់ដោយ ប៉ុល ពត និងខ្មែរក្រហមជាន់ខ្ពស់ដទៃទៀត ដើម្បីរៀបចំផែនការអំពើហិង្សា ឲ្យទៅជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។

វិធីសាស្ត្រនៃក្រុមហ៊ុនរចនាប្លង់ ដេវ៉ា កាង គឺជ្រើសយកទិដ្ឋភាពរួមជាយុទ្ធសាស្ត្រ នៃស្រុកអន្លង់វែងទាំងមូល ដែលមានទំហំប្រមាណ៥០គីឡូម៉ែត្រ ដោយប្រើប្រាស់នូវទស្សនៈ «ការកែច្នៃសណ្ឋានដី ការព្យាបាលរបួសសង្គម» ។ យើងរួមបញ្ចូលវិធីសាស្ត្រទំនើបមួយនៃហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ និងការងារអភិវឌ្ឍអមជាមួយនឹងយុទ្ធសាស្ត្រនៃការបណ្តុះព្រៃយ៉ាងសម្រិតសម្រាំង ក៏ដូចជាការអភិវឌ្ឍនូវវិធីសាស្ត្រកសិកម្មបែបថ្មី និងឧស្សាហកម្មថ្មី ។ ប្រព័ន្ធ «ខ្សែអំបោះមាសមួយសរសៃ» បង្កើតបានជាអន្តរាគមន៍ភូមិសាស្ត្រមានភាពបត់បែន ដែលត្រូវបានរចនាឡើងដើម្បីបង្កើតនិងធ្វើឲ្យប្រសើរឡើងនូវភូមិសាស្ត្រ ។ ខ្សែបូរនៃការបណ្តុះដើមឈើជាជួរៗត្រូវបានរួមផ្សំជាមួយនឹងកិច្ចការដីធ្លី និងផ្លូវទឹក ដើម្បីធ្វើឲ្យដីធូរស្រាល និងផ្តល់ជាចំណុចគោលនានាសម្រាប់សួនច្បារ ផ្លូវដើរពណ៌បៃតង ទីតាំងកម្សាន្ត និងបរិក្ខាផ្សេងៗទៀត ។ លំហូរបត់បែននៃខ្សែបូរឆ្មារត្រូវបានរចនាឡើង ដើម្បីធ្វើអប្បបរមាកម្មការបាត់បង់ដីកសិកម្ម ។ តាមរយៈវិធីសាស្ត្រនេះ យើងគាំពារដល់ការរស់នៅរបស់កសិករក្នុងតំបន់អន្លង់វែង ស្របពេលនឹងថែរក្សាទិន្នផលដីសម្រាប់ពេលអនាគត ។

នៅក្នុងពិធីបុណ្យព្រះពុទ្ធិសាសនានិងពិធីបុណ្យផ្សេងៗទៀតក្នុងពិភពលោក ស្លាកដៃធ្វើអំពីខ្សែអំបោះត្រូវបានរំនៅជុំវិញកដៃ ប្រើប្រាស់ជានិមិត្តរូបដើម្បីការពារការធ្វើទុក្ខបុកម្នេញពីអំពើអាក្រក់ និងព្រាយបីសាច ។ ការប្រើប្រាស់ខ្សែអំបោះមាសមួយសរសៃ នៅអន្លង់វែងក្នុងការរចនាប្លង់គោលនេះ គឺជានិមិត្តរូបនៃការលះបង់ និងការតាំងចិត្តលើការកែច្នៃសណ្ឋានដីដើម្បីប្រជាជនមូលដ្ឋាន និងអនាគតថ្មីមួយ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា រួមសហការជាមួយនឹងក្រសួងទេសចរណ៍ និងគណៈកម្មការអន្តរក្រសួងដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រអន្លង់វែង បានកំណត់នូវទីតាំងប្រវត្តិសាស្ត្រចំនួន១៨កន្លែង នៅតាមបណ្តោយផ្លូវចេញពីភូមិអន្លង់វែង ទៅកាន់កំពូលភ្នំដងរែក ហើយសំណើគម្រោងរបស់យើង ភ្ជាប់ទីតាំងទាំងនេះជាមួយគ្នា បង្កើតបានជាផ្លូវដើរទៅវិញទៅមកនៅតាមបណ្តោយទីក្រុង និងតំបន់កសិកម្មឆ្ងាយៗ ។ អ្នកទស្សនាដែលមក



ប្លង់គោលដែលតភ្ជាប់តំបន់ប្រវត្តិសាស្ត្រទាំង១៨កន្លែង នៅក្នុងស្រុកអន្លង់វែង គូរដោយក្រុមហ៊ុនរចនាប្លង់ ដេវ៉ា កាង មានមូលដ្ឋាននៅប្រទេសអង់គ្លេស សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងទេសចរណ៍ ។

ដល់បឹងអន្លង់វែង ទទួលបានផែនទី និងកូនឈើមួយដើម ព្រមទាំងចាប់ផ្តើមការធ្វើដំណើររយៈពេលបីថ្ងៃរបស់ខ្លួន ។ នៅតាមផ្លូវអ្នកទស្សនាអាចដាំកូនឈើរបស់ខ្លួននៅទីតាំងដែលខ្លួនបានកំណត់ទុក ព្រមទាំងក្លាយជាអ្នកចូលរួមនៅក្នុងការកែច្នៃសណ្ឋានដីរបស់ស្រុកអន្លង់វែង ។ ដំណើរការនៃការរៀនសូត្រអំពីប្រវត្តិសាស្ត្រអន្លង់វែង និងដំណើរការនៃការកែច្នៃសណ្ឋានដី ត្រូវបានរួមបញ្ចូលគ្នានៅក្នុងបទពិសោធន៍ដ៏មានឥទ្ធិពលមួយ ។ ការធ្វើដំណើរនេះបញ្ចប់នៅពេលព្រឹកថ្ងៃទីបី ដោយគយគន់ព្រះអាទិត្យរះពីមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដែលស្ថិតនៅជម្រាលភ្នំដងរែក ។

ប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាអ្វីដែលធ្វើឲ្យអន្លង់វែងមានលក្ខណៈពិសេសជាងកន្លែងដទៃទៀត ហើយវិធីសាស្ត្ររបស់យើងគឺធ្វើការអភិវឌ្ឍតំបន់នេះ ដោយមិនមែនលុបបំបាត់ចោលនូវការចងចាំពីអំពើហិង្សា និងការប៉ះទង្គិចផ្លូវចិត្តទេ ក៏ប៉ុន្តែត្រូវប្រែក្លាយតំបន់នេះពីទីតាំងនៃការឈឺចាប់ឲ្យទៅជាទីតាំងនៃការបង្កើតជីវិតថ្មី ។ ទីកន្លែងនៃការប្រព្រឹត្តអំពើហិង្សាលើស្ត្រី ដែលប្រពន្ធ និងកូនស្រីរបស់អតីតមេដឹកនាំជាន់ខ្ពស់ ត្រូវបានរំលោភ និងសម្លាប់ អាចប្រែក្លាយទៅជាមជ្ឈមណ្ឌលស្ត្រីសម្រាប់បណ្តុះបណ្តាល និងពិគ្រោះយោបល់ ។ ឃ្លាំងដែលធ្លាប់ស្តុកទុកគ្រាប់មីន អាចប្រែក្លាយទៅជាទីកន្លែងដែលប្រជាជនអាចផលិតឈើប្រត់ រទេះរុញ និងកង់ជាដើម ។ ២៥ភាគរយនៃប្រជាជនអន្លង់វែងត្រូវទទួលរងពិការភាពដោយសារតែគ្រាប់មីន និងសង្គ្រាមទ័ពព្រៃយ៉ាងវែងអន្លាយ ។ តាមរយៈដំណើរការនៃការប្រែក្លាយនេះ ទីកន្លែងមួយដែលធ្វើឲ្យប្រជាជនរងរបួស និងពិការ អាចក្លាយជាទីកន្លែងដែលផ្តល់ការងារដល់ប្រជាជនតាមរយៈការលើកកម្ពស់ដល់ជនពិការឲ្យដើរបានឡើងវិញ និងការស្តារសង្គមទៀតផង ។

ក្រុមហ៊ុនរចនាប្លង់ ដេវ៉ា កាង ប្រមើមើលនូវអារម្មណ៍នានាចំពោះអន្តរាគមន៍ស្ថាបត្យកម្មដ៏ស្រស់ស្អាត នៅទីតាំងប្រវត្តិសាស្ត្រសំខាន់ៗទាំងនេះ ។ អគារនៅលើជម្រាលភ្នំ ថែរក្សាទេសភាពនៅលើភ្នំ ទន្ទឹមនឹងនោះក៏បានបង្កើតជាបទពិសោធន៍ដ៏អស្ចារ្យសម្រាប់ទេសចរ ដែលធ្វើដំណើរទៅកាន់អាគារទាំងនោះដែរ ។ នៅក្នុងតំបន់អន្លង់វែងនេះ យើងមានបំណងកសាងភូមិសាស្ត្របែបទីក្រុង និងកសិកម្ម ជាទីតាំងដែលអាគារដ៏ស្រស់ស្អាត និងអស្ចារ្យគួបផ្សំជាមួយនឹងវិស្វកម្មខ្នាតធំ ពោរពេញដោយការបង្កើតថ្មីដើម្បីបង្កើតនូវអនាគតដ៏ត្រចះត្រចង់សម្រាប់ប្រជាជនក្នុងតំបន់និងបទពិសោធន៍មួយ ដែលបំភ្លេចពុំបានសម្រាប់អ្នករាល់គ្នាដែលមកទស្សនា ។

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ត្រូវបានគ្រប់គ្រងដោយលោកបណ្ឌិត លី សុខឃាង និងជាការផ្តួចផ្តើមរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជានាយកវិទ្យាស្ថានស្លឹករឹត ។ ក្រុមហ៊ុន រចនា ប្លង់ ដេវ៉ា កាង មានទីតាំងវិចិត្រសាលរចនាដែលមានមូលដ្ឋាននៅទីក្រុងឡុងដ៍ មានជំនាញរចនាប្លង់ ដើម្បី ផ្តល់នូវសោភ័ណភាព ការបង្កើតថ្មី និងភាពសុខដុម ។

ក្រុមការងារនៃគម្រោងប្លង់គោលស្រុកអន្លង់វែងនេះ សូមសម្តែងការដឹងគុណចំពោះលោកស្រី វ៉ាហែល បូស្ស នៃភ្នាក់ងារស៊ីសដើម្បីការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ ដែលបានគាំទ្រយ៉ាងសប្បុរសដល់សេចក្តីផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ លោកស្រីបានប្តេជ្ញាយ៉ាងមុតមាំក្នុងការរក្សាសន្តិភាព និងលើកកម្ពស់ការផ្សះផ្សា នៅក្នុងសហគមន៍អន្លង់វែងដែលធ្លាប់រងនូវអស្ថិរភាពជាយូរមកហើយ ។ យើងខ្ញុំក៏សូមអរគុណជាពិសេសចំពោះលោកស្រី ប៉ូលី ដុនហ្វុត នៃភ្នាក់សហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ ដោយលោកស្រីបានផ្តល់ការគាំទ្រដល់ប្រតិបត្តិការស្នូលរបស់យើង ។ ប្រសិនបើពុំមានការគាំទ្របន្តបន្ទាប់នេះទេ យើងនឹងប្រឈមនឹងផលពិបាកក្នុងការប្រែក្លាយសេចក្តីផ្តួច ផ្តើមនេះឲ្យលេចចេញជារូបរាង ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់អភិបាលស្រុកអន្លង់វែង លោក ហោ ជិនវីរៈយុទ្ធ ព្រមទាំងមន្ត្រីរបស់លោក ដែលបានការគាំទ្រ និងជំរុញទឹកចិត្ត ក៏ដូចជាការអនុញ្ញាតឲ្យយើងខ្ញុំទទួល និងប្រមូលព័ត៌មានដើម្បីរៀបចំប្លង់គោលនេះ ។

រក្សាសិទ្ធិឆ្នាំ២០១៧ ដោយ ក្រុមហ៊ុនរចនាប្លង់ ដេវ៉ា កាង និងមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដោយមានកិច្ចសហប្រតិបត្តិការជាមួយស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ក្រសួងទេសចរណ៍ និងគណៈកម្មការអន្តរក្រសួងដើម្បីគ្រប់គ្រងនិងអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# រូបថតកងយោធាខ្មែរក្រហមនៅអន្លង់វែង បានផ្តាច់ខ្លួ











# នចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា កាលពីឆ្នាំ១៩៩៨









# រូបថតនៅស្រុកអន្លង់វែ










# ០ ខែមិថុនា ឆ្នាំ២០១៧












# ចម្លើយសារភាពរបស់ ហ៊ាក វួន អនុលេខា វរសេនាតូច២១៧ កងពលទី១

***ដកស្រង់ចេញពីឯកសារលេខ D៤១២៧២***

ហ៊ាក វួន មានអាយុ២៦ឆ្នាំ (ឆ្នាំ១៩៧៧) កើតនៅភូមិដំឡូងទឹក ឃុំម្កាក់ ស្រុកសេរីសោភណ្ឌ តំបន់៥ (ខេត្តបាត់ដំបង) ។ ឪពុកឈ្មោះ ហ៊ាក ម្តាយឈ្មោះ គឹម អ្នកទាំងពីរប្រកបរបរធ្វើស្រែ ។ មុនអង្គការចាប់ខ្លួន វួន មាននាទីជាអនុលេខាវរសេនាតូចលេខ២១៧ កងពលទី១ ។ វួន ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧៧ ។ នៅក្នុងចម្លើយសារភាពរបស់ វួន ចែកចេញជាបីផ្នែកទី១ រៀបរាប់ពីប្រវត្តិ និងឈ្មោះរបស់បក្ខពួកក្បត់ម្នាក់ៗ (សង្ខេបខ្លីៗ) រួមនិងសេចក្តីកំណត់ហេតុមានចំនួន ២០ទំព័រ ធ្វើចប់នៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៧ ដែលមានស្នាមផ្តិតមេដៃរបស់ ហ៊ាក វួន និងបានចុះហត្ថលេខាអ្នកសួរចម្លើយចំនួនពីរនាក់មានឈ្មោះ ដឹម ខន និង ខន ។ ផ្នែកទី២ ជាចម្លើយសារភាពរបស់ វួន ដែលបានសរសេរពីសកម្មភាពក្បត់របស់ខ្លួនមាន


ទិដ្ឋភាពមន្ទីរសន្តិសុខស-២១ ថតដោយ ហូ វ៉ាន់ តៃ អ្នកថតរូបជនជាតិវៀតណាម និងក្រុមការងាររបស់គាត់ ឌិញ ហុង កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ ។

ចំនួន២៩ទំព័រ ចាប់ផ្តើមធ្វើនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៧៧ និងធ្វើចប់នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៧៧ ដែលមានចុះហត្ថលេខារបស់អ្នកធ្វើឯកសារឈ្មោះ ទិត នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៧៧ ។ ផ្នែកទី៣ ជាចម្លើយសារភាពលើកទី២ របស់ ហ៊ាក វួន ដែលអត្ថន័យនៅក្នុងនោះ បានរៀបរាប់ពីសកម្មភាពរបស់ខ្លួនក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ មានចំនួន១៤ទំព័រ ធ្វើនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧ ។ ខាងក្រោមនេះ ជាសេចក្តីសង្ខេបដកស្រង់ចេញពីចម្លើយសារភាពរបស់ ហ៊ាក វួន៖

ឆ្នាំ១៩៦៧ វួន បានមកធ្វើស្រែជាមួយឪពុកម្តាយនៅភូមិអន្លង់ស្នួរ ឃុំសំរោង ស្រុកសេរីសោភ័ណ្ឌ ខេត្តបាត់ដំបង ។ នៅពេល វួន កំពុងឃ្វាលគោជាមួយមិត្តភក្តិពីរនាក់ទៀត ប៉ូលីសឈ្មោះ ឈឿ បានដើរមករកអ្នកទាំងបី ហើយបានអប់រំអ្នកទាំងបីឲ្យចូលធ្វើជាគិញ ដោយបាននិយាយបញ្ចុះបញ្ចូលថា “យើងត្រូវស្រឡាញ់ជាតិខ្មែរ យើងកុំឲ្យខ្មែរក្រហមចូលមកក្នុងភូមិយើងបានឲ្យសោះ ពួកនោះជាចោរព្រៃ បើយើងឲ្យវាចូលមក ប្រយ័ត្នវាលួចគោ-ក្របីក្នុងភូមិអស់ ។ ឈឿ បានបន្ថែមថា បើប្អូនចូលធ្វើគិញនឹងបានជាប្រាក់ខែ ។ ក្មេងៗដូចប្អូនឯង មានអនាគតទៅមុខទៀតវែងឆ្ងាយណាស់ ។ បន្ទាប់មក ឈឿ បានចាត់ឲ្យអ្នកទាំងបីចូលធ្វើគិញ” ។ ពេលនោះ វួន និងមិត្តភក្តិពីរនាក់ទៀតក៏យល់ព្រមធ្វើគិញឲ្យប៉ូលីស ឈឿ នៅខែមេសា ឆ្នាំ១៩៦៧ ចាប់ពីពេលនោះមក ។ បន្ទាប់មក ឈឿ បានដាក់ភារកិច្ចឲ្យអនុវត្តគឺ៖

១) ពិនិត្យចាំមើលខ្មែរក្រហមដែលចូលមកក្នុងភូមិ

២) ពិនិត្យប្រជាជនក្នុងភូមិ ថាតើនរណាខ្លះ ចូលចិត្តឲ្យបាយឲ្យទឹកខ្មែរក្រហមស៊ី? ។

ឆ្នាំ១៩៦៨ វួន បានឃើញខ្មែរក្រហមចំនួន៦នាក់ចូលភូមិទទា ពេលនោះ វួន បានរាយការណ៍ប្រាប់ទៅប៉ូលីសៗ ក៏បានមកចាប់បានពីរនាក់ រីឯបួននាក់ទៀត បានរត់ចូលព្រៃអស់ ។ នៅក្នុងខែវិច្ឆិកា វួន បានពិនិត្យឃើញខ្មែរក្រហមចូលសំដៅទៅផ្ទះរបស់ឈ្មោះ ប្រាំង ចាត់តាំងជាសម្ងាត់ដើម្បីទាក់ទងជាខ្សែរយៈនៅក្នុងភូមិទទា ។ ពេលនោះ វួន ក៏បានរាយការណ៍ទៅប៉ូលីស ឈឿ ។ ប៉ូលីស ក៏បាននាំគ្នាមកព័ទ្ធចាប់ តែចាប់មិនបានព្រោះយប់ងងឹតពេក ហើយខ្មែរក្រហមក៏បានរត់ចូលព្រៃអស់ ។ ដល់ខែឧសភា ឆ្នាំ១៩៦៩ ប៉ូលីសក៏បានមកចាប់ឈ្មោះ ប្រាំង យកទៅសាលាស្រុកសេរីសោភណ្ឌចំនួន១៥ថ្ងៃ ហើយក៏បានដោះលែងឲ្យត្រឡប់មកផ្ទះវិញ ។ ខែតុលា ប៉ូលីស ឈឿ បានផ្លាស់ចេញពីបន្ទាយគានន់ នៅពេលនោះ វួន កសាងកម្លាំងបានម្នាក់ឈ្មោះ ម៉ាន បច្ចុប្បន្នជាមេក្រុមយោធាវរ២០៧ ហើយបានឲ្យ ម៉ាន ជួយពិនិត្យតាមដានមើលខ្មែរក្រហមដែលចូលមកក្នុងភូមិ ។

ឆ្នាំ១៩៧០ ខែឧសភា វួន បានទៅភ្ជាប់ខ្សែរជាមួយ គើន ស័ក្តិពីរ និង រៀម អាស្តង់សែហ្វ នៅបន្ទាយនិមិត្ត ។ ពេលនោះ គើន និង រៀម បានអប់រំ វួន ដោយបាននិយាយថា “របបសាធារណរដ្ឋខ្មែរ មានការឧបត្ថម្ភពីអាមេរិកគ្រប់បែបយ៉ាងទាំងអស់ តាមសេចក្តីត្រូវការរបស់ខ្មែរ ហើយអាមេរិកជាប្រទេសមហាអំណាចក្នុងសកលលោកទាំងមូល និងជាអ្នកមានធំជាងគេបំផុត តើប្អូនពេញចិត្តទេ? យើងនឹងបញ្ចូលប្អូនឯងជាខ្សែ សេ.អ៊ី.អា សម្រាប់ទៅបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ ព្រោះប្អូនធ្លាប់ធ្វើជាគិញស្រាប់ ។ ពេលនោះ វួន ក៏បានឆ្លើយថា ពេញចិត្តណាស់ ហើយអ្នកទាំងពីរ (គើន និង រៀម) បានអប់រំឲ្យ វួន មានការងារធ្វើទៀត ព្រោះប៉ូលីសផ្លាស់ចេញទៅអស់ហើយ ដែល វួន នៅពេលនោះក៏ដាច់ខ្សែទាក់ទងដែរ ។ បន្ទាប់មក កម្មវិធីបញ្ចូលជាសមាជិក សេ.អ៊ី.អា ក៏បានចាប់ផ្តើម ដោយឈ្មោះ គើន ជាអ្នកទទួលស្គាល់ និងឈ្មោះ រៀម ជាអ្នកឧទ្ទេសនាម ហើយអ្នកត្រូវបានបញ្ចូលជាសមាជិក សេ.អ៊ី.អា មានចំនួនបីនាក់ គឺ វួន, ស្រួច និង ម៉ុន ។ កម្មវិធីបញ្ចូលសមាជិក សេ.អ៊ី.អា នេះ ធ្វើនៅភូមិគោកល្វា ឃុំមោង ស្រុកក្រឡាញ់ ខេត្តសៀមរាប តំបន់១០៦ ។ បន្ទាប់ពីចូលជាសមាជិក សេ.អ៊ី.អារួចហើយ វួន, ស្រួច និង ម៉ុន បានទទួលផែនការឲ្យកសាងកម្លាំង សេ.អ៊ី.អា ថែមទៀត ដើម្បីបង្កប់ស៊ីរូងផ្ទៃក្នុងនៅក្នុងជួរបដិវត្តន៍ ។ ក្រោយមក វួន កសាងកម្លាំងបាន៦នាក់ ហើយក៏បានប្រគល់ទៅឲ្យ ឈ្មោះ ណៃ និង រេន ដើម្បីបញ្ចូលជាខ្សែ សេ.អ៊ី.អា ។ នៅខែតុលា ឆ្នាំ១៩៧០ អ្នកទាំងប្រាំមួយត្រូវបានបញ្ចូលជា សេ.អ៊ី.អា ហើយបានចាត់ឲ្យមកបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ ។ ពេលនោះ វួន ក៏បានចូលរួមក្នុងកម្មវិធីនេះដែរក្នុងឋានៈជាភ្ញៀវ ដើម្បីជួយផ្តល់មតិណែនាំបន្ថែមងាយស្រួលឲ្យ សមាជិក សេ.អ៊ី.អា បានយល់កាន់តែច្បាស់ នៅពេលនោះដែរ ណៃ ជាអ្នកទទួលស្គាល់ និង

រេន ជាអ្នកខ្ទេសនាមបញ្ចូល ។

បន្ទាប់ពីកម្មវិធីបានបញ្ចប់ទៅ ណៃ បានដាក់ផែនការ ដោយធ្វើការពន្យល់សមាជិក សេ.អ៊ី.អា ដែលទើបបញ្ចូលថ្មីអស់រយៈពេលមួយថ្ងៃកន្លះ ឲ្យដើម្បីយកទៅអនុវត្តរៀងៗខ្លួន ។ នៅខែវិច្ឆិកា ឆ្នាំ ១៩៧០ អ្នកទាំងប្រាំមួយ បានធ្វើសកម្មភាពជាបន្តបន្ទាប់ និងបានសម្លាប់កម្មាភិបាលអស់ពីរនាក់ ដោយកម្មាភិបាលទាំងនេះមិនព្រមអនុវត្តតាម ណៃ បញ្ជា ។

ខែមករា ឆ្នាំ១៩៧១ វួន បានទាក់ទងទៅទាហាននៅបន្ទាយនិមិត្ត ឲ្យមកធ្វើសកម្មភាពដុតផ្ទះប្រជាជន ដេញចាប់ប្រជាជនយកទៅឃុំខ្លួននៅបន្ទាយនិមិត្ត ។ ផ្ទះរបស់អ្នកភូមិ ត្រូវភ្លើងឆេះខ្ទេចខ្ទីអស់ ចំណែក ស្រូវ អង្ករ ជ្រូក មាន់ ទា ត្រូវពួកទាហានយកគ្មានសល់ ។ បន្ទាប់មក វួន បានភ្ជាប់ខ្សែជាមួយ ណៃ លុះដល់ខែខសភា ឈ្មោះរិទ្ធិ បានយក វួន ទៅសៀមរាបជាមួយ ចំណែក ណៃ បានឡើងទៅរៀនសូត្រ ។ ពេលនោះ វួន ក៏បានភ្ជាប់ខ្សែជាមួយឈ្មោះ នៅ បច្ចុប្បន្នជាអនុលេខាកងពលទី១ ។ ខែមិថុនា វួន បានកសាងកម្លាំងបានបួននាក់បន្ថែមទៀតនៅខេត្តសៀមរាប ហើយបានបញ្ជូនអ្នកទាំងបួនឲ្យទៅឈ្មោះ នៅ និង រេន ដើម្បីបញ្ចូលជាសមាជិក សេ.អ៊ី.អា ។ ក្រោយពីបញ្ចូលជាសមាជិក សេ.អ៊ី.អា រួចមក រេន និង នៅ បានចាត់តាំង ស្រួច ឲ្យបញ្ជូនទៅបង្កប់ខ្លួនក្នុងកងទ័ពនៅសមរភូមិ ហើយអ្នកទាំងនេះ បានធ្វើសកម្មភាពជាមួយ វួន ដោយបានចាប់ប្រជាជននៅភូមិប្រីម្នាក់ យកទៅសម្លាប់ចោល ព្រោះម្នាក់នេះមិនព្រមអនុវត្តតាមផែនការរបស់ នៅ ។ ក្រោយមកទៀត វួន បានទទួលផែនការពីឈ្មោះ នៅ ឲ្យទៅទាក់ទងជាមួយស័ក្តិបី ដោក នៅបន្ទាយស្រីស្នំក្នុងភូមិពង្រ ។ ក្រោយពី នៅ និង ដោក បានជួបគ្នាហើយ ក៏បានដាក់ផែនការកម្ទេចមូលដ្ឋានអង្គការនៅ និងអូ ខាងកើតភូមិពង្រ ។ ពេលនោះ នៅ បានប្រគល់បួង ឲ្យទៅ ដោក ដើម្បីធ្វើសកម្មភាព ។ បន្ទាប់មក មូលដ្ឋាន និងឃ្លាំងនៅកន្លែងនោះ ត្រូវយន្តហោះបាញ់ឆេះអង្ករអស់ជាង២០០បាវ ពេលនោះអង្គការក៏បានដកថយចាកចេញពីកន្លែងនោះ ទៅតាំងទីកន្លែងថ្មីផ្សេងទៀត ។ នៅខែវិច្ឆិកា វួន និងបក្ខពួកបានទទួលផែនការពី នៅ ដោយទាក់ទងឲ្យជាប់ជាមួយសក្តិបី ដោក ធ្វើសកម្មភាពនាំទាហានមកព័ទ្ធកន្លែងរបស់ ញឹម នៅភូមិគោកល្វា ឃុំមោង ស្រុកក្រឡាញ់ ខេត្តសៀមរាប ប៉ុន្តែ ញឹម បានគេចចេញផុតពីការហ៊ុមព័ទ្ធនេះ ។ រីឯ នៅក្នុងភូមិ ពួកទាហានបានធ្វើសកម្មភាពរឹបអូសយករបស់របរពីប្រជាជន មន្ទីររបស់អង្គការ សម្ភារ ស្រូវ អង្ករ ត្រូវភ្លើងឆេះអស់ ។

ខែមីនា ឆ្នាំ១៩៧២ អង្គការមានផែនការឲ្យកងទ័ពទៅកសាងមូលដ្ឋាននៅខាងភ្នំព្រះជិតថ្មពួក ពេលនោះឈ្មោះ ហ៊ូវ ប្រធានកងអនុសេនាតូច បានទៅទាក់ទងស័ក្តិមួយឈ្មោះ ទុំ នៅបន្ទាយថ្មពួក ឲ្យធ្វើសកម្មភាពរារាំងមិនឲ្យអង្គការកសាងមូលដ្ឋាននេះបាន ។ វួន នៅរក្សាការទាក់ទងជាមួយ នៅ ដដែល ហើយបានទទួលផែនការពី នៅ ឲ្យធ្វើការទាក់ទងជាមួយខ្សែរយៈឈ្មោះ ថន សមាជិកវរសេនាតូច២២៧ កងពលទី១, ឈ្មោះ យន អនុវរសេនាតូចលេខ៣១៥ នៅតំបន់៥, ឈ្មោះ វ៉ាល់ សមាជិកស្រុកភ្នំស្រុកតំបន់៥, វៃ ប្រធានមន្ទីរពេទ្យព-២ ប្រចាំក្រុងបាត់ដំបង, ផុន ប្រធានមន្ទីរពេទ្យនិមិត្ត ប្រចាំកងពលទី១ ។ វួន បានធ្វើការទាក់ទងជាមួយខ្សែរបស់ខ្លួន ដើម្បីធ្វើសកម្មភាព ហើយបានចាត់តាំងកម្លាំងរបស់ខ្លួនឲ្យទៅទាក់ទងជាមួយ ហ៊ូវ ហ៊ូវ ក៏បាននាំបន្តឲ្យទៅទាក់ទងជាមួយ ទុំ នៅបន្ទាយថ្មពួក តំបន់៥ ។ ការទាក់ទងក៏បានសម្រេច ។ ពេលនោះ ទាហានបន្ទាយថ្មពួក បានឡើងមកធ្វើសកម្មភាពនៅភ្នំព្រះ ហើយបានវាយប្រហារគ្នាជាមួយកងទ័ពបដិវត្តន៍មួយថ្ងៃពេញទើបដកថយ ចំណែកយន្តហោះក៏បានវាយប្រហារមកលើកងទ័ពបដិវត្តន៍យ៉ាងខ្លាំងក្លាណាស់ដែរ បណ្តាលឲ្យកងទ័ពមានគ្រោះថ្នាក់ និងរបួសជាច្រើន ។ ក្រោយមកស័ក្តិមួយ ទុំ ក៏បានចូលមកក្នុងជួរបដិវត្តន៍ ដើម្បីចូលមកយកការណ៍ពីអង្គការដោយផ្ទាល់តាមរយៈ ហ៊ូវ ។ ពេលនោះ អង្គការបានចាត់ ទុំ ឲ្យធ្វើជាកម្មាភិបាលបណ្តោះអាសន្នសម្រាប់ធ្វើនយោបាយទាក់ទងពួកទាហានឲ្យរត់ចូលមកកាន់តំបន់រំដោះ តែនៅពេលនោះ ទុំ បានធ្វើសកម្មភាពមកលើបដិវត្តន៍ជាបន្តបន្ទាប់រហូតដល់ឆ្នាំ១៩៧៣ ទើបរត់ចេញពីក្នុងជួរបដិវត្តន៍វិញ ។

ឆ្នាំ១៩៧៣ វួន បានភ្ជាប់ខ្សែជាមួយ ព្រំ នាទីអនុរោងចក្រមង្គលបូរី (អង្គការកម្ទេចហើយ) និង អ៊ីង នាទីប្រធានបច្ចេកទេសយោធាភូមិភាគពាយ័ព្យ ។ អ្នកទាំងពីរ (ជាខ្សែរបស់វៀតណាម) បានអប់រំ វួន បន្ថែមឲ្យធ្វើសកម្មភាព ធ្វើវិច្ឆេទកម្ម ឲ្យបានជាប់លាប់

ព្រោះអ្នកទាំងពីរមានគោលបំណងចង់កម្ទេចឈ្មោះ វិត ។ ចំណែក វិតក៏មានការប្រុងប្រយ័ត្នតាមដានខ្មាំង រកខ្មាំងក្នុងអង្គភាព តែ ព្រំ និង អ៊ឹង នៅតែធ្វើសកម្មភាពបាន ។ ឆ្នាំ១៩៧៣ វួន បានធ្វើការទាក់ទងឈ្មោះ ប៊ី ចេង, សេង និង យឹម ជាខ្សែរយៈរបស់ខ្លួន ដើម្បីរួមធ្វើសកម្មភាពអុកឡុកនៅក្នុងអង្គភាពនីមួយៗ រហូតបានធ្វើឲ្យឈ្មោះ សារាយ នៅក្នុងកងរត់ចូលទៅបន្ទាយទាហាននៅឃ្លាំងតាហែន ។ អង្គការត្រូវយកកម្មាភិបាលឲ្យទៅរៀនសូត្រ តែដល់ពេលមានយុទ្ធជនរត់ចូលទៅខាងទាហាន ហើយសាលារៀនក៏ត្រូវបែកការណ៍ដោយត្រូវយន្តហោះមកទម្លាក់គ្រាប់បែកនៅក្បែរសាលារៀន ត្រូវភូមិរបស់អ្នកស្រុកធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអស់ជាច្រើន ហើយការរៀនសូត្រក៏ត្រូវបានអង្គការឲ្យផ្អាកមួយរយៈសិនដែរ ។ នៅចុងឆ្នាំ១៩៧៣ អង្គការមានផែនការទៅជួយធ្វើសកម្មភាពនៅតំបន់៣ ពេលនោះ អ៊ឹង និង ព្រំ ត្រូវចុះទៅជាប់ជាមួយដែរ តែអ្នកទាំងពីរមានផែនការចាត់ឲ្យ វួន និងបក្ខពួកធ្វើវិច្ឆេទកម្មបំផ្លាញសម្ភារសំខាន់ៗពិសេស កាំភ្លើង និងគ្រាប់ ។ ពេលនោះ វួន មានភារកិច្ចជញ្ជូនសម្ភារមកឲ្យអ្នកនៅសមរភូមិ ហើយបានចាត់ឲ្យឈ្មោះ សេង ដែលជាខ្សែទាក់ទង ឲ្យយកគ្រាប់ទៅទម្លាក់ចោលក្នុងទឹកអស់១២កេះ ។

ឆ្នាំ១៩៧៤ វួន នៅជាប់ជាមួយ អ៊ឹង ដដែល ហើយក៏បានទទួលផែនការពី អ៊ឹង ជាបន្តបន្ទាប់ ។ ក្រោយមក អ៊ឹង បានប្រគល់មនុស្សចំនួនប្រាំនាក់ឲ្យមក វួន មានឈ្មោះ រិន, ឡេ, ភួន, កែវ និង ឈួម ដើម្បីធ្វើសកម្មភាពនៅតំបន់៣ ។ ក្រោយមក អង្គការមានផែនការវាយបន្ទាយអំពិល ។ ពេលនោះ អ៊ឹង បានណែនាំ វួន ធ្វើយ៉ាងណាកុំឲ្យវាយបន្ទាយអំពិលបាន ព្រោះអង្គការមានបំណងវាយឲ្យខ្ទេចខ្ទី មានកាំភ្លើងគ្រប់ធុនទាំងកាំភ្លើងតូច-ធំ ។ ពេលនោះ អ្នកបដិវត្តន៍ក៏ត្រូវទៅពិនិត្យសមរភូមិច្រើនដែរដើម្បីវាយឆាប់ៗ ។ នៅពេល វួន ទៅដល់ភូមិស្ដីដូង បានស្គាល់យុទ្ធជនម្នាក់ឈ្មោះ សៅ នៅកង៣០១ ហើយបានអប់រំយុទ្ធជននោះជាសម្ងាត់ ដោយឲ្យយុទ្ធជននោះនាំដំណឹងទៅប្រាប់ទាហានឲ្យប្រុងប្រយ័ត្ន ព្រោះអង្គការមានផែនការវាយបន្ទាយអំពិលនេះ ។ ហេតុនេះ ផែនការវាយបន្ទាយអំពិលរបស់អង្គការត្រូវបានផ្អាក ។ ខែសីហា វួន បានទទួលផែនការពី អ៊ឹង ឲ្យទៅចាប់ប្រជាជនបួននាក់យកទៅកម្ទេចចោលពីព្រោះប្រជាជនទាំងនោះ បាននិយាយមើលងាយដល់ អ៊ឹង ថា “ស៊ីបាយអស់បាយ ស៊ីអង្ករអស់អង្ករ” ។

ខែកុម្ភៈ ឆ្នាំ១៩៧៥ វួន បានភ្ជាប់ខ្សែជាមួយឈ្មោះ សាន លេខាកងពលទី១ និងបានកម្ទេចបញ្ជាការវរសេនាតូចអស់ពីរនាក់ឈ្មោះ កុក ស្លាប់ និង ផៃ របួសធ្ងន់ ដោសារមានទំនាស់នឹងគ្នា ។ ក្រោយមក សាន បានប្រគល់ខ្សែចាស់ដែលមកពីកងតំបន់មកនៅកងភាគពាយ័ព្យ និងបានខ្ទេសនាមឈ្មោះ ភឿ មកឲ្យ វួន សម្រាប់ទាក់ទងធ្វើសកម្មភាព ។ ក្រោយរំដោះបានបន្តិច វួន បានមកភ្ជាប់ខ្សែជាមួយ នៅ វិញ ហើយនៅពេលនោះដែរ អង្គការបានដក នៅ ពីកងតំបន់៥ ឲ្យទៅនៅក្នុងកងទ័ពភាគពាយ័ព្យ និងបានទទួលនាទីជាអនុលេខាកងពលទី១ និងបានដាក់ផែនការចំនួនបីចំណុចឲ្យ វួន គឺៈ

១) កសាងកម្លាំងក្បត់មកបង្កប់ក្នុងជួរបដិវត្តន៍

២) ទាក់ទងជាមួយថៃ អ៊ិន តាំ

៣) រៀបចំកងទ័ពដើម្បីវាយយកតំបន់ទី៣ ហើយរៀបចំទប់ទល់ និងទាក់ទងជាមួយ អ៊ិន តាំ ឲ្យជាប់ ដើម្បីមកជួយធ្វើសកម្មភាពប្រឆាំងជាមួយនឹងបក្សកុម្មុយនីស្ដកម្ពុជាដោយយកប្រទេសថៃធ្វើជាមូលដ្ឋាន ។ នៅចុងឆ្នាំ១៩៧៥ វួន បានទទួលភារកិច្ចឲ្យជ្រើសរើសយុទ្ធជនចូលធ្វើកងទ័ព ហើយសំណូមពររបស់អង្គការ គឺឲ្យរើសអ្នកដែលមានប្រវត្តិរូបល្អ ស្អាតស្អំ ។ ពេលនោះ នៅ បានដាក់ផែនការឲ្យ វួន ជ្រើសរើសយកអ្នកដែលមានឪពុកម្ដាយ បងប្អូន ឬសាច់ញាតិដែលធ្វើការបម្រើខ្មាំង យកមកឲ្យខ្លួនដើម្បីអប់រំ ។ វួន បានរើសមនុស្សដែលមាននិន្នាការដូចខាងលើបានចំនួន៨០នាក់ ហើយប្រគល់ឲ្យទៅ នៅ ទាំងអស់ ។ បន្ទាប់មក នៅ ក៏បានរៀបចំកងមួយផ្សេងពីគេ ដោយបច្ចុប្បន្នយុទ្ធជនទាំងនោះនៅក្នុងកងវរសេនាតូចលេ២០៧ កងពលទី១ ។ ក្រោយមកទៀត វួន បានទទួលផែនការពី នៅ ឲ្យទៅទាក់ទងជាមួយថៃនៅក្បែរភូមិ ម៉ក់ ហឹន ជាប់ព្រំដែន ។ ការទាក់ទងជាមួយថៃនេះ គឺដើម្បីឲ្យថៃជួយទាក់ទង អ៊ិនតាំ ដើម្បីរៀបចំផែនការឲ្យបានជាប់គ្នា នេះជាផែនការទាក់ទងជាមួយថៃដំបូង ។ បន្ទាប់មក នៅ បានខ្ទេសនាមឲ្យស្គាល់ឈ្មោះ គន នាទីជាលេខាវរសេនាតូច២១៧ ដើម្បីទាក់ទងធ្វើសកម្មភាព ។ ក្រោយមក វួន ក៏បានទាក់ទងជាមួយ គន ធ្វើសកម្មភាពបំភ្លៃមាគ៌ារបស់បក្សជាបន្តបន្ទាប់ ។

ឆ្នាំ១៩៧៦ វ៉ន បានទទួលផែនការពី នៅ ឲ្យទៅប្រាប់ អ៊ិន តាំ ឲ្យឆាប់ដកថយចេញពីភ្នំម៉ាឡៃជាប្រញាប់ ព្រោះខ្លួន (នៅ) បានទទួលផែនការពីអង្គការឲ្យទៅវាយពួក អ៊ិន តាំ ដោយអង្គការដឹងថាពួក អ៊ិន តាំ នៅភ្នំម៉ាឡៃ ។ ពេលនោះ វ៉ន មានភារកិច្ចទៅស៊ើបការណ៍មុន ។ ពេលទៅដល់ភ្នំម៉ាឡៃ វ៉ន បានជួបនឹងទាហាន អ៊ិន តាំ ពីរនាក់នៅក្បែរភ្នំម៉ាឡៃ ហើយក៏បានទាក់ទងឲ្យទាហាន អ៊ិន តាំ ទាំងពីរឲ្យឆាប់ដកទ័ពចេញពីទីនោះជាបន្ទាន់ ។ បន្ទាប់មកពួកទាហាន អ៊ិន តាំ បានដកចេញពីកន្លែងនោះ ហើយធ្វើដំណើរឆ្ពោះទៅភ្នំបារាំងធ្លាក់ ដល់ពេលកងទ័ពបដិវត្តន៍ទៅដល់ទីតាំងដែលទ័ព អ៊ិន តាំ បោះទ័ពស្នាក់នៅភ្នំម៉ាឡៃ គឺមិនបានឃើញទាហាន អ៊ិន តាំ ទេ ឃើញតែរោងទទេតែប៉ុណ្ណោះ ។ ក្រោយមកទៀត វ៉ន បានប្រាប់ឲ្យពួក អ៊ិន តាំ ត្រៀមចាំវាយកងទ័ពបដិវត្តន៍ នៅភ្នំបារាំងធ្លាក់ ។ លុះដល់ពេលកងទ័ពបដិវត្តន៍ទៅដល់ភ្នំនោះ ពួកទាហាន អ៊ិន តាំ ដែលបានត្រៀមចាំរួចជាស្រេចនោះ បានបាញ់មកលើកងទ័ពបដិវត្តន៍បណ្ដាលឲ្យស្លាប់ចំនួន៩នាក់ ដោយព្រៃស្តុក ហើយផ្លូវមានតែមួយច្រក ហេតុនេះកងទ័ពបដិវត្តន៍ក៏បានដកថយមកវិញ ។ នៅចុងឆ្នាំ១៩៧៦ វ៉ន បានទទួលយុទ្ធជន៦នាក់ ព្រមទាំងកាំភ្លើង៦ដើមផង យកទៅប្រគល់ឲ្យ អ៊ិន តាំ ។ បន្ទាប់មក វ៉ន បានទៅបំផុសអប់រំមេឃុំឈ្មោះ សាប់ នៅភូមិសំរោងឲ្យឆាប់ភាសខ្លួនចាកចេញពីភូមិ ព្រោះខ្លាចអង្គការកម្ទេចចោល ។ មេឃុំ សាប់ ក៏បានកេណ្ឌបានមនុស្សចំនួន២៦នាក់ផ្សេងទៀត រត់ចេញទៅថៃ ។ នៅខែមីនា វ៉ន បានទទួលផែនការពី សាន និង នៅ៖

១) ឲ្យទាក់ទងជាមួយថៃ និង អ៊ិន តាំ ដើម្បីរកច្រកចេញទៅនៅដីថៃ ទាំងកងទ័ព និងប្រជាជន

២) រៀបចំកងទ័ពពិសេសមួយវរសេនាតូច៧នាក់ ដើម្បីទាក់ទងធ្វើការងារជាមួយ អ៊ិន តាំ

៣) សម្លាប់ប្រជាជនដោយបង្អត់បាយ ឬបំពុល ពិសេសប្រជាជនមូលដ្ឋានចាស់ ដែលមានជំហរច្បាស់លាស់ចំពោះបដិវត្តន៍ ។ ក្រោយពីបានទទួលភារកិច្ចនេះហើយ វ៉ន មានភារកិច្ចមួយផ្សេងទៀត គឺត្រូវធ្វើការទាក់ទងជាមួយចៅហ្វាយស្រុកអារញ្ញឈ្មោះ ឡុង នៅខាងជើងប៉ោយប៉ែត ដើម្បីឲ្យឈ្មោះ ឡុង ចាំទទួលយកប្រជាជនដែលបានភាសខ្លួនមកដោយជួយឧបត្ថម្ភផង ហើយចៀសវាងកុំធ្វើបាបឲ្យសោះ ។ ចាប់ពីពេលនោះមក វ៉ន និង ឡុង ក៏បានទាក់ទងជាមួយគ្នាជាប់រហូតមក ។ បន្ទាប់មកទៀត វ៉ន បានធ្វើសកម្មភាពយកប្រជាជននៅភូមិសូរីយា ដែលជាប្រជាជនមូលដ្ឋានចាស់ ហើយដែលមានទំនាស់អំពីរបបសមូហភាពទៅសម្លាប់ចោល ។

នៅឆ្នាំ១៩៧៧ វ៉ន បានទៅបំផុស អប់រំមេកងតូចដោយនិយាយថា «ពីរថ្ងៃមុខ ខ្ញុំបានឮអង្គការនិយាយថា នឹងបម្រុងដកទ័ពមួយកងតូចនេះចេញពីព្រំដែន» ហើយថែមទាំងបាននិយាយពីថៃនៅពេលឃើញខ្មែររត់ចូលទៅ គេជួយឧបត្ថម្ភ គេចិញ្ចឹមយើង ។ ពេលបានឮដូច្នេះ មេកងតូចនោះ ក៏បានទៅអប់រំយុទ្ធជនរបស់គាត់ឲ្យរត់ចេញទៅថៃទាំងអស់ ដោយមានជាប់ទៅជាមួយនូវអាវុធម្នាក់មួយដើមផង ។ បន្ទាប់មក វ៉ន បានទៅទាក់ទងជាមួយថៃ ហើយបានជួបជាមួយស័ក្តិ៣ឈ្មោះ កែវ សាខន នៅបន្ទាយអាងសីឡាជាប់ព្រំដែន ដើម្បីឲ្យ កែវ សាខន មកជួបជាមួយ នៅ ដោយផ្ទាល់នៅឫស្សីស្រុកដើម្បីឲ្យ កែវ សាខន ទទួលស្គាល់ ហើយឲ្យជួយដោះស្រាយបញ្ហាគ្រប់បែបយ៉ាងដែល នៅ ត្រូវការ ។ ម្យ៉ាងទៀត គឺទាក់ទងជាមួយ អ៊ិន តាំ ដើម្បីឲ្យ អ៊ិន តាំ ជួយធ្វើសកម្មភាពមកខាងក្នុង (ប្រទេសកម្ពុជា) ឲ្យជ្រៅ ដើម្បីអុកឡុក ធ្វើមិនឲ្យអង្គការកសាងសង្គមនិយមបានឆាប់រហ័ស រារាំងចលនាបដិវត្តន៍ឲ្យជាប់ ។ ម្យ៉ាងទៀត ការទាក់ទងនេះ ទុកសម្រាប់ប្រើពេលមានអាសន្ន ត្រូវចេញទៅទឹកដីថៃជាមួយ អ៊ិន តាំ ។ វ៉ន បានធ្វើការទាក់ទងផ្ទាល់ជាមួយ អ៊ិន តាំ បានពីរដងនៅបន្ទាយអាងសីឡាជាប់ព្រំដែនខ្មែរ-ថៃ ។ វ៉ន បានទទួលផែនការពី នៅ យកមកអនុវត្តជាបន្តបន្ទាប់ជាប់រហូតមកដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧៧ ទើបត្រូវអង្គការចាប់ខ្លួនតែម្តង ។

នៅពីរទំព័រចុងក្រោយនៃឯកសារចម្លើយសារភាពរបស់ វ៉ន ជាបញ្ជីរាយឈ្មោះបក្សពួកក្បត់របស់ វ៉ន ចំនួន២៧នាក់ ដែលក្នុងនោះ មានសរសេរឈ្មោះ មានបញ្ជាក់ពីតួនាទីច្បាស់លាស់ និងឈ្មោះអង្គភាពរបស់សមាជិកម្នាក់ៗ ។ នៅទំព័រចុងក្រោយមានសរសេរថា «ពួកធ្វើឯកសារ ពិនិត្យចប់ថ្ងៃ៤-៩-៧៧» ព្រមទាំងមានចុះហត្ថលេខារបស់អ្នកធ្វើឯកសារឈ្មោះ មិត្ត ទិត ផង ។

**ឆេង ខេង**

# តាំង អាន ហៅ អេន ប្រធានយោធាវរសេនាតូច៧០៩ វរសេនាធំ៦០២ កងពល១៧៤ ភូមិភាគកណ្ដាល

***ដកស្រង់ចេញពីឯកសារលេខ D៤១២៧៩***

ឈ្មោះ តាំង អាន ហៅ អេន ភេទប្រុស អាយុ២៨ឆ្នាំ (គិតត្រឹមឆ្នាំ១៩៧៧) កើតនៅភូមិសម៉ចិនសង្កាត់ពោរុំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ មុនអង្គការចាប់ខ្លួនមានតួនាទីជាអនុលេខាវរសេនាតូចលេខ៧០៩ វរសេនាធំ៦០២ កងពលទី១៧៤ នៅក្រុងកំពង់ចាម ភូមិភាគកណ្ដាល ។ អេន ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ១៩៧៧ ។ នៅក្នុងចម្លើយសារភាពរបស់ អេន ចែកចេញជាពីរ គឺចម្លើយលើកទី១ សួរដោយឈ្មោះ ឈុន ធ្វើចប់នៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៧៧ មានចំនួន១៨ទំព័រ និងចម្លើយលើកទី២ សួរដោយឈ្មោះ អឿន ធ្វើចប់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៧៧ មានចំនួន២៩ទំព័រ ។ ចម្លើយសារភាពទាំងពីរលើកនេះ អេន បានសរសេររៀបរាប់ពីប្រវត្តិសកម្មភាពក្បត់របស់ខ្លួនរួមជាមួយបក្ខពួកធ្វើការប្រឆាំងនឹងបដិវត្តន៍ ។ យើងមិនដឹងថាការឆ្លើយសារភាពរបស់ អេន ពិតប៉ុណ្ណាទេ ។ ខាងក្រោមនេះ ជាសេចក្ដីសង្ខេបដែលបានដកស្រង់ចេញពីចម្លើយសារភាព



រូបថតជនរងគ្រោះមិនស្គាល់អត្តសញ្ញាណ ដែលត្រូវបានធ្វើទារុណកម្មសម្លាប់ នៅមន្ទីរស-២១ ថតដោយ ហូ វ៉ាន់ តៃ អ្នកថតរូបជនជាតិវៀតណាម និងក្រុមការងាររបស់គាត់ ឌិញ ហ៊ុង កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ ។

របស់ តាំង អាន ហៅ អេន៖

កាលពីក្មេង អេន បានរៀននៅវត្តសាម៉ាលាវ សង្កាត់ពោរ៉ុ ចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ លុះដល់ឆ្នាំ១៩៦៦ អេន បានប្រឡងចូលរៀននៅអនុវិទ្យាល័យក្រាំងស្លា សង្កាត់ស្មោ ស្រុកព្រៃកប្បាស រហូតដល់ឆ្នាំ១៩៦៩ រៀនដល់ថ្នាក់ទី៤ បន្ទាប់មកក៏ឈប់រៀន ហើយមកជួយធ្វើការងារឪពុកម្តាយវិញ ។ ពេលនោះ ឪពុកម្តាយរបស់ អេន បានផ្លាស់ប្តូរទីកន្លែងមករស់នៅភូមិខ្ទួយ សង្កាត់អូរម្ជ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ហើយ អេនក៏បានមករស់នៅជាមួយឪពុកម្តាយដែរ ។ នៅឆ្នាំ១៩៧២ អេន បានចូលរួមធ្វើសកម្មភាពក្នុងបាតុកម្មមួយ ដែលមានអាចារ្យឈ្មោះ ចឹក និងលោកតាប៉ាង មេវត្តខ្ទួយ ជាអ្នកដឹកនាំធ្វើបាតុកម្មនេះ ដើម្បីទាមទារយកសាសនាមកវិញ ។ បាតុកម្មនេះធ្វើអស់រយៈពេលពីរម៉ោង ។ ឆ្នាំ១៩៧៣ អេន បានចូលធ្វើបដិវត្តន៍តាមរយៈឈ្មោះ តាប៉ិត ជាសង្ក្រាជវត្តស្រែវាល ដែលបានមកឃោសនានៅភូមិ ។ ក្រោយពីបានចូលបដិវត្តន៍ហើយ អេន បានមករស់នៅក្នុងអង្គភាព យោធា៨០៧ ជាយោធាតំបន់៤២ ដែលមានឈ្មោះ ស៊ឹម ជាប្រធាននយោបាយវរសេនាតូច ឈ្មោះ រាប អនុលេខាវរសេនាតូច និងឈ្មោះ ហេង ជាសមាជិកវរសេនាតូច ។ អេន រស់នៅក្នុងអង្គភាព៨០៧ បានប្រហែលបួនប្រាំខែ ឈ្មោះ ស៊ឹម ក៏បានចាត់ អេន និងឈ្មោះ ថន ឲ្យទៅទទួលខុសត្រូវនៅកងថ្មី ដែលអង្គការទើបនឹងរៀបចំឡើង ហើយ ស៊ឹម បានណែនាំ អេន ឲ្យទៅជួបឈ្មោះ វ៉ើង នៅសូភាស ។ ក្រោយពីជួប វ៉ើង ហើយ អេនក៏បានធ្វើដំណើរមកសមរភូមិដោយបានបោះទីតាំងនៅភូមិមាំងផរ សង្កាត់ទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ បន្ទាប់មក វ៉ើង បានហៅ អេនឲ្យទៅនៅជាមួយ តែមិនទាន់ប្រគល់ភារកិច្ចអ្វីឲ្យធ្វើនៅឡើយទេ ។ ក្រោពីមានការទុកចិត្ត អេន ហើយ វ៉ើង បាននិយាយជាមួយ អេន ថា "តើមិត្តសុខចិត្តរស់នៅជាមួយខ្ញុំដែរឬទេទៅអនាគត? ហើយបើជួបឧបសគ្គ តើមិត្តសុខចិត្តស្លាប់រស់ជាមួយគ្នាដែរឬទេ? បើមិត្តនៅជាមួយខ្ញុំហើយ ខំធ្វើការតាមការណែនាំរបស់ខ្ញុំ អនាគតមិត្តនឹងមានកិច្ចការធ្វើពុំខាន" ។ ពេលនោះ អេន មិនមានការស្មុគស្មាញអ្វីទេ ហើយក៏បានយល់ព្រមធ្វើតាមការណែនាំរបស់ វ៉ើង ទាំងអស់ ។ ក្រោយពីដឹងថា អេន សុខចិត្តចូលបម្រើខ្លួនហើយ វ៉ើង ក៏បានអប់រំ អេន ឲ្យចូលរួមជួយធ្វើសកម្មភាពបំផុសយុទ្ធជនឲ្យប្រឆាំងនឹងមាគ៌ាបដិវត្តន៍ព្រមទាំងបង្កប់ខ្លួនអង្គភាព បំផុសឲ្យយុទ្ធជនរត់ចោលអង្គភាព និងរត់ចូលខ្មាំង ។ នៅខែតុលា ឆ្នាំ១៩៧៣ វ៉ើង បានចាត់ អេន ឲ្យរស់នៅតាមកងដោយទទួលភារកិច្ចជាយោធាកងធំ ។ អេន បានយកផែនការរបស់ វ៉ើង មកអនុវត្ត គឺនៅចុងឆ្នាំ១៩៧៣ នៅសមរភូមិមានការខ្វះខាតពិសេសផ្នែកជីវភាពរស់នៅ ។ អេន បានធ្វើឲ្យយុទ្ធជនរត់ចោលអង្គភាព ដោយបានអប់រំអ្នកទាំងនោះតាមខ្លឹមសារ៖

ទី១) ធ្វើបដិវត្តន៍នៅខាងមុខ និងនៅខាងក្រោយមានការខុសគ្នាឆ្ងាយណាស់ នៅខាងក្រោយទោះបីលំបាកយ៉ាងណាក៏មិនស្លាប់ នៅសមរភូមិ ដេកហាលភ្លៀងហាលខ្យល់ អត់ឯងងុយទល់ភ្លឺរាល់ថ្ងៃ ហើយមិនកំណត់ក្នុងការរស់ឬស្លាប់ទៀត ។ បើនៅសមរភូមិក្រោយវិញ មិនមានអ្វីនាំឲ្យស្មុគស្មាញទេ ។

ទី២) យើងវាយខ្មាំង បើមានការខ្វះខាតយ៉ាងនេះ គ្មានលទ្ធភាពវាយឈ្នះសត្រូវទេ ព្រោះសត្រូវវាមានអាវុធគ្រប់គ្រាន់ ។ ឯយើងវិញ មានអាវុធពាក់កណ្តាលស្វ័យប្រវត្តិ ដូច្នេះយើងគ្មានលទ្ធភាពវាយឈ្នះសត្រូវបានទេ ។ ជាលទ្ធផល អេន បានអប់រំយុទ្ធជននៅក្នុងកងទាំងមូលឲ្យស្ថិតនៅក្នុងសភាពអស់ជំនឿលើបក្ស ធ្វើឲ្យចលនាវាយខ្មាំងត្រូវស្ទះ ដោយពេលនោះ យុទ្ធជនបានរត់ទៅក្រោយអស់ចំនួន១៥នាក់ រត់ចូលខ្មាំងចំនួន៣នាក់ ។ កិច្ចការខាងលើ អេន បានបន្តធ្វើរហូតដល់ឆ្នាំ១៩៧៤ ។ ថ្ងៃមួយ វ៉ើង បានហៅ អេន ឲ្យទៅជួបហើយបានណែនាំឲ្យស្គាល់ខ្សែរយៈរបស់ខ្លួនមួយចំនួនមានឈ្មោះ ស៊ឹម, រាប, ហេង, ដៃ, សែ, នា, ស៊ុន និង ជាតិ ដើម្បីងាយស្រួលទាក់ទងធ្វើការងារ ។

ឆ្នាំ១៩៧៤ វ៉ើង បានចាត់តាំង អេន និង ស៊ុន ឡើងវាយទីតាំងរបស់ខ្មាំងនៅមុខព្រួញផ្លូវជាតិលេខ៧ ។ ពេលកំពុងវាយ អេន និង ស៊ុន បានបញ្ជាទ័ពឲ្យដកថយមកក្រោយវិញ បណ្តាលឲ្យកងទ័ពរបួស៦នាក់ ពលីពីរនាក់ និងបាត់បង់អាវុធអាកាមួយដើម ។ បន្ទាប់មក អេន បានបន្តជំរុញសកម្មភាព ដោយធ្វើឲ្យមានការជ្រួលច្របល់នៅតាមខ្សែត្រៀមនៅពេលយប់ស្ងាត់ ដោយលួចបាញ់ពីក្រោយ ឬលួចគប់គ្រាប់បែក ធ្វើឲ្យគ្រោះថ្នាក់ដល់កម្លាំងរបស់បដិវត្តន៍ជាបន្តបន្ទាប់ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៤ វ៉ើង បានចាត់

អេន ឲ្យទៅទាក់ទងជាមួយឈ្មោះ សែ ដើម្បីសហការពង្រឹងពង្រីកសកម្មភាពសម្ងាត់ថែមទៀត ។ ក្រោយពីបានជួបជាមួយ សែ មក អ្នកទាំងពីរបានពិភាក្សាគ្នា ឲ្យបន្តទិតទំ និងជំរុញសកម្មភាពផែនការសម្ងាត់ឲ្យមានសភាពរស់រវើកនៅតាមមុខសញ្ញានីមួយៗ ក្នុងន័យបង្កើននូវសកម្មភាពដឹកនាំប្រឆាំងនឹងចលនាបដិវត្តន៍ ដើម្បីធ្វើឲ្យការវាយខ្មាំងរបស់បដិវត្តន៍មានចលនាយឺត ។ ពេលបែកពី សែ មកកន្លែងវិញ អេន និង នា បានសហការគ្នា បន្តសកម្មភាពអនុវត្តផែនការ បណ្តោយឲ្យខ្មាំងឡើងធ្វើសកម្មភាពតាមចិត្ត ហើយឥតមានរៀបចំកម្លាំងវាយទប់ស្កាត់ចលនារបស់ខ្មាំងឡើយ ធ្វើឲ្យខ្មាំងប្រមូលកម្លាំងវាយបុកផ្តាច់ខ្សែត្រៀម ធ្វើឲ្យយុទ្ធជនរបួស និងពលីអស់ចំនួន១៣នាក់ ។ ការណ៍ដែលធ្វើនេះ គឺក្នុងគោលបំណងបំបាក់ស្មារតីយុទ្ធជន កម្មាភិបាល និងបំផ្លាញកម្លាំងបដិវត្តន៍ ។ បន្ទាប់មកទៀត ដោយមានផែនការវាយទីតាំងខ្មាំង វើង បានចាត់តាំង អេន ឲ្យទៅរួមសហការជាមួយ ស៊ីម ដើម្បីរៀបចំផែនការវាយទីតាំងរបស់ខ្មាំង ធ្វើយ៉ាងណាឲ្យទទួលបរាជ័យពេលវាយសម្រុក ។ ពេលផែនការវាយខ្មាំងមកដល់ វើង និង ស៊ីម បានចាត់ អេន, នា និង ដៃ ឲ្យឡើយវាយ នៅពេលដែលខ្មាំងជិតបាក់ស្មារតីចាញ់ហើយ អេន, នា និង ដៃ បានបញ្ជាទ័ពឲ្យដកថយវិញ ។ ក្រោយមក នៅតាមមុខព្រួញនីមួយៗ បានរៀបចំសំណាញ់ឈ្លប ។ ការធ្វើសំណាញ់ឈ្លបនេះ អេន បានអប់រំយុទ្ធជន និងកម្មាភិបាលមិនឲ្យខំប្រឹងប្រែងពេកទេ ។ អេន បានអប់រំយុទ្ធជនឲ្យមានការស្មុគស្មាញក្នុងការបំពេញភារកិច្ចតាំងពីដំបូង ដោយមានខ្លឹមសារថា “យើងវាយខ្មាំងមួយគ្រាប់ៗយ៉ាងនេះ មិនងាយឈ្នះវាទេ ព្រោះផែនការវាយទីតាំងធំៗម្តងៗ ប្រើអាវុធសម្បូរបែបផង នៅតែវាយមិនឈ្នះ ទំរាំយើងយកមួយគ្រាប់ៗ ទៅវាយវា បើប្រៀបធៀបទៅខុសគ្នាឆ្ងាយណាស់ យើងមិនបាច់ប្រឹងពេកទេ ធ្វើឲ្យតែគ្រប់ផែនការទៅបានហើយ” ។ បន្ទាប់មក សកម្មភាពវាយខ្មាំង ស្ថិតនៅក្នុងសភាពធម្មតា គឺមិនសកម្ម និងមិនខ្លាំង ។ នៅក្នុងឆ្នាំដដែលនេះ អេន បានបន្តសកម្មភាពរបស់ខ្លួន សហការគ្នាពីកន្លែងមួយទៅកន្លែងមួយទៀត ដោយបានឃោសនាអប់រំយុទ្ធជនមិនឲ្យខំវាយខ្មាំង ដើម្បីធ្វើឲ្យស្ទះដល់ចលនាវាយសម្រុក ។

ឆ្នាំ១៩៧៥ ដោយមានផែនការវាយទូទាំងប្រទេស ពេលនោះការវាយសម្រុកខ្មាំងស្ថិតនៅក្នុងសភាពមួយមិនខ្លាំងក្លាទេ ក្រោមការដឹកនាំរបស់ អេន និងខ្សែរយៈ បានធ្វើឲ្យចលនាវាយសម្រុកខ្មាំងត្រូវវិវត្តថយក្រោយវិញ ។ អេន បានអនុវត្តតាមផែនការដូចខាងលើរហូតមកដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ។ នៅពេលចូលក្រុងបានកន្លះខែ អេន មិនបានធ្វើសកម្មភាពអ្វីទេ ។ បន្ទាប់មក កងទ័ពក៏ត្រូវបានរំសាយ ហើយមកនៅការពារជុំវិញក្រុងវិញ ដើម្បីរៀបចំលក្ខណៈសម្បត្តិធ្វើស្រែខបត្តម្ពខ្លួន ។ អេន បានរក្សាការទាក់ទងជាមួយ នា និង សែ ដដែល ហើយបានបន្តសកម្មភាពដោយរៀបចំផែនការធ្វើឲ្យរាំងស្ទះដល់ចលនាបដិវត្តន៍ និងធ្វើឲ្យខូចខាតសន្ទូង ។ អេន និងបក្ខពួក បានអប់រំយុទ្ធជនឲ្យសេរី ភ្លើតភ្លើន និងជ័យជម្នះ ភ្លេចបំពេញភារកិច្ចរបស់ខ្លួន ។ ក្នុងការធ្វើស្រែដំបូង អេន និងបក្ខ បានធ្វើសកម្មភាពដូចជា សាបស្រូវរួច ទុកទឹកឲ្យនៅក្នុងស្រែបីបួនថ្ងៃ មិនបើកបង្ហូរទឹកចេញពីថ្នាលសំណាបទេ បណ្តាលឲ្យគ្រាប់ស្រូវរលួយខូចអស់ ពេលស្ទូងស្រូវ បានបញ្ជាមិនឲ្យបើកបង្ហូរទឹកចេញពីស្រែទេ ទុកឲ្យសន្ទូងលិចទឹករលួយខូចខាតអស់ ពេលស្រូវកើតរោគ មិនបានរកថ្នាំមកបាញ់ទេ បណ្តាលឲ្យស្រូវចុះថយគុណភាព ។ ពេលមានទឹកជំនន់ អេន បានបិទទប់ទឹកឲ្យហូរចូលស្រែលិចស្រូវ ធ្វើឲ្យស្រូវរលួយខូចអស់បីបួនហិកតា ហើយនៅពេលស្រូវកំពុងត្រូវការទឹក បានបើកបង្ហូរទឹកចេញ ធ្វើឲ្យស្រូវនៅកន្លែងខ្លះដែលគ្មានទឹក ត្រូវស្កកខូចស្រូវអស់បួនប្រាំហិកតាទៀត ។ នៅចុងឆ្នាំ១៩៧៥ អេន កសាងកម្លាំងបានម្នាក់ឈ្មោះ ឡាយ ដោយត្រូវចំណាយពេលកន្លះខែក្នុងការអប់រំម្នាក់នេះ ។

ឆ្នាំ១៩៧៦ ស៊ីម និង រាប បានចាត់ អេន ឲ្យទទួលខុសត្រូវធ្វើស្រែប្រាំង ពេលនោះ អេនរួមជាមួយ ឡាយ បានធ្វើសកម្មភាពបំផ្លាញស្រូវប្រាំងអស់ពីរហិកតា និងធ្វើឲ្យខូចម៉ាស៊ីនបូមទឹកអស់មួយគ្រឿង ។ ជាបន្តបន្ទាប់ អេន កសាងកម្លាំងបានចំនួន៥នាក់ មានឈ្មោះ ឈឹម, កន, វី, ថន និង ម៉ៅ ។ នៅថ្ងៃមួយនាពាក់កណ្តាលឆ្នាំ ស៊ីម បានហៅ អេនឲ្យទៅជួបនៅកន្លែងរបស់ខ្លួន ដើម្បីរៀបចំផែនការបន្តធ្វើសកម្មភាព ដោយពេលនោះ ស៊ីម បានអប់រំ អេន ឲ្យលួចអាវុធនៅតាមអគ្គភាព និងនៅតាមរោងយាម ។ បន្ទាប់ពីទទួលការអប់រំរួច អេន បានសហការជាមួយ សែ និង នា ដោយបានចាត់ ឡាយ និង ឈឹម ឲ្យធ្វើសកម្មភាព ។ អ្នកទាំងពីរ

បានធ្វើសកម្មភាពលួចបានកាំភ្លើងអាកាចំនួនពីរដើម ហើយយកមកប្រគល់ឲ្យ អេន ៗ ក៏បានប្រគល់បន្តឲ្យទៅ ស៊ឹម ។ ស៊ឹម ក៏បានយកអាវុធនេះ ឲ្យទៅពេទ្យឈ្មោះ សែន ដែលឈ្មោះ សែន នេះជាពេទ្យឃ្លង់សម័យបដិវត្តន៍ ហើយបានរត់ចូលព្រៃដោយមានគ្នីគ្នាមួយក្រុមស្ថិតនៅក្នុងព្រៃវិហារធំ សង្កាត់វិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម (តែក្រុមនេះបច្ចុប្បន្នត្រូវអង្គការចាប់ខ្លួនអស់ហើយ) ។ នៅចុងឆ្នាំ១៩៧៦ ស៊ឹម និង រាប បានចាត់តាំង អេន ឲ្យទៅប្រូតស្រូវនៅវាលក្រោម ខេត្តកំពង់ធំ តែដោយស្រូវពុំទាន់ទុំល្អ អេន បានទៅជួប វើង ហើយក៏បានរាយការណ៍ពីសកម្មភាពដែលបានធ្វើកន្លងមកប្រាប់ទៅ វើង រួចមក វើង ក៏បានប្រាប់ អេន ឲ្យបានដឹងពីកម្លាំងដែលបានរួមធ្វើសកម្មភាពជាមួយខ្លួនចំនួន៦នាក់ និងបានណែនាំឲ្យស្គាល់ក្រុមនីរសាររបស់ខ្លួនផ្ទាល់ចំនួន៩នាក់ថែមទៀត ដើម្បីងាយស្រួលទាក់ទងគ្នាពីធ្វើការពីកន្លែងមួយទៅកន្លែងមួយទៀត ។ ចប់ភារកិច្ច អេន ក៏បានលា វើង ត្រឡប់មកកំពង់ចាមវិញ ។ បន្ទាប់មក ស៊ឹម បានហៅ អេន ឲ្យទៅជួបហើយបានឲ្យ អេន បន្តធ្វើសកម្មភាព ដើម្បីបំផ្លាញកម្លាំងបដិវត្តន៍ ដោយយកអាវុធត្រៀមស្ទាក់ចាំបាញ់យុទ្ធជន និងកម្មាភិបាលដែលធ្វើដំណើរតាមផ្លូវពេលយប់ស្ងាត់ ។ ចំពោះកិច្ចការនេះ អេន បានចាត់តាំងបន្តឲ្យ ឡាយ, ឈឹម, តន ធ្វើសកម្មភាពនេះ ហើយជាលទ្ធផល អ្នកទាំងបីបានបាញ់យុទ្ធជនម្នាក់ឈ្មោះ ធឿន ស្លាប់ បន្ទាប់មកបានបាញ់ឲ្យយុទ្ធជនម្នាក់ទៀតរបួសត្រង់ដៃ ។

នៅឆ្នាំ១៩៧៧ ស៊ឹម បានហៅ អេន ឲ្យទៅកន្លែងរបស់ខ្លួន ហើយបានណែនាំឲ្យស្គាល់ខ្សែរយៈទាក់ទងដែលបានរួមធ្វើសកម្មភាពជាមួយគ្នាយូរមកហើយមានចំនួន១៥នាក់ ។ ក្រោយមក ស៊ឹម, ដួង និង រាប បានរៀបផែនការដោយហៅបក្ខពួកទាំងអស់ឲ្យចូលរួមប្រជុំនៅវត្តថ្មីខាងត្បូងក្រុងកំពង់ចាមក្នុងគោលបំណងវាយរំដោះទីក្រុងកំពង់ចាម ហើយរៀបចំសេរីរបបឯកជនឡើងវិញ ។ ក្នុងអង្គប្រជុំ ដួង បានលើកផែនការ ៖

១) រៀបចំកម្លាំងវាយតាមមុខសញ្ញានីមួយៗ

២) ពេលចូលដល់ក្រុង រៀបចំបោសសម្អាត និងកម្ទេចកម្មាភិបាល

៣) រៀបចំសេរីរើបង្កើតរបបឯកជន

៤) ពេលរំដោះបាន រៀបចំបោះទីតាំងជាមូលដ្ឋាន

៥) រៀបចំកម្លាំងបង្កប់តាមមូលដ្ឋាន នៅកន្លែងណាដែលខ្វះខាត ដើម្បីបំផុសទំនាស់ប្រជាជន និងកៀងគរកម្លាំងប្រជាជនឲ្យបានច្រើន ដើម្បីបន្តពង្រីក និងពង្រឹងចលនាឲ្យខ្លាំងក្លា ។ បន្ទាប់មក ដួង បានបញ្ជាក់ថា បញ្ហាអាវុធ គ្រាប់រំសេវ បើមានការខ្វះខាត មានឈ្មោះ លី សមាជិកកងពល១៧៤ (លី មាននាទីជាអ្នកទទួលខុសត្រូវសម្ភារ និងអាវុធគ្រាប់រំសេវក្នុងកងពលទាំងមូល ត្រូវអង្គការចាប់ខ្លួនហើយ) នៅខាងក្នុងជាអ្នកទទួលខុសត្រូវ ។ ដួង បានប្រាប់ឲ្យដឹងទៀតថា ចំពោះបញ្ហាកម្លាំងទាំងយុទ្ធជន-កម្មាភិបាល ត្រូវក្តាប់ឲ្យជាប់ កុំឲ្យរហេតរហូត សំខាន់កម្លាំងដែលយើងកសាងបានតាមអង្គភាពដែលជាកម្លាំងស្នូលដឹកនាំសំខាន់របស់យើង ។ ម៉្យាងទៀត យើងត្រូវអប់រំ បំផុសចលនាប្រឆាំងនឹងរបបសមូហភាពឲ្យដល់យុទ្ធជន ដើម្បីងាយស្រួលកៀងគរកម្លាំង ។ កម្លាំងដែលត្រូវវាយទាំងអស់មាន៧វរសេនាតូច ហើយកម្លាំងដែលត្រូវវាយចូលខាងលិចមានឈ្មោះ រាប, ហំ, សែ, នា, រុំ, នោជ និង ស៊ុន ។ មុខព្រួញវាយចូលខាងត្បូងមានឈ្មោះ ស៊ុម, ដួង, វ៉ាត, សែម, ថុង, ញោម, ឯក និង យន ។ មុខព្រួញខាងជើងមានឈ្មោះ វិន, សារាយ, ម៉េង, ដេង និង វឿន ។ ក្រោយពីលើកទិសហើយ ដួង បានអប់រំឲ្យបក្ខពួកខិតខំកសាងកម្លាំងឲ្យបានច្រើនថែមទៀត ដើម្បីសម្រេចផែនការនាពេលខាងមុខ ។ ផែនការនេះ ត្រូវអនុវត្តនៅខែកុម្ភៈ ឬខែមីនា តែពុំទាន់កំណត់ថ្ងៃឲ្យបានច្បាស់លាក់នៅឡើយ ។ ក្រោយពេលប្រជុំ អេន កសាងកម្លាំបានបីនាក់ ។

នៅក្នុងខែកុម្ភៈ-មីនា អង្គការបានចាប់ខ្សែរយៈទាក់ទងរបស់ អេន ជាបន្តបន្ទាប់ ដែលធ្វើឲ្យផែនការដែលបានរៀបចំខាងលើត្រូវបរាជ័យ ។ ពេលនោះ អេន មិនបានធ្វើសកម្មភាពអ្វីទេ ត្រូវសម្របខ្លួនជាមួយនឹងបដិវត្តន៍ ។ ក្រោយមក ក្នុងខែមីនា រាប បានហៅ អេន ឲ្យទៅចូលរួមប្រជុំនៅភ្នំ ដើម្បីរៀបចំផែនការថ្មី ។ ខ្លឹមសារនៃការប្រជុំនោះគឺ ៖

១) រៀបចំដុត និងបំផ្លាញផលស្រូវវស្សា និងស្រូវប្រាំង

២) រៀបចំបង្កើននូវរបបឯកជនតាមអង្គភាពនីមួយៗ ឲ្យខ្លាំង

៣) បន្តជំរុញការកសាងកម្លាំង ដើម្បីពង្រីកសកម្មភាពឲ្យ

បានខ្លាំងក្លា ។ បន្ទាប់មក រាប បានទទួលនាទីជាសមាជិកកងពល ១៧៤ ។ បន្ទាប់ពីបានចូលរួមប្រជុំមក អេន បានយកផែនការនេះ មកអនុវត្ត ដោយបានរៀបចំបង្កើតរបបឯកជនប្រឆាំងនឹងរបប សមូហភាព ពិសេសរៀបចំថ្នាក់កម្មាភិបាល ហើយបានរៀប ផែនការបំផ្លាញផលស្រូវដោយបានចាត់តាំងឈ្មោះ កន ឲ្យធ្វើ សកម្មភាព ។ កន បានធ្វើឲ្យឆេះខូចខាតស្រូវមួយស្នឹមដែលពុំទាន់ បោកបែន ។ ក្រោយពេលធ្វើសកម្មភាពហើយ អេន បានរក្សា ស្ថានភាពធម្មតា ព្រោះពេលនោះ អង្គការកំពុងតាមដានខ្លាំងរក ចាប់ខ្លួនជនក្បត់ ។

ខែឧសភា ឆ្នាំ១៩៧៧ រាប បានហៅបក្ខពួកប្រជុំម្តងទៀត នៅជំរំ៧០៩ ដោយខ្លឹមសារនៃការប្រជុំ គឺគ្រាន់តែរំឭកអំពី ផែនការចាស់ និងធ្វើការបូកសរុបលទ្ធផលក្រោយពីបានអនុវត្ត កន្លងមក ។ ក្រោយពីប្រជុំចប់ អេនមិនបានធ្វើសកម្មភាពទេ ព្រោះ មានការភ័យព្រួយដោយអង្គការកំពុងស្រាវជ្រាវរកចាប់ខ្មែរក្បត់ ។ នៅក្នុងខែកក្កដា-សីហា រាប បានហៅបក្ខពួកប្រជុំម្តងទៀតនៅជំរំ ៧០១ រីឯខ្លឹមសារគឺ៖

១) រៀបចំផែនការតម្កល់ស្រូវ ពោត ទុកដើម្បីត្រៀម លក្ខណៈពេលវាយរំដោះក្រុង ម្យ៉ាងទៀតធ្វើឲ្យស្ទះដល់ការដោះ ស្រាយជីវភាពប្រជាជន និងកងទ័ព ។

២) រៀបចំផែនការវាយចូលក្រុងលើកទី២ ក្នុងរយៈពេល បុណ្យឌូប

៣) បន្តការកសាងកម្លាំង និងបំផុសទំនាស់ឲ្យខ្លាំង ដើម្បី កៀងគរកម្លាំងឲ្យបានច្រើន ។

◆ ផែនការទី១ ក្នុងការតម្កល់ស្រូវទុកនេះ មានចំនួនជិត ១០០តោន ទីកន្លែងគឺនៅក្នុងជង្រុកធំក្នុងកងពល មានឈ្មោះ លី នៅចាំទទួលខុសត្រូវ ស្រូវដែលសល់ទុកនេះ រួមទាំងស្រូវប្រាំង ស្រូវវស្សាឈ្មោះ លី និង រាប ឥតបានរាយការណ៍ជូនអង្គការភូមិ ភាគទេ ដើម្បីបំបាត់ស្រូវដែលសល់នេះទុកសម្រាប់ប្រើប្រាស់ ពេលមានផែនការ ព្រោះរៀងរាល់ឆ្នាំ ស្រូវដែលសល់ទោះតិចក្តី ច្រើនក្តី គឺរាយការណ៍ជូនអង្គការ ហើយចែករបបនេះឲ្យទៅប្រជា ជននៅកន្លែងណាដែលខ្វះខាត ។

◆ ផែនការទី២ រៀបចំផែនការវាយក្រុងកំពង់ចាមលើកទី២ ខ្លឹមសារនិងផែនការលើកទី២ គឺរៀបចំគម្រោងផែនការដូចលើក ទី១ដែរ ទាំងការរៀបចំកម្លាំង ទាំងការទាក់ទងអាវុធគ្រាប់រំសេវ ពេលចូលដល់ក្រុង ដោយមានឈ្មោះ លី ជាអ្នកទទួលដោះស្រាយ នៅខាងក្នុងស្រាប់ ។ ចំណែកមុខសញ្ញានៅរក្សាដដែលមាន រាប ទទួលខុសត្រូវរួម ឈ្មោះ វ៉ែន, ឈាន, សូត្រ, ផា, ញោ, ថេន, ទន, ឡាច ទទួលសុខត្រូវខាងលិចក្រុង ឈ្មោះ វឿន, ខា, កុល, ស្វាញ, ឈាត, ប៉ុក, អឿន, ស្រ៊ាន ចាំទទួលនាំកម្លាំងពីខាងត្បូង ឯខាងជើង មានឈ្មោះ ឥន្យ នីន្យ ឈិត្យ សេវ្យ សាំង ។

◆ផែនការទី៣ គឺជំរុញការកសាងកម្លាំងតាមអង្គភាពនីមួយៗ ឲ្យបានខ្លាំងក្លា និងធ្វើការអប់រំកៀងគរកម្លាំងឲ្យបានច្រើន ដើម្បី សម្រេចតាមផែនការ ដោយរៀបចំបង្កើនរបបឯកជនឲ្យខ្លាំង ហើយ លុបបំបាត់របបសមូហភាព ។ រីឯផែនការចូលក្រុង គឺរៀបចំដូច ផែនការទី១ដែរ ដោយចាប់ដៃគ្នានៅកណ្តាលក្រុង ។ រាប បានបន្ត ការអប់រំដល់បក្ខពួក ឲ្យខិតខំកសាងកម្លាំង និងបន្តការឃោសនា អប់រំឲ្យយុទ្ធជន ប្រឆាំងនឹងចលនាបដិវត្តន៍ឲ្យរឹតតែខ្លាំងក្លា ។ ក្រោយ ពីរៀបចំផែនការហើយទាំងអស់គ្នាក៏បានវិលមកកន្លែងរៀងៗខ្លួន ។ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧ មានផ្ទុះមីនពីរគ្រាប់ នៅកន្លែង ជួសជុលអាវុធ ធ្វើឲ្យកន្លែងនេះត្រូវខ្ទេចខ្ទីអស់ ឯកន្លែងសន្តិសុខ ភូមិភាគក៏ត្រូវបាក់ខ្ទេច ហើយទីលំនៅនៅជុំវិញកន្លែងផ្ទុះ ក៏ត្រូវ បាក់បែកដែរ ។ ក្រោយពីផ្ទុះមីននេះរួចមក អង្គការបានចាប់ខ្សែ រយៈរបស់ អេន ជាបន្តបន្ទាប់ ហើយ អេន ផ្ទាល់ ត្រូវបានអង្គការ ចាប់ខ្លួននៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៧ ។

តាមចម្លើយសារភាពរបស់ អេន បានសរសេរចប់នៅថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៧៧ ព្រមទាំងមានចុះហត្ថលេខា និងស្នាមផ្តិត មេដៃរបស់ អេន ផង ។ នៅផ្នែកខាងឆ្វេងស្នាមមេដៃរបស់ អេន មានសរសេរថា «៣១-១០-១៩៧៧ ពួកធ្វើឯកសារ និងមាន ចុះហត្ថលេខាដោយអ្នកសួរឈ្មោះ អឿន» ។ ហើយនៅទំព័របន្ទាប់ ខាងក្រោយចំនួន៦ទំព័រ ជាបញ្ជីរាយឈ្មោះជនក្បត់ដែលជាបក្ខ ពួករបស់ អេន សរុបចំនួន៦៧នាក់ ដែល អេន បានសរសេរ យ៉ាង ច្បាស់លាស់ពីឈ្មោះ តួនាទី អង្គភាពរបស់ម្នាក់ៗ ហើយដែលភាគ ច្រើននៃឈ្មោះនេះ បានដាក់ថា «ចាប់» ។

**ឆេង ម៉េង**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthsodavy.u@dccam.org* ។




















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ : ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ម៉ែន ពិចិត្រ ទូរសព្ទលេខ : ០២៣ ២១៨ ០០៩ អ៊ីម៉ែល : truthmpechet@dccam.org*

# យុវជន-យុវនារីបដិវត្តន៍យើង រំភើបរីករាយឥតឧបមាចំពោះ ដែលបក្សកុម្មុយនីស្តកម្ពុជាប្រកាសចេញជាចំហ ជាផ្លូវការ ទាំងក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ

*ដកស្រង់ចេញឯកសារយុវជន និងយុវនារីបដិវត្តន៍លេខពិសេស ខែកញ្ញា ឆ្នាំ១៩៧៧ D២១៤០៣*

កាលពីថ្ងៃទី២៧ កញ្ញា ឆ្នាំ១៩៧៧ កន្លងទៅនេះ បក្សកុម្មុយនីស្តកម្ពុជាយើង បានរៀបចំមហាមីទិញមួយនៅទីក្រុងភ្នំពេញ ដើម្បីទទួលអំណរខួបទី១៧ ដ៏មហាជោគជ័យ នៃកំណើតបក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ ។ ក្នុងឱកាសនេះ បក្សកុម្មុយនីស្តកម្ពុជា ក៏បានអនុញ្ញាតឲ្យយើងខ្ញុំជាយុវជន-យុវនារី តំណាងកម្មករសហជីព កសិករសហករណ៍ តំណាងកងទ័ពបដិវត្តន៍ និងតំណាងយុទ្ធជន-យុទ្ធនារីនៅតាមគ្រប់ក្រសួង មន្ទីរចូលរួមដែរ ។ អង្គមីទិញបានចាប់ផ្តើមនៅវេលាម៉ោង៧ព្រឹក ក្នុងបរិយាកាសមហាសាមគ្គីជាតិទូលំទូលាយ និងរីករាយខ្ទៀវខ្ទាក្រៃលែង ។

ក្រោយពីបានសម្តែងនូវការគោរព ដោយភាតរភាពបដិវត្តន៍យ៉ាងកក់ក្តៅ ចំពោះតំណាងគ្រប់រូប ដែលមានមុខក្នុងទីនោះហើយ សមមិត្តលេខាបក្សកុម្មុយនីស្តកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍អំពីប្រវត្តិតស៊ូរបស់ប្រជាជនកម្ពុជា ប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការដឹកនាំប្រជាជនកម្ពុជា ធ្វើបដិវត្តន៍អស់រយៈពេល១៧ ឆ្នាំកន្លងមកយ៉ាងពិស្តារ ។ នៅផ្នែកខាងដើមនៃខ្លឹមសារសេចក្តីថ្លែងការណ៍ដ៏មានអត្ថន័យ៉ាងជ្រាលជ្រៅនេះ សមមិត្តលេខាបក្សយើង បានមានប្រសាសន៍ដោយទឹកមុខញញឹម ហើយបានសង្កត់ពាក្យថាៈ "ក្នុងឱកាសនេះ ដែលយើងធ្វើបុណ្យខួបកំណើតឆ្នាំទី១៧ ដ៏មហាជោគជ័យរបស់បក្សកុម្មុយនីស្តកម្ពុជាយើង មានចំណុចពិសេស



កម្មករកំពុងធ្វើការនៅរោងចក្រតម្បាញ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) ។

មួយ ដែលខ្ញុំសូមជម្រាបជាផ្លូវការនៅទីនេះ ។ ក្នុងឱកាសរំលឹកខួបទី១៧ នៃកំណើតបក្សកុម្មុយនីស្តកម្ពុជាយើង នៅឆ្នាំនេះ បក្សយើងបានសម្រេចប្រកាសបក្សកុម្មុយនីស្តកម្ពុជាជាចំហ ជាផ្លូវការ ទាំងនៅក្នុងប្រទេស ទាំងនៅលើឆាកអន្តរជាតិ» ។ បក្សយើងខ្ទេសនាមឃ្លានេះ មិនទាន់ទាំងចប់ស្រួលបួលផង ស្នូរទះដៃ និងសម្រែកជ័យឃោសន៍ របស់តំណាងទាំងឡាយ បានលាន់ឮឡើងកងរំពងពេញកន្លែងមីទិញ ។ ពាក្យសំដីទាំងពីរឃ្លានេះ របស់លេខាបក្សយើង ពិតមែនតែខ្លី តែមានអត្ថន័យជាប្រវត្តិសាស្ត្រជ្រាលជ្រៅណាស់ ដែលពញ្ញាក់កន្ត្រាក់អារម្មណ៍តំណាងទាំងឡាយ ក៏ដូចជាយើងខ្ញុំជាយុវជន-យុវនារីបដិវត្តន៍ដែរ ឲ្យរំភើប ញាប់ញ័រ គ្មានអ្វីប្រៀបផ្ទឹមបានឡើយ ។ តាំងពីយើងខ្ញុំកើតឡើងដឹងក្តីមក យើងខ្ញុំមិនដែលបានជួបប្រទះនឹងព្រឹត្តិការណ៍អ្វី ឬដឹងឮអ្វីដែលធ្វើឲ្យយើងខ្ញុំរំភើប និងរំជើបរំជួលក្នុងចិត្តដូចពេលនេះទេ ។

យើងខ្ញុំជាយុវជន-យុវនារី កូនចៅប្រជាជនកម្មករ កសិករក្រីក្រ បានចូលបម្រើបដិវត្តន៍តាំងពីធំដឹងក្តីភ្លាមម្ល៉េះ ។ ដោយបានបក្សកុម្មុយនីស្តកម្ពុជាយកចិត្តទុកដាក់ ឃោសនាអប់រំ ទូន្មានកសាងជាបន្តបន្ទាប់ និងដោយបានសាកល្បង ហ្វឹកហ្វឺនក្នុងចលនាប្រយុទ្ធវាយសម្រុកខ្មាំងជាក់ស្តែងនៅគ្រប់សមរភូមិ នយោបាយ យោធា សេដ្ឋកិច្ចទាំងខាងមុខ ទាំងខាងក្រោយមក យើងខ្ញុំបានស្គាល់ច្បាស់នូវប្រវត្តិតស៊ូរបស់បក្សកុម្មុយនីស្តកម្ពុជាយើង ដែលពារពេញទៅដោយការលះបង់កម្រិតខ្ពស់បំផុត និងពលិកម្មគ្រប់បែបយ៉ាងចាប់តាំងពីឆ្នាំ១៩៦០ មកម្ល៉េះ ។ ព្រមជាមួយនេះ យើងខ្ញុំក៏ឃើញច្បាស់ថា គឺបក្សកុម្មុយនីស្តកម្ពុជានេះហើយ ដែលដឹកនាំប្រជាជនកម្មករ-កសិករក្រីក្រ និងពលករផ្សេងៗទៀត ធ្វើបដិវត្តន៍វាយកម្ទេចចក្រពត្តិអាមេរិក-បរិវារ ពួកអាក្បត់ជាតិ ពួកវណ្ណៈជិះជាន់គ្រប់ប្រភេទ រំដោះទឹកដី រំដោះប្រជាជន និងរំដោះវណ្ណៈក្រីក្រឲ្យរួចចាកផុតពីទុក្ខវេទនា និងការជិះជាន់មើលងាយមើលថោកសព្វបែបយ៉ាងទាំងអស់ និងឲ្យចេញផុតពីភាពល្ងីតល្ងង់ខ្លៅរាប់ពាន់ឆ្នាំមកហើយនោះទៀតផង ។

ក្នុងពេលសង្គ្រាមបដិវត្តន៍ជាង៥ឆ្នាំកន្លងទៅ ប្រជាជនក្រីក្រ ក្រោមការដឹកនាំរបស់បក្ស ទទួលបានជ័យជម្នះត្រចេះត្រចង់ជាបន្តបន្ទាប់ ដូចជាជ័យជម្នះក្នុងការវាយបំបាក់ឈ្លានពាននៃកងទ័ពអាមេរិក និងកងទ័ពអាធិរាជព្រៃនគរវាល់សែននាក់នៅខែឧសភា ឆ្នាំ១៩៧០ ការវាយបំបាក់ប្រតិបត្តិការចិន្លាទី២ នៅចុងឆ្នាំ១៩៧១ ការវាយបំបាក់សង្គ្រាមអាកាសរបស់ចក្រពត្តិអាមេរិក ឲ្យបរាជ័យយ៉ាងអាម៉ាស់នៅឆ្នាំ១៩៧៣ ។ល។ មហាជ័យជម្នះមានលក្ខណៈជាប្រវត្តិសាស្ត្រទាំងអស់នេះ គឺសុទ្ធតែបានមកពីពលិកម្មឈាមស្រស់ក្រហមច្រាល របស់កងទ័ពបដិវត្តន៍ និងរបស់ប្រជាជនក្រីក្រយើង ក្រោមការដឹកនាំរបស់បក្សទាំងអស់ ។

ចាប់តាំងពីក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥មក បក្សកុម្មុយនីស្តកម្ពុជាយើង បានដឹកនាំវីរប្រជាជន កម្មករ-កសិករ និងវីរកងទ័ពបដិវត្តន៍យើង ប្រយុទ្ធស្តារសេដ្ឋកិច្ច ដែលត្រូវខ្ទេចខ្ទាំ ដោយសារសង្គ្រាមមហាវិនាសកម្មរបស់ចក្រពត្តិអាមេរិក-បរិវារ លើកស្ទួយជីវភាពប្រជាជនយើង ឲ្យសម្បូរធូរធាជាលំដាប់ និងប្រយុទ្ធការពារកសាងប្រទេស ដោយឯករាជ្យម្ចាស់ការ ហើយសម្រេចមហាជោគជ័យដ៏មហាអស្ចារ្យទៀត ជាពិសេសមហាជោគជ័យជាប្រវត្តិសាស្ត្រ ក្នុងការកម្ទេចខ្សែខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជាយុទ្ធសាស្ត្រនៅក្នុងជួរបដិវត្តន៍យើងនៅដើមឆ្នាំ១៩៧៧នេះ ។ មហាជ័យជម្នះជាបន្តបន្ទាប់នេះ សុទ្ធតែជាមហាជ័យជម្នះមានលក្ខណៈជាប្រវត្តិសាស្ត្រទាំងអស់ ។ មហាជ័យជម្នះទាំងអស់នេះ បានធ្វើឲ្យយើងខ្ញុំរំភើបរីករាយ គោរពស្ងប់ស្ងែងនូវការវៃឈ្លាសរបស់បក្ស គោរពដឹងគុណបក្សយ៉ាងអនេក ។ តាមរយៈនេះ រឹតតែធ្វើឲ្យយើងខ្ញុំរង់ចាំការប្រកាសបក្សជាចំហ ជាផ្លូវការដោយអន្ទះអន្ទែងខ្លាំងជាងមុនទៅទៀត ។ អារម្មណ៍មួយរបស់យើងខ្ញុំ ស្ថិតនៅក្នុងសភាពរង់ចាំជានិច្ច ។

ដូច្នេះហើយ បានជានៅពេលដែលយើងខ្ញុំបានឮថា បក្សកុម្មុយនីស្តកម្ពុជាយើងត្រូវបានប្រកាសជាចំហ និងជាផ្លូវការទាំងក្នុងប្រទេស និងនៅលើឆាកអន្តរជាតិហើយ យើងខ្ញុំរំភើបរីករាយគ្មានអ្វីប្រៀបផ្ទឹមបានឡើយ ។ ការរីករាយរបស់យើងខ្ញុំនៅពេលនេះ បានរីកពេញទំហំអតិបរមាហើយ ។ យើងខ្ញុំរីករាយដោយគ្មានមន្ទិលសៅហ្មងអ្វីទាំងអស់ ។ ការរំភើបរីករាយនេះ បានផ្តល់នូវកម្លាំងប្រយុទ្ធមួយថ្មីទៀតដល់យើងខ្ញុំ ។

យើងខ្ញុំជឿជាក់ថា ការប្រកាសបក្សកុម្មុយនីស្តកម្ពុជាជាចំហ ជាផ្លូវការនៅពេលនេះ នាំឲ្យបក្សយើងកាន់តែមានឥទ្ធិពល

ថែមទៀត ទាំងនៅក្នុងប្រទេស ទាំងនៅលើសកលលោក ហើយបដិវត្តន៍យើង និងប្រជាជនកម្ពុជាយើង ក៏នឹងកាន់តែមានកិត្តិយសកេរ្តិ៍ឈ្មោះបោះសំឡេងនៅលើសកលលោកថែមទៀត ពិសេសចំពោះប្រទេសតូចតាចក្រីក្រ ដែលកំពុងធ្វើការតស៊ូបដិវត្តន៍រំដោះប្រទេសជាតិ និងរំដោះវណ្ណៈក្រីក្រ ។ យើងខ្ញុំឯកភាពទាំងស្រុងជាមួយបក្ស និងមានមោទកភាពយ៉ាងខ្ពង់ខ្ពស់បំផុត ចំពោះបក្សកុម្មុយនីស្តកម្ពុជាយើង ។ គឺត្រូវតែប្រកាសបក្សកុម្មុយនីស្តកម្ពុជាយើងជាចំហ ជាផ្លូវការនៅក្នុងប្រទេស និងក្រៅប្រទេស ។ ព្រោះបក្សយើង ជាបក្សគំរូជាបក្សវៃឈ្លាស ជាបក្សអង់អាចក្លាហានហ៊ានវាយជាមួយចក្រពត្តិអាមេរិក មេក្លោងចក្រពត្តិធំជាងគេនៅលើសកលលោក ហើយវាយឈ្នះចក្រពត្តិអាមេរិកមុនគេទៀត ។

ព្រមជាមួយនេះ យើងខ្ញុំក៏មានមោទកភាព ចំពោះខ្លួនខ្ពង់ខ្ពស់ដែរ ។ ម៉្យាងដោយមកពីយើងខ្ញុំបានចូលរួមក្នុងចលនាបដិវត្តន៍បានឆ្លងកាត់ចលនាបដិវត្តន៍ បត់បែន ស្មុគស្មាញជាក់ស្តែងជាមួយបក្ស រហូតដល់សម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យទាំងស្រុង ហើយក្នុងសភាពដែលយើងខ្ញុំស្ថិតនៅក្នុងវ័យយុវភាពទៀត ។ ម៉្យាងទៀត ដោយមកពីយើងខ្ញុំបានចូលរួមដឹងឮនូវថ្ងៃប្រវត្តិសាស្ត្រដែលបក្សកុម្មុយនីស្តកម្ពុជាយើង ប្រកាសជាចំហ ជាផ្លូវការទាំងនៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ លើសពីនេះទៅទៀត គឺដោយមកពីយើងខ្ញុំមានបក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវ និងភ្លឺស្វាងដឹកនាំជារៀងរហូតទៅ ។ ដូច្នេះអនាគតយើងខ្ញុំជាយុវជនយុវនារីកម្ពុជា ពិតជាភ្លឺស្វាងរុងរឿង ។

ទាំងអស់នេះ ជាការរំភើបរីករាយ និងជាមោទកភាពដ៏ខ្ពង់ខ្ពស់របស់យើងចំពោះបក្សកុម្មុយនីស្តកម្ពុជា និងចំពោះខ្លួនជាយុវជនយុវនារីជំនាន់នេះ ។ តែយើងខ្ញុំក៏មិនភ្លេចទេនូវគំរូវីរភាព និងគំនរសាច់ឈាម ឆ្អឹងឆ្អែង របស់វីរៈបុរស វីរៈនារី រាប់សែននាក់ ជាកម្មាភិបាល ជាយុទ្ធជន ជាប្រជាជន ដែលបានពលីទៅ ដើម្បីបុព្វហេតុបដិវត្តន៍ រំដោះជាតិ រំដោះប្រជាជន និងរំដោះវណ្ណៈក្រីក្រ ដោយគោលជំហរស្នេហាជាតិ ដ៏ឧត្តុង្គឧត្តម ស្នេហាប្រជាជនដ៏ខ្ពង់ខ្ពស់ស្នេហាវណ្ណៈក្រីក្រដ៏ជ្រាលជ្រៅ និងឧត្តុង្គឧត្តមបំផុត ។

យើងខ្ញុំប្តេជ្ញាប្រែក្លាយការរំភើបរីករាយ ក្នុងឱកាសដែលបក្សប្រកាសចេញជាចំហ ជាផ្លូវការនេះ និងការស្តាយស្រណោះអាឡោះអាល័យចំពោះយុទ្ធមិត្តដែលពលីទៅឲ្យទៅជាកម្លាំងកាយចិត្តយ៉ាងខ្លាំងក្លា ៖

◆ ប្រយុទ្ធរៀនសូត្រមាគ៌ាបក្សដើម្បីកសាងខ្លួន ឲ្យទៅជាជនកុម្មុយនីស្ត ដ៏បរិសុទ្ធ និងរឹងប៉ឹងដើម្បីបន្តវេនបដិវត្តន៍ទៅអនាគតទៀត ឲ្យកាន់តែក្រហមឆ្អិនឆ្អៅ ។

◆ ប្រយុទ្ធលះបង់គ្រប់បែបយ៉ាង ដើម្បីការពារបក្ស បដិវត្តន៍ប្រជាជន ការពារទឹកដី ការពាររដ្ឋអំណាចបដិវត្តន៍កម្មករ កសិករ និងការពារជ័យផលបដិវត្តន៍ទាំងអស់ ឲ្យនៅគង់វង្ស ស្ថិតស្ថេរជារៀងរហូត និងប្រយុទ្ធកសាងកម្ពុជាប្រជាធិបតេយ្យយើង ឲ្យរីកចម្រើនដោយសន្ទុះលោតផ្លោះលើគ្រប់វិស័យ សមស្របតាមជំនឿទុកចិត្តរបស់បក្សមកលើយើងខ្ញុំជាយុវជន យុវនារីបដិវត្តន៍ជំនាន់នេះ ។ ជាក់ស្តែង ៖

◆ យើងខ្ញុំជាយុវកម្មករ ប្តេជ្ញាវាយសម្រុករៀនសូត្រ វប្បធម៌ និងបច្ចេកទេស វិទ្យាសាស្ត្រគ្រប់បែបយ៉ាង ដើម្បីផលិតឧបករណ៍ និងសម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗ ឲ្យកាន់តែបានច្រើន និងកាន់តែមានគុណភាពខ្ពស់ រួមចំណែកកែប្រែជីវភាពប្រជាជនយើង ឲ្យកាន់តែសម្បូរធូរធា និងរួមវាយផ្តាច់បីតោន និងប្រាំមួយតោន ក្នុងឆ្នាំ១៩៧៧នេះ ឲ្យបានដាច់ខាត ។

◆ យើងខ្ញុំជាយុវកសិករសហករណ៍ ប្តេជ្ញាវាយផ្តាច់ផែនការបីតោន និងប្រាំមួយតោន នៅឆ្នាំ១៩៧៧នេះ ឲ្យបានដាច់ខាត ។

◆ យើងខ្ញុំជាយុទ្ធជន-យុទ្ធនារីកងទ័ពបដិវត្តន៍ ប្តេជ្ញាការពារព្រំដែន គោក ទឹក សមុទ្រ កោះ ឲ្យបានដាច់ខាត ។

◆ យើងខ្ញុំជាយុទ្ធជន-យុទ្ធនារីនៅតាមមន្ទីរ ក្រសួងនានា ប្តេជ្ញាវាយសម្រុកបំពេញភារកិច្ចស្នូលរបស់ខ្លួន គ្រប់មុខព្រួញ ឲ្យបានសម្រេចតាមផែនការកំណត់ និងឲ្យលើសផែនការថែមទៀតដាច់ខាត ។

យើងខ្ញុំទាំងអស់គ្នា ប្តេជ្ញាការពារបក្ស ដើរតាមបក្ស ជឿជាក់លើបក្ស និងស្មោះត្រង់ចំពោះបក្ស វណ្ណៈ និងប្រជាជនរហូតអស់មួយជីវិត និងប្តេជ្ញាកសាងកម្ពុជាប្រជាធិបតេយ្យឲ្យទៅជាប្រទេសកសិកម្មសម័យ និងឧស្សាហកម្មយ៉ាងឆាប់រហ័សដាច់ខាត ។

**ឆេង ម៉េង**

# បានជួបត្រឹមសាកសព

ឆាយ ប៉ោយ មានស្រុកកំណើតនៅស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលមានឪពុកម្តាយជាកសិករ និងមានបងប្អូនប្រុស ៦នាក់ ។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ឆ្នាំ១៩៧០ បងប្អូនប្រុសបីនាក់របស់គាត់ បានចូលរួមចលនាតស៊ូបដិវត្តន៍ជាមួយខ្មែរក្រហម ។ ដោយឡែក ប៉ោយ មិនបានចូលរួមជាមួយបងប្អូនគាត់ទេ ដោយនៅជួយធ្វើស្រែចម្ការជាមួយឪពុកម្តាយ ។


រូបភាពពីឆ្វេង ៖ ឆាយ ប៉ោយ ផ្តល់បទសម្ភាសន៍ទាក់ទងរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ ទារ៉ា សារៈមុន្នីនុ បុគ្គលិកទស្សនាវដ្តីស្វែងរកការពិត ។

ក្រោយជ័យជម្នះ១៧ មេសា ឆ្នាំ១៩៧៥ របស់ខ្មែរក្រហម ទោះបីជាគ្រួសាររបស់ ប៉ោយ មានបងប្អូនធ្វើជាយោធាខ្មែរក្រហមក៏ដោយ ក៏សមាជិកគ្រួសារគាត់ទាំងអស់គ្នាត្រូវបានអង្គការចាត់តាំងឲ្យធ្វើការងារដូចប្រជាជនជម្លៀសដទៃទៀតដែរ ។ បងប្អូនរបស់ ប៉ោយ ដែលស្ម័គ្រចូលរួមជាមួយខ្មែរក្រហមក៏មិនដែលបានមកជួបគ្នាដែរ បន្ទាប់ពីប្រទេសត្រូវបានរំដោះហើយ ។ ប៉ោយ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើការនៅកងភ្ជួរ ដែលមានសមាជិកទាំងប្រុសទាំងស្រីចំនួន៧០នាក់ ។ ក្រៅពីការងារភ្ជួរ ប៉ោយ ក៏មាននាទីបោចស្មៅ ធ្វើនង្គ័ល ស្ទូងស្រូវ និងច្រូតទៀតផង ។ ប៉ោយ បានឲ្យដឹងថា សមាជិកក្រុម៧០នាក់នេះ គឺទទួលបានរបបអង្ករតែប្រាំកំប៉ុងប៉ុណ្ណោះ សម្រាប់បបរចែកគ្នាក្នុងមួយពេល ។ គ្មាននរណាម្នាក់បរិភោគគ្រប់គ្រាន់ឡើយ ហើយក៏គ្មាននរណាម្នាក់ហ៊ានជំទាស់តវ៉ាដែរ ។ អំឡុងឆ្នាំ១៩៧៧-៧៨ សមាជិកក្នុងក្រុមរបស់គាត់ ត្រូវបានអង្គការចាប់យកទៅជាបន្តបន្ទាប់ ។ ភាគច្រើនអ្នកទាំងនោះត្រូវបានអង្គការមើលឃើញថា ជាអ្នកដែលមានគំនិតប្រឆាំងនឹងអង្គការ តវ៉ា ឬ ស្ពឹកស្រពន់ក្នុងការងារ ។ អ្នកដែលមិនធ្វើការគ្រប់ផែនការដែលអង្គការដាក់ឲ្យម្តងពីរដងនោះ អង្គការនឹងចាប់យកទៅដូចគ្នា ហើយអ្នកខ្លះទៀតត្រូវបានអង្គការភូតកុហកថា ស្នើឲ្យទៅជួយការងារនៅសហករណ៍ផ្សេង ។ ប៉ោយ បានឲ្យដឹងថា ចាប់តាំងពីពេលនោះមក អ្នកទាំងនោះមិនដែលបានឃើញត្រឡប់មកវិញទេ ។ នៅអំឡុងឆ្នាំ១៩៧៨ដដែលនេះ ប៉ោយ នៅចាំបានថា ការកាប់សម្លាប់ធ្វើឡើងជារៀងរាល់ថ្ងៃ មិនថាប្រជាជន ឬកម្មាភិបាលរបស់អង្គការឡើយ ។ ម្នាក់ៗរស់នៅដោយភាពភ័យខ្លាច និងមិនទុកចិត្តគ្នា ហើយតែងតែយកការណ៍ ឬស៊ើបការណ៍ពីគ្នាទៅវិញទៅមក ដើម្បីរាយការណ៍ជូនអង្គការជាថ្នូរនឹងភាពស្មោះត្រង់ និងទទួលការទុកចិត្តពីអង្គការដើម្បីរក្សាជីវិត ។

ព្រឹត្តិការណ៍មួយដែល ប៉ោយ ចាំមិនភ្លេចនៅក្នុងជីវិតរបស់គាត់ គឺការស្លាប់បងប្រុសរបស់គាត់ ដែលបានបែកពីគ្រួសារចាប់តាំងពីចូលរួមចលនាតស៊ូបដិវត្តន៍ជាមួយខ្មែរក្រហម ។ គាត់បានរម្លឹកពីហេតុការណ៍នោះថា អំឡុងចុងឆ្នាំ១៩៧៨ ការកាប់សម្លាប់ប្រជាជនកើនឡើងយ៉ាងខ្លាំង នរណាម្នាក់ដែលអង្គការសង្ស័យថាជាខ្មាំង គឺត្រូវតែកម្ទេចតែម្តង ។ អំឡុងពេលនោះសង្គ្រាមរវាងខ្មែរក្រហម និងវៀតណាមក៏ខ្លាំងណាស់ដែរ ។ នៅតាមបណ្តាភូមិនីមួយៗ មនុស្សស្លាប់ស្ទើរតែជីករណ្តៅកប់មិនទាន់ ហើយក្នុងភូមិរបស់ ប៉ោយ ដោយមានមនុស្សស្លាប់ច្រើនពេក អង្គការក៏ដកគាត់ពីកងភ្ជួរឲ្យមកជួយកប់សាកសព ។ អំឡុងពេលកប់សាកសពទាំងនោះ មានម្នាក់ដែលគាត់ចំណាំយ៉ាងច្បាស់នោះ គឺសាកសពបងប្រុសរបស់គាត់ ។ បងប្រុសរបស់គាត់ជាយោធានៅភូមិភាគបូព៌ា ដែលឈរជើងនៅខេត្តស្វាយរៀង ។ អ្នកដែលចូលរួមកប់សាក

សពជាមួយ ប៉ោយ បានប្រាប់គាត់ថា សាកសពយុទ្ធជនទាំងនេះ ជាយោធាដែលរត់មកពីខាងបូព៌ា ។ អ្នកកប់សពនោះ មិនដឹងថា ក្នុងចំណោមសាកសពទាំងនេះ មានម្នាក់ជាសពបងប្រុសរបស់ ប៉ោយ ទេ ។ គាត់បានប្រាប់ទៀតថា អំឡុងពេលដែលកងទ័ពខាងបូព៌ា កំពុងវាយប្រយុទ្ធជាមួយនឹងវៀតណាម យុទ្ធជនមួយចំនួនបានរត់គេចពីការប្រយុទ្ធមកកាន់ស្រុកកំណើត ហេតុនេះ អង្គការចាត់ទុកទង្វើនេះថា គឺជាការរត់ចោលជួរ ដូច្នេះអង្គការក៏កម្ទេចតែម្តង ពេលដែលអ្នកទាំងនោះមកដល់ស្រុកកំណើតភ្លាម ។ ប៉ោយ កាយដីកប់សាកសពបងប្រុសជាមួយនឹងអារម្មណ៍ក្តុកក្តួលយ៉ាងខ្លាំង និងប្រឹងទប់ចិត្តកុំឲ្យមានប្រតិកម្មអ្វីចេញមកក្រៅ ព្រោះខ្លាចអង្គការចាត់ថ្នាក់បាននឹងមានរឿងដល់ខ្លួន និងគ្រួសារ ។ គាត់និងគ្រួសារបានបែកពីបងប្រុស ប្រហែល៨ឆ្នាំ ហើយនៅទីបំផុត គាត់បានជួបត្រឹមសាកសពបងប្រុសជាមួយនឹងអាម្មណ៍ឈឺចាប់ ។ គាត់បាននាំយកដំណឹងដ៏ក្រៀមក្រំនេះ មកប្រាប់ដល់គ្រួសារ ហើយម្នាក់ៗបានត្រឹមតែយំ និងសោកស្តាយប៉ុណ្ណោះ ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ សមាជិកគ្រួសាររបស់គាត់នៅសល់តែ៦នាក់ប៉ុណ្ណោះ ក្នុងនោះស្លាប់បងប្រុសគាត់ម្នាក់ ដោយអង្គការកម្ទេច និងឪពុកគាត់ស្លាប់ដោយជំងឺគ្មានថ្នាំព្យាបាល ។ ក្នុងឆ្នាំដដែល ប៉ោយ ជាមួយនឹងប្រពន្ធ បានផ្លាស់មករស់នៅភ្នំពេញ និងចាប់ផ្តើមជីវិតជាថ្មី ដោយប្រកបរបរធ្វើស្រែចម្ការ និងជាងផ្ទះនៅខណ្ឌដង្កោ រហូតមកដល់សព្វថ្ងៃ ។

សម្រាប់ ប៉ោយ ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ទៅកាន់ក្មេងជំនាន់ក្រោយ គឺពិតជាមានសារសំខាន់ណាស់ ព្រោះគាត់ចង់ឲ្យកូនៗ ក៏ដូចជាក្មេងជំនាន់ក្រោយ ធ្វើការសិក្សាស្វែងយល់ឲ្យកាន់តែច្បាស់ពីឫសគល់ដែលធ្វើឲ្យកើតមានរបបខ្មែរក្រហម ក៏ដូចជាការកាប់សម្លាប់ជាតិសាសន៍ឯងនេះឡើង ។

**ធាវ សារៈមុនិន្ទ**

# ដំណឹងស្វែងរកពូ និងមីង



នាងខ្ញុំឈ្មោះ កប ដាវី ជាកូនរបស់លោកឪពុកឈ្មោះ ពៅ កប ។ ឪពុកខ្ញុំកើតនៅឆ្នាំ១៩៣០ នៅភូមិសូសិតក្រោម ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត ។ គាត់មានឪពុកឈ្មោះ ពៅ កាន់ និងម្តាយឈ្មោះ អ៊ុំ ឆិន ។

ឪពុកខ្ញុំ ពៅ កប បានចូលរួមក្នុងចលនាខ្មែរឥស្សរៈនៅជំនាន់អាណានិគមនិយមបារាំង ។ ក្រោយមក គាត់បានទៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

នៅឆ្នាំ១៩៥៤ គាត់បានរៀបការជាមួយប្រពន្ធជនជាតិវៀតណាម និងមានកូនស្រីពីរនាក់ ។ នៅឆ្នាំ១៩៧០ គាត់បានចូលមកកម្ពុជាវិញ ដើម្បីវាយប្រឆាំងនឹងអាមេរិក ហើយក្រោយមកទៀត ខ្ញុំគ្រាន់តែដឹងថា គាត់ត្រូវបានខ្មែរក្រហមសម្លាប់ ។

ជាចុងក្រោយ ខ្ញុំគ្រាន់តែដឹងថា ឪពុករបស់ខ្ញុំមានប្អូនប្រុសឈ្មោះ ពៅ ហ៊ុន និងប្អូនស្រីឈ្មោះ ពៅ ហ៊ិម ។ សព្វថ្ងៃ ខ្ញុំនៅតែចង់ជួប និងសង្ឃឹមថា ពូមីង នឹងបានឃើញខ្ញុំ ហើយអាចមករកខ្ញុំ (ក្មួយ) នៅមន្ទីរពេទ្យធំ (ព្រះកេតុមាលា) ព្រោះសព្វថ្ងៃខ្ញុំជាគ្រូពេទ្យមធ្យមនៅមន្ទីរពេទ្យនេះ ។ **ពីក្មួយ កប ដាវី**

# ស្ម័គ្រចិត្តនៅសមរភូមិប្រសើរជាងឱ្យអង្គការសម្លាប់

កោះគ្នោត គឺជាកោះមួយក្នុងចំណោមកោះជាច្រើនតាមបណ្តោយដងទន្លេមេគង្គ ដែលស្ថិតក្នុងស្រុកសម្បូរ ខេត្តក្រចេះ ។ យើងអាចធ្វើដំណើរទៅកោះមួយនេះ តាមរយៈទូកដរ ឬទូកតូចល្បឿនលឿន ដែលអ្នកស្រុកនៅទីនោះហៅថា “អាអេវ” ដោយចំណាយពេលជាង៤០នាទី ។ ប្រជាជនដែលរស់នៅកោះគ្នោតនេះ ភាគច្រើនប្រកបរបរធ្វើស្រែចម្ការ និងនេសាទ ។ កន្លងមកមានអង្គការមួយចំនួនបានចុះមកបង្រៀនអ្នកភូមិអំពីរបៀបធ្វើកសិកម្ម ចិញ្ចឹមសត្វ ក៏ដូចជាបង្កើតឲ្យមានផ្ទះសហគមន៍សម្រាប់ភ្ញៀវទេសចរណ៍ស្នាក់នៅ ដែលធ្វើឲ្យប្រជាជនអាចរកចំណូលបន្ថែមសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ។

តាមអ្វីដែលអ៊ំប្រុស ចាន់ ពៅ បានរៀបរាប់ អ្នកភូមិរស់នៅកោះគ្នោតភាគច្រើនជាជនជាតិភាគតិចកួយ និងអ្នកស្រុកដែលភៀសខ្លួនមករស់នៅក្រោយរបបខ្មែរក្រហមបានដួលរលំ ។ អង្គុយជជែកគ្នាលេងនៅមាត់ទ្វារផ្ទះ ដែលបែរមុខទៅទន្លេមេគង្គ ជាមួយនឹងខ្យល់ត្រជាក់ និងមានម្លប់ស្វាយ និងម្លប់ក្រូចថ្លុងត្រឈឹងត្រឈៃ ពៅ បានរៀបរាប់ពីប្រវត្តិផ្ទាល់ខ្លួនខ្លះៗប្រាប់ខ្ញុំថា គាត់ជាអ្នកដែលមានស្រុកកំណើតនៅភូមិកោះទ្រង់ ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ ប៉ុន្តែឪពុកម្តាយរបស់គាត់ជាអ្នកខេត្តស្វាយរៀងដែលផ្លាស់មករស់នៅកោះទ្រង់ តាំងពីសម័យបារាំង ។ គាត់ជាកូនទីពីរក្នុងចំណោមបងប្អូនប្រុសបីនាក់ ។ បងប្រុសរបស់គាត់បានស្លាប់ក្នុងរបបខ្មែរក្រហម និងប្អូនប្រុសទីបីបានបែកគ្នាអំឡុងឆ្នាំ១៩៧០ ពេលដែលប្អូនគាត់ទៅរៀននៅភ្នំពេញ ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក ។ បន្ទាប់ពីឪពុកម្តាយរបស់គាត់បានស្លាប់ទៅ ពៅ បានឈប់ រៀនត្រឹមថ្នាក់ទី៧ ហើយក៏មកស៊ីឈ្នួលធ្វើអួនឲ្យថៅកៃវៀតណាម ។ រយៈពេលជាងមួយឆ្នាំក្រោយមក ពៅ បានត្រឡប់មកភូមិកោះទ្រង់វិញ និងបានបួសជាសង្ឃដើម្បីបន្តការសិក្សា ។ រៀនសាលាបាលីបានមួយឆ្នាំ ពៅ ក៏ឡើងមកខេត្តក្រចេះ ដើម្បីរៀនបំពេញវិជ្ជា និងបានទៅបង្រៀននៅកោះដំបងរយៈពេលប្រមាណប្រាំបីខែ ។ ពៅ បានរៀបការនៅកោះដំបង ក្នុងឆ្នាំ១៩៧០ មុនរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ។



ចាន់ ពៅ និងចៅប្រុស នៅផ្ទះរបស់គាត់ស្ថិតនៅឃុំកំពង់ចាម ស្រុកសម្បូរណ៍ ខេត្តក្រចេះ ។

ក្រោយរដ្ឋប្រហារបានបីខែ នៅអំឡុងខែមិថុនា ឃុំបឹងចារទាំងមូលត្រូវបានខ្មែរក្រហមគ្រប់គ្រង ។ ពៅ ត្រូវបានខ្មែរក្រហមចាត់ឲ្យដើរបង្រៀនអក្សរក្មេងៗតាមភូមិ ។ ពៅ បានឲ្យដឹងថា ខ្មែរក្រហមពេលនោះ បានបែងចែកឲ្យប្រជាជនធ្វើការងារដូចជា ធ្វើស្រែចម្ការ ឬធ្វើដីលេខមួយ ហើយក្មេងៗពេលថ្ងៃត្រូវដើររើសអាចម៍គោ កាប់ទន្រ្ទានខែត្រ ដើម្បីធ្វើជី និងពេលយប់ត្រូវទៅរៀនអក្សរមួយម៉ោង មុននឹងសម្រាក ។ ពៅ បានឲ្យដឹងថា ទោះបីជាខ្មែរក្រហមចាត់គាត់ឲ្យធ្វើជាគ្រូបង្រៀន ប៉ុន្តែគាត់តែងតែប្រុងប្រយ័ត្នជានិច្ច ចំពោះសកម្មភាពរបស់ខ្លួន ។ ជារឿយៗ ខ្មែរក្រហមតែងតែនិយាយលេងសើចជាមួយគាត់ថា "ប្រយ័ត្នវើយ អាអនុធនសិស្ស អាអនុធនសង្ឃ" ។ ពៅ បង្រៀនសិស្សរហូតដល់ឆ្នាំ ១៩៧៧ ហើយអ្នកដែលគាត់បង្រៀនភាគច្រើនជាកូនកម្មាភិបាលខ្មែរក្រហមតែម្តង ។ ក្រៅពីការងារបង្រៀន ពៅ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើបញ្ជីឈ្មោះ ឬស្ថិតិតាមភូមិ ។ ចំពោះការងារដកស្ទូងភ្ជួររាស់ ពៅ មិនសូវបានធ្វើនោះទេ ។ នៅអំឡុងឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមខាងនិរតី បានមកគ្រប់គ្រងតំបន់របស់ ពៅ រស់នៅ ។ កម្មាភិបាលមូលដ្ឋានមួយចំនួនត្រូវបានផ្លាស់ប្តូរ និងហៅយកទៅបាត់ៗ មិនដែលឃើញត្រឡប់មកវិញទេ ។ ពៅ បានឲ្យដឹងថា កម្មាភិបាលដែលមកពីខាងនិរតីទាំងនោះ មានចរិតកាចសាហាវណាស់ ។ ស្របពេលនោះ ការប្រយុទ្ធគ្នាជាមួយវៀតណាមក៏កើតមានឡើងជាបន្តបន្ទាប់ដែរ ។ កម្មាភិបាលមូលដ្ឋានដែលស្រឡាញ់រាប់អាន ពៅ បានលួចប្រាប់គាត់ថា បើសិនជាអាច ចូរគាត់កុំនៅភូមិអី គួរតែផ្លាស់ទៅកន្លែងផ្សេង ឬទៅមុខ (សមរភូមិ) ដើម្បីរក្សាជីវិត ព្រោះមិនយូរប៉ុន្មានអង្គការនឹងកម្ទេចមិនខាន ។ ស្របពេលនោះ អង្គការបានចាប់ផ្តើមកេណ្ឌយុវជន យុវនារី ក្នុងភូមិទាំងអស់ទៅច្បាំងជាមួយវៀតណាមនៅសមរភូមិ ។

ក្រោយពីស្តាប់តាមការណែនាំទាំងនេះ ពៅ គិតក្នុងចិត្តថា បើនៅភូមិទៀត ប្រាកដជាអង្គការយកទៅកម្ទេចទាំងគ្រួសារមិនខាន ហេតុនេះ គាត់ក៏សម្រេចចិត្តស្ម័គ្រចិត្តចូលធ្វើយោធាដើម្បីប្រយុទ្ធជាមួយនឹងវៀតណាម ធ្វើយ៉ាងនេះដើម្បីឲ្យអង្គការមើលឃើញថា គាត់ស្មោះត្រង់ និងហ៊ានលះបង់ដើម្បីអង្គការ ។ ហេតុផលមួយទៀត គឺ ពៅ គិតថា បើនៅភូមិច្បាស់ណាស់ គាត់ប្រាកដជាស្លាប់ តែបើគាត់ទៅប្រយុទ្ធនៅសមរភូមិ គាត់អាចមានផ្លូវពីរ គឺ រួចរស់ជីវិត និងស្លាប់ ។ ពៅ គិតក្នុងចិត្តថា សុខចិត្តឲ្យត្រូវគ្រាប់នៅសមរភូមិស្លាប់ ប្រសើរជាងគេចាប់យកទៅវាយចោល ។ ទោះបីជាយ៉ាងណាអំឡុងពេលដែលគាត់ចាកចេញពីភូមិទៅសមរភូមិនោះ កូនៗរបស់គាត់ពីរនាក់បានស្លាប់ ដោយសារជំងឺគ្មានថ្នាំព្យាបាល ។ រឿងដ៏គួរឲ្យសោកស្តាយមួយនេះ គាត់បានដឹងបន្ទាប់ពីគាត់បានមកជួបជុំគ្រួសារវិញ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ។ ពៅ បានទៅនៅសមរភូមិជិតមួយឆ្នាំ ប៉ុន្តែគាត់មិនមែននៅខាងទ័ពស្រួចនោះទេ ។ ដោយសារវ័យរបស់គាត់ជាង៣០ឆ្នាំនៅ ពេលនោះដូចនេះ ពៅ ត្រូវអង្គការចាត់តាំងឲ្យធ្វើការខាងដឹកជញ្ជូនស្បៀង និងសែងអ្នករបួស ។

ក្រោយរបបខ្មែរក្រហមបានដួលរលំ ពៅ និងគ្រួសារ បានផ្លាស់ពីឃុំបឹងចារ មករស់នៅស្រុកសម្បូរណ៍រយៈពេលប្រមាណ៦ខែ ហើយក៏បានផ្លាស់មករស់នៅកោះត្នោតនេះរហូតដល់បច្ចុប្បន្ន ។ ពៅ បានរម្លឹកពីទិដ្ឋភាពរួមនៅកោះត្នោតនេះថា កោះត្នោតនេះមានបីភូមិ គឺភូមិកោះដំបង ភូមិកំពង់រទេះ និង ភូមិតាំរ៉ែ ហើយប្រជាជនដែលមករស់នៅលើកោះត្នោតនេះ ភាគច្រើនសុទ្ធតែជាអ្នកចំណាកស្រុកដែលភៀសខ្លួនចេញពីតំបន់ប្រទាញប្រទង់នៅខាងលើខេត្តក្រចេះ រវាងកងទ័ពរដ្ឋាភិបាល និងកងទ័ពខ្មែរក្រហម ហើយភាគច្រើនអ្នកទាំងនោះជាជនជាតិភាគតិចគួយ ។ ប៉ុន្តែ មកដល់បច្ចុប្បន្ន បងប្អូនជនជាតិភាគិតិចគួយទាំងនេះ ក្រៅពីចាស់ៗ ក្មេងៗជំនាន់ក្រោយមិនចេះនិយាយភាសាគួយនោះទេ ។ អ្នកទាំងនោះនិយាយតែភាសាខ្មែរ ដោយគ្រាន់តែដឹងថាខ្លួនមានដើមកំណើតជាជនជាតិភាគតិចគួយប៉ុណ្ណោះ ។

បច្ចុប្បន្ន អ្វីដែលគួរឲ្យសោកស្តាយសម្រាប់ ពៅ និងអ្នកភូមិ គឺធនធានត្រី ។ គាត់បានឲ្យដឹងថា ត្រីមិនសូវសម្បូរដូចកាលពីមុនទេ ព្រោះតែមានការនេសាទ និងប្រើប្រាស់ឧបករណ៍ឆក់ និងអួនអូសខុសច្បាប់ពីសំណាក់ឈ្មួញទុច្ចរិត ។ ពៅ រម្លឹកថា ពីមុនត្រីសម្បូរណាស់ ហើយក្នុងមួយយប់ យើងអាចរកបានរាប់រយគីឡូ ប៉ុន្តែសព្វថ្ងៃ គាត់មិនអាចរកបានដូចមុនឡើយ ជាពិសេស នៅរដូវបិទនេសាទដែលជារដូវត្រីពង ក៏នៅតែមានការលួចនេសាទដដែល ដែលជាហេតុធ្វើឲ្យត្រីមួយចំនួនស្ទើរតែផុតពូជ ។

**ផាន់ សារៈមុនិន្ទ**

# ការសិក្សាអំពីរបបខ្មែរក្រហមធ្វើឱ្យយើងស្គាល់ពីទុក្ខលំបាករបស់ឪពុកម្ដាយ

មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាថ្នាក់រៀនស្ដីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យព្រែកថ្មី ដែលមានសិស្សានុសិស្សថ្នាក់ទី១២ ចំនួន ៩១នាក់ បានចូលរួម ។ កម្មវិធីនេះ រៀបចំឡើងក្រោមកិច្ចសហការជាមួយក្រសួង អប់រំ យុវជន និងកីឡា ព្រមទាំងទទួលបានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ *(USAID)* ។ វេទិកាថ្នាក់រៀននេះ រួមបញ្ចូលសកម្មភាពចំនួនបួនគឺ ការធ្វើបទបង្ហាញខ្លីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ វិធីសាស្ត្រនៃការធ្វើសម្ភាសន៍ ការបញ្ចាំងខ្សែភាពយន្តឯកសារ និងការទស្សនាពិព័រណ៍ស្ដីអំពីការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម ។

បើតាមប្រសាសន៍របស់លោកនាយកវិទ្យាល័យព្រែកថ្មី ង៉ួន ទេង កាលពីដំបូងឡើយ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតសាលាមធ្យមសិក្សាកម្រិត១ នៅភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដោយខ្ចីអគារសាលាបឋមសិក្សាកោះក្របី ដែលមាន៦ថ្នាក់ និងមានសិស្សសរុប ៣៣៧នាក់ (ស្រី ២០៩នាក់) មកពីឃុំព្រែកថ្មី ឃុំឈើទាល និងឃុំកំពង់ស្វាយ ។ នៅពេលនោះមានគ្រូបង្រៀន ៩នាក់ (ស្រី១នាក់) ដែលស្ថិតក្រោមការគ្រប់គ្រងរបស់លោកនាយក ឯម កួន និងនាយករង លី សំអឿន ។ នៅឆ្នាំ១៩៨៥ ប្រជាជនបានកសាងអគារសិក្សាមួយខ្នងអំពីឈើ ប្រក់ក្បឿង ដែលមាន៣បន្ទប់ នៅក្រោយវត្តកោះក្របី ព្រមទាំងបានទទួលសិស្សមកពីសាលាបឋមសិក្សាបានមួយចំនួន ។


ក្រុមការងារគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថតរូបជាមួយសិស្សានុសិស្សវិទ្យាល័យព្រែកថ្មី ក្រោយចប់កម្មវិធីបណ្ដុះបណ្ដាលស្ដីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ - ១៩៧៩) ។



សិស្សានុសិស្សវិទ្យាល័យព្រែកថ្មី កំពុងស្តាប់អ្នកនាង សិរិ សាវីណា ប្រធានក្រុមការងារអប់រំនិងផ្សាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើបទបង្ហាញពិព័រណ៍ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ ក្នុងរបបខ្មែរក្រហម ។

នៅឆ្នាំ១៩៩០ ប្រជាជនបានកសាងអគារមួយខ្នងទៀតទន្ទឹមនឹងអគារឈើ ធ្វើអំពីឥដ្ឋ ដែលមាន៣បន្ទប់ ដោយសម្រេចបាន៦០% ព្រមទាំងបានប្រែឈ្មោះជាអនុវិទ្យាល័យព្រែកថ្មី ។ នៅឆ្នាំ១៩៩២ សម្តេចព្រះ នរោត្តម រណឫទ្ធិ បានកសាងបង្ហើយអគារថ្មដែលមាន៣បន្ទប់ និងរួចរាល់ជាស្ថាពរនៅឆ្នាំ១៩៩៣ ។ ទន្ទឹមនឹងនោះដែរ លោក ឃុន ឈាង និងលោក ឃុន វុធ បានចូលរួមកសាងអគារមួយខ្នងទៀតអំពីថ្មប្រក់ក្បឿងដែលមាន៤បន្ទប់ ។ នៅឆ្នាំ១៩៩៣ សម្តេចក្រុមព្រះបានយាងសម្ពោធ និងបានប្រសិទ្ធិនាមថា អនុវិទ្យាល័យ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រែកថ្មី ។ នៅឆ្នាំ១៩៩៨ សម្តេចក្រុមព្រះបានកសាងអគារមួយខ្នងទៀតអំពីថ្មប្រក់ក្បឿងដែលមាន១០បន្ទប់ ។ នៅឆ្នាំ២០០៥ ក្លិបរ៉ូធីរ៉ាក់ភ្នំពេញសហការជាមួយក្លិបរ៉ូធីរ៉ាក់សឹង្ហបូរី បានកសាងអគារបណ្ណាល័យ១ខ្នងអំពីឥដ្ឋប្រក់សង្កសី ព្រមទាំងបំពាក់កុំព្យូទ័រចំនួន៥គ្រឿង ។ នៅឆ្នាំ ២០១២ អនុវិទ្យាល័យនេះត្រូវបានប្តូរទៅជាវិទ្យាល័យព្រែកថ្មី ។ សម្រាប់ឆ្នាំសិក្សា ២០១៦-២០១៧ វិទ្យាល័យព្រែកថ្មី មានសិស្សសរុបចំនួន៥៩៨នាក់ (ស្រី២៧១) បុគ្គលិក និងគ្រូបង្រៀនចំនួន ៦៤នាក់ (ស្រី២៨នាក់) ។

មុននឹងផ្តើមនៃវេទិកាថ្នាក់រៀននេះ លោកនាយកវិទ្យាល័យ ងួន ទេង បានសម្តែងកិច្ចស្វាគមន៍ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចុះមកធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់សិស្សានុសិស្ស ។ លោកបានបន្ថែមថា ការសិក្សាអំពីរបប៣ឆ្នាំ៨ខែ និង២០ថ្ងៃមានសារសំខាន់ដែលសិស្សានុសិស្សត្រូវយល់ដឹងដោយសារតែរបបខ្មែរប្រហម មិនមែនជារឿងដែលត្រូវបានគាត់តែងឡើងនោះទេ ប៉ុន្តែគឺជារឿងពិត ។ លោកនាយកបានរំឭកថា កាលពីពេលកន្លងមកសិស្សានុសិស្សធ្លាប់បានទៅទស្សនាបូជនីយដ្ឋានតម្កល់អដ្ឋិធាតុអ្នកដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនៅវត្តចំពុះ ក្អែក ។ ហេតុដូច្នេះ លោកនាយកបានសំណូមពរសិស្សានុសិស្សដែលចូលរួមវេទិកាថ្នាក់រៀនថ្ងៃនេះ ត្រងត្រាប់ស្តាប់ និងកត់ត្រាទុក ព្រមទាំងលើកទឹកចិត្តឲ្យសិស្សានុសិស្សសួរសំណួរទៅកាន់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានូវចម្ងល់ទាំងឡាយដែលទាក់ទងនឹងរបបខ្មែរក្រហម ។

បន្ទាប់មក លោក ផេង ពង្សរ៉ាស៊ី ប្រធានក្រុមគម្រោងអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចែកក្រដាសស្ទាបស្ទង់មតិដើម្បីវាស់កម្រិតនៃការយល់ដឹងរបស់សិស្សានុសិស្សអំពីរបបខ្មែរក្រហម មុននឹងលោកចាប់ផ្តើមធ្វើបទបង្ហាញ ដោយសង្ខេបអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ មិនតែប៉ុណ្ណោះ លោកបានស្នើឲ្យសិស្សសរសេរអំពីអ្វីដែលខ្លួនបានដឹងអំពីរបបខ្មែរក្រហម និងអ្វីដែលខ្លួនចង់ដឹងបន្ថែមអំពីរបបខ្មែរក្រហម ។ សិស្សភាគច្រើនបានទទួលស្គាល់ថារបបខ្មែរក្រហមជារបបឃោរឃៅមួយ ដែលបានធ្វើទារុណកម្មប្រជាជន បង្ខំឲ្យប្រជាជនធ្វើការងារធ្ងន់ បង្អត់អាហារប្រជាជនបំបែកបំបាក់គ្រួសារ សម្លាប់អ្នកចេះដឹង និងប្រជាជនស្លូតត្រង់ លុបបំបាត់ការប្រណិប័តន៍សាសនា និងព្រមទាំងជម្លៀសប្រជាជនពីតំបន់មួយទៅតំបន់មួយទៀត ។ ចំណែកឯអ្វីដែលសិស្សចង់ដឹងបន្ថែមអំពីរបបខ្មែរក្រហម គឺតើរបបខ្មែរក្រហមកើតឡើងដោយ

របៀបណា? នរណាខ្លះជាមេដឹកនាំខ្មែរក្រហម? ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជន? ហេតុអ្វីបានជាខ្មែរក្រហមជម្លៀសប្រជាជន? តើវត្តអារាម និងសាលារៀនត្រូវបានប្រើប្រាស់សម្រាប់ធ្វើអ្វី? តើប្រជាជនធ្វើការមួយថ្ងៃប៉ុន្មានម៉ោង និងទទួលបានរបបអាហារចំនួនប៉ុន្មាន? សិស្សានុសិស្សហាក់ដូចជាចង់ចេះដឹងអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដោយបានចោទជាសំណួរជាច្រើន ។

បន្ទាប់ពីការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ ខ្សែភាពយន្តឯកសារខ្លីមួយស្តីអំពីគុកទួលស្លែង ដែលបានថតនៅឆ្នាំ១៩៧៩ ត្រូវបានចាក់បញ្ចាំងឲ្យសិស្សទស្សនាស្វែងយល់អំពីគុករបស់ខ្មែរក្រហម ។ លោក ផេង ពង្សរ៉ាស៊ី បានពន្យល់ប្រាប់សិស្សានុសិស្សថា ខ្សែភាពយន្តឯកសារនេះត្រូវបានថតនៅដើមឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពរំដោះ បានចូលមកដល់ទីក្រុងភ្នំពេញ ។

ជាកិច្ចបន្តនៃកម្មវិធីព្រឹកនេះ លោក ឡុង ដានី ប្រធានក្រុមគម្រោងការជំរុញឲ្យមានការទទួលខុសត្រូវ បានពន្យល់សិស្សានុសិស្សអំពីវិធីសាស្ត្រសម្ភាសន៍ ។ មុននឹងលោកចាប់ផ្តើម លោកបានសាកសួរទៅសិស្សានុសិស្សប្រសិនបើសិស្សណាខ្លះធ្លាប់សម្ភាសឪពុកម្តាយ ជីដូន ជីតា ឬសាច់ញាតិរបស់ខ្លួនអំពីបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហម ។ សិស្សមួយចំនួន បានឆ្លើយថាខ្លួនធ្លាប់បានសួរឪពុកម្តាយអំពីជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។ លោក ឡុង ដានី បានបញ្ជាក់ថា អ្នកសម្ភាសន៍ត្រូវតែបញ្ជាក់អំពីវត្ថុបំណងរបស់ខ្លួនឲ្យបានច្បាស់លាស់ នៅពេលដែលសម្ភាសជនរងគ្រោះនៃរបបខ្មែរក្រហម ដើម្បីជៀសវាងការភាន់ច្រឡំ ព្រមទាំងរៀបចំកម្រងសំណួរឲ្យបានត្រឹមត្រូវ ។ ជាងនេះទៅទៀត អ្នកសម្ភាសន៍ត្រូវសុំការយល់ព្រមពីអ្នកផ្តល់បទសម្ភាសន៍ជាមុនសិន ។ អ្នកសម្ភាសន៍ត្រូវយកចិត្តទុកដាក់ស្តាប់ និងចេះកត់ត្រានូវព័ត៌មានសំខាន់ៗដែលអ្នកផ្តល់បទសម្ភាសន៍បានរៀបរាប់ប្រាប់ ។

មុននឹងបញ្ចប់កម្មវិធីវេទិកាថ្នាក់រៀន អ្នកនាង ស៊ុំ សាវីណា ប្រធានគម្រោងអប់រំផ្សព្វផ្សាយ និងទំនាក់ទំនងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានដឹកនាំសិស្សានុសិស្សដើរទស្សនាពិព័រណ៍ចល័តស្តីអំពីការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម ។ អ្នកនាងបានពន្យល់ប្រាប់សិស្សានុសិស្សថា ជនរងគ្រោះនៃរបបខ្មែរក្រហមមួយចំនួនយល់ឃើញថា ការជម្លៀសប្រជាជននៅក្នុងរបបខ្មែរក្រហមគឺជាចំណុចរបត់មួយដែលនាំទៅរកការបែកបាក់គ្រួសារ ការបង្ខំឲ្យធ្វើការការអត់អាហារ និងការស្លាប់ជាដើម ។

យុវជន ចាន់ លីណា អាយុ១៨ឆ្នាំ បានចូលរួមចែករំលែកថាធ្លាប់បានឮឪពុកម្តាយរៀបរាប់ប្រាប់អំពីបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហម និងធ្លាប់បានទស្សនាតាមរយៈទូរទស្សន៍ ។ លីណា បានបន្ថែមថា ការរស់នៅរបស់ប្រជាជននៅក្នុងរបបខ្មែរក្រហមមិនដូចគ្នាទាំងស្រុងនោះទេ ពោលគឺខុសគ្នាពីតំបន់មួយទៅតំបន់មួយ ។

រីឯ យុវជន ហា សុខហេង បាននិយាយថា ការសិក្សាអំពីរបបខ្មែរក្រហមធ្វើឲ្យយើងយល់ដឹងអំពីទុក្ខលំបាករបស់ឪពុកម្តាយ ។ សុខហេង បានរំឭកថា ម្តាយរបស់ខ្លួនត្រូវបានខ្មែរក្រហមបញ្ជាឲ្យធ្វើការនៅក្នុងរោងបាយសហករណ៍ ។ ប៉ុន្តែ គាត់មិនបានទទួលរបបអាហារគ្រប់គ្រាន់នោះទេ ។ គាត់បានបេះស្លឹកថ្នឹង ស្លឹកសង្កែ មកហូបរហូតដល់ខ្លួនរបស់គាត់ហើម ។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ ម្តាយរបស់ សុខហេង បានត្រឡប់មកភូមិវិញ ។ អ្នកជិតខាងរបស់គាត់គិតថា គាត់ប្រហែលជាស្លាប់បាត់ទៅហើយ ដោយសារតែបានបែកគ្នានៅក្នុងរបបខ្មែរក្រហម ។

ចំណែកឯ យុវតី តូ ស្រីខួច យល់ថាក្នុងនាមជាយុវជនជំនាន់ក្រោយ ការស្វែងយល់អំពីរបបខ្មែរក្រហមមានសារសំខាន់ណាស់ ក្នុងការកសាងសន្តិភាព និងទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅថ្ងៃអនាគត ។ ស្រីខួច បាននិយាយថា ជីដូនរបស់ខ្លួនមិនចង់រម្លឹកអំពីរបបខ្មែរក្រហមនោះទេ ដោយសារតែការឈឺចាប់ដែលគាត់បានជួបប្រទះហាក់ដូចជាធ្ងន់ធ្ងរ ។ មិនតែប៉ុណ្ណោះ ស្រីខួច បានបន្ថែមថា ជីតារបស់គាត់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ។

ជាកិច្ចបញ្ចប់កម្មវិធី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)" ដល់សិស្សានុសិស្សដែលបានចូលរួមវេទិកាថ្នាក់រៀននេះ ព្រមទាំងបានតម្កល់សៀវភៅមួយចំនួននៅក្នុងបណ្ណាល័យ ដើម្បីឲ្យសិស្សដទៃបានសិក្សាស្វែងយល់អំពីរបបខ្មែរក្រហម ។

**ម៉ែន ពិចិត្រ**

# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្ត
# នៅវិទ្យាល័យព្រែកថ្មី កាលពី









# សាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩) ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧









# ពីធីសម្ពោធផ្ទាំងពាក្យស្លោកនិយាយពីការអប់រំអំពើ[...]
# បឋមសិក្សាបឹងតាព្រាម សង្កាត់ត្រើយកោះ ក្រុងកំព[...]










# ប្រល័យពូជសាសន៍ក្នុងរបបខ្មែរក្រហម នៅសាលា
# ត ខេត្តកំពត កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧









# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិ
# នៅវិទ្យាល័យជ្រោយចង្វារ ភាល










# ត្តសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩) ពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧









# ពិធីបើកដំណើរការសាកល្បងគេហទំព័រអប់រំពីអំពើប្រល័យពូជស
# អភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយអាល្លឺម៉ង់ ពីថ្ងៃទី២៦-២៩ ខែមិថុ









# ាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយអង្គការ
# នា ឆ្នាំ២០១៧ នៅវិចិត្រសាលសហសម័យវិទ្យាស្ថានស្លឹករឹត









# ឡាំង អេង: ក្លាយជាក្មេងកំព្រាតាំងពីកុមារ

នៅប្រហែល៩គីឡូម៉ែតពីរង្វង់មូលទីរួមស្រុកអន្លង់វែង តាមបណ្តោយផ្លូវគ្រោះក្រហមមួយខ្សែ ដែលស្ថិតនៅភូមិទឹកជុំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ នៅពីមុខផ្ទះទាមដំបូលប្រក់សង្កសីមួយ លោកយាយ និងលោកតា បាននឹងកំពុងតែជជែកគ្នាលេងពីនេះពីនោះក្នុងទឹកមុខសប្បាយរីករាយ ។ ប៉ុន្តែទឹកមុខរបស់អ្នកទាំងពីរប្រែប្រួលមួយរំពេច នៅពេលដែលវត្តមានរបស់ខ្ញុំ ចូលទៅដល់ទីនោះភ្លាម ។ មិនបង្អង់យូរ ខ្ញុំក៏បានណែនាំខ្លួន និងបានជម្រាបអំពីគោលបំណងរបស់ខ្ញុំដល់ពួកគាត់ ។ នៅពេលដែលពួកគាត់បានស្គាល់ និងបានយល់ពីបំណងរបស់ខ្ញុំរួចហើយ ខ្ញុំក៏ចាប់ផ្តើមសួរគាត់ខ្លះពីជីវិតពិតរបស់គាត់ដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ។

មានសម្បុរសដូចកូនចៅចិនមើលទៅគាត់ទាំងពីរ ហាក់ដូចជាមិនមែនជាប្រជាជនរស់នៅក្នុងតំបន់នេះទេ ។ ជាការពិតណាស់ យាយ ឆេង ឡាំងអេង អាយុ ៦២ឆ្នាំ និងតា ថោង ថាន អាយុ៦៥ឆ្នាំ ជាអ្នកភ្នំពេញ ហើយគាត់មកភូមិទឹកជុំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យនេះ គឺដើម្បីមកលេងកូនប្រុសច្បងរបស់គាត់ដែលមានភរិយាជាអ្នកស្រុករស់នៅទីនេះ ។ ជាការពិត ប្រជាជនមួយភាគដែលកំពុងរស់នៅក្នុងតំបន់នេះ ជាអ្នកចំណូលថ្មីមកពីបណ្តាលខេត្តនានា នៃប្រទេសកម្ពុជា និងមួយចំនួនទៀត ជាអតីតកម្មាភិបាលខ្មែរក្រហម ដែលរស់នៅក្នុងតំបន់នេះ និងធ្លាប់រស់នៅក្រោមការគ្រប់គ្រងរបស់តាម៉ុក ។ ក្នុងបទសម្ភាស ឆេង ឡាំងអេង បានរៀបរាប់ពីដំណើជីវិតដ៏ជូចត់របស់គាត់ក្នុងរបបខ្មែរក្រហមដូចតទៅ៖

ឡាំងអេង មានស្រុកកំណើតនៅឃុំម្កាក់ ស្រុកអង្គស្នួល



ទិដ្ឋភាពផ្លូវឡើងទៅលើភ្នំដងរែក ព្រំប្រទល់ខ្មែរ-ថៃ ស្ថិតនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ


បឹងអន្លង់វែង ដែលជាកន្លែងស្តុកទឹកទុកសម្រាប់ប្រជាជននៅក្នុងសហគមន៍ប្រើប្រាស់ប្រចាំថ្ងៃ ។

ខេត្តកណ្តាល មានបងប្អូនចំនួន៦នាក់ ប្រុស២នាក់ និងស្រី៤នាក់ គាត់ជាកូនទី១ក្នុងគ្រួសារ ។ កាលរបប លន់ នល់ ពីឆ្នាំ១៩៧០-១៩៧៥ ដោយសារសង្គ្រាម គ្រួសាររបស់គាត់បានមករស់នៅក្នុងទីក្រុងភ្នំពេញ ។ នៅពេលដែលខ្មែរក្រហមបានទទួលជ័យជម្នះនៅថ្ងៃ១៧ មេសា ១៩៧៥ ភ្លាម ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឲ្យទៅកាន់ទីជនបទ ។ ដោយឡែកគ្រួសាររបស់ ឡាំងអេង ក៏ត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញទាំងបង្ខំដូចប្រជាជនឯទៀតដែរ ។ នៅពេលនោះ ឡាំងអេង ត្រូវបានបែកបាក់ពីឪពុកម្តាយ និងបងប្អូនរបស់គាត់ ដោយគាត់រួមជាមួយកូន និងស្វាមី ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅស្រុកសូទ្រនិគម ខេត្តសៀមរាប ។ ឡាំងអេង បានបន្តថា ក្នុងពេលធ្វើដំណើរទៅស្រុកសូទ្រនិគម គឺពិតជាមានការលំបាកខ្លាំងណាស់ ព្រោះនៅតាមផ្លូវធ្វើដំណើរមិនមានអាហារហូបគ្រប់គ្រាន់ ខ្វះទឹក ខ្វះជំរក និងត្រូវធ្វើដំណើរដោយថ្មើរជើងទៀត ហើយពេលដល់ទីណាគឺគាត់សម្រាកនៅទីនោះ ។ ខ្មែរក្រហម បានចាត់ទុកអ្នក១៧ មេសា ជាប្រជាជនថ្មី ។ ឡាំងអេង បានរៀបរាប់ថា គាត់ធ្លាប់តែរស់នៅស្រួល ហូបស្រួល ដេកស្រួល ហើយសូម្បីតែដើមស្រូវក៏មិនទាំងធ្លាប់ស្គាល់ផង ។ ការងារប្រចូតកាត់ ដកស្ទូង មានភាពលំបាកយ៉ាងខ្លាំងសម្រាប់គាត់នៅពេលនោះ ។ តែទោះជាយ៉ាងនេះក្តី គាត់ត្រូវរិតខំព្យាយាមជម្នះរាល់ការលំបាកទាំងឡាយ ស៊ូទ្រាំធ្វើការទាំងយប់ទាំងថ្ងៃ មិនហ៊ានឈប់សម្រាកទេ បើគ្មានការអនុញ្ញាតពីមេកង ។

ថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ជាថ្ងៃដែលរបបខ្មែរក្រហមដួលរលំ ឡាំងអេង និងគ្រួសារបានធ្វើដំណើរមកទីក្រុងភ្នំពេញវិញ ដើម្បីស្វែងរកបងប្អូន និងឪពុកម្តាយ ។ និយាយដល់ចំណុចនេះ ទឹកមុខរបស់ ឡាំងអេង ហាក់មានការស្រងូតស្រងាត់ បន្ទាប់មកទឹកភ្នែករបស់គាត់បានហូរ ។ ឈប់មួយស្របក់ទើប ឡាំងអេង និយាយបន្តថា ពេលមកដល់ផ្ទះ គាត់មិនបានជួបឪពុក និងប្អូនស្រីជាទីស្រលាញ់របស់គាត់ទេ ។ ឪពុករបស់គាត់ឈ្មោះ ឆេង គឹមស្រ៊ុន បានស្លាប់នៅបុស្សីកែវភ្នំពេញ ដោយសារជំងឺហើម ក្នុងរបបខ្មែរក្រហម ។ ចំណែកប្អូនស្រីទាំងពីររបស់គាត់ក៏ត្រូវបានស្លាប់នៅបុស្សីកែវ ដោយសារជំងឺហើមដូចឪពុករបស់គាត់ដែរ ។ មិនត្រឹមតែឪពុក និងប្អូនស្រីរបស់គាត់ទេ ដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហមនោះ ចំណែកឯបងប្អូនជីដូនមួយរបស់គាត់ជាច្រើននាក់ ក៏បានស្លាប់បាត់បង់ជីវិតក្នុងរបបនោះដែរ ។

ការបាត់បង់មនុស្សជាទីស្រឡាញ់ មានទំហំធំធេងណាស់សម្រាប់រូបគាត់ មិនអាចកាត់ថ្លៃ និងរកអ្វីមកជំនួសបានទេ ។ ការបាត់បង់នេះ ធ្វើឲ្យ ឡាំងអេង ក្លាយជាក្មេងកំព្រាឪពុក និងបាត់បង់ភាពកក់ក្តៅ ។ ការបាត់បង់មនុស្សជាទីស្រឡាញ់ បានដក់ជាប់ក្នុងអារម្មណ៍របស់ ឡាំងអេង អស់ជាច្រើនឆ្នាំមកហើយ ។ ឡាំងអេង តែងនិយាយរឿងរ៉ាវទាំងនេះប្រាប់ដល់កូនៗរបស់គាត់ អោយបានដឹងពីអារម្មណ៍ឈឺចាប់ របស់គាត់ និងរបបខ្មែរក្រហមដែលធ្វើឲ្យគាត់មានអារម្មណ៍ធូរស្បើយបានមួយកម្រិតដែរ ។

**ឡាយ សក្កដា**

# គ្មានជម្រើសទេសម្រាប់ខ្ញុំ

នាងខ្ញុំឈ្មោះ គង់ បូរ៉ាន់ ជានិស្សិតនៃសាកលវិទ្យាល័យបាត់ដំបង មានឱកាសបានទៅធ្វើទស្សនកិច្ចសិក្សានៅស្រុកអន្លង់វែងដែលជាតំបន់ប្រវត្តិសាស្ត្រ និងជាតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម នៅខេត្តឧត្តរមានជ័យ ។ តាមការធ្វើបទបង្ហាញ ការណែនាំ ការជួយទំនុកបម្រុងពីនាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ទើបធ្វើឲ្យខ្ញុំមានឱកាសបានទៅធ្វើបទសម្ភាសន៍ជាមួយប្រជាជនផ្ទាល់ដែលធ្លាប់រស់នៅតំបន់នោះ ដែលបានឆ្លងកាត់ព្រឹត្តិការណ៍ដែលមិនអាចបំភ្លេចបានសម្រាប់គាត់ ។ ខាងក្រោមជាបទសម្ភាសន៍រវាងខ្ញុំជាមួយ ទៀន នី៖



ទីន នី ផ្តល់បទសម្ភាសន៍ទាក់ទងនឹងរឿងរ៉ាវក្នុងរបបខ្មែរក្រហម ដល់ គង់ បូរ៉ាន និស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។

ទៀន នី អាយុ៦៥ឆ្នាំ ជាអតីតកងទ័ពរបស់ខ្មែរក្រហម សព្វថ្ងៃរស់នៅភូមិទឹកជុំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ នី បានចូលបម្រើអង្គការខ្មែរក្រហមនៅឆ្នាំ១៩៧៣ ។ អង្គការបានផ្លាស់ នី ពីកន្លែងមួយទៅកាន់កន្លែងមួយទៀតជាញឹកញាប់ ដែលធ្វើឲ្យ នី ជួបប្រទះរឿងរ៉ាវជាច្រើនក្នុងជីវិតកាលពីអតីតកាល ។

នី បានរៀបរាប់ឲ្យដឹងថា នៅឆ្នាំ១៩៧៥ ក្រោយពេលខ្មែរក្រហមបានទទួលជ័យជម្នះទាំងស្រុងហើយ ខ្មែរក្រហមបានជម្លៀសប្រជាជន ចេញពីក្រុងភ្នំពេញទាំងបង្ខំ ឲ្យទៅរស់នៅតាមជនបទ ស្រែចម្ការ ។ ដោយឡែក នី ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅស្រុកអូររាំង ខេត្តមណ្ឌលគិរី ។ នៅខេត្តមណ្ឌលគិរី នី បានរស់នៅជាមួយជនជាតិភាគតិច ។ ពេលនោះ នី បានបន្តធ្វើជាកងទ័ពដដែល ហើយកងទ័ពនៅពេលនោះមិនមានភារកិច្ចប្រយុទ្ធតតាំងជាមួយសត្រូវការពារទឹកដីទេ គឺនាំគ្នាធ្វើស្រែចម្ការ ពេលបានផលត្រូវយកមកដាក់ជម្រុករួម និងហូបរួមគ្នា ។

ចំណែក ការហូបចុករបស់កងទ័ពនៅសម័យនោះវិញ ពេលព្រឹកម៉ោង៧ ហូបបបរស រួចហើយចុះធ្វើការដល់ម៉ោង១១ ទើបឈប់សម្រាកហូបបាយថ្ងៃត្រង់ ។ លុះដល់ម៉ោង២រសៀលត្រូវចុះធ្វើការទៀតរហូតដល់ម៉ោង៥ល្ងាច ទើបឈប់សម្រាកហូបបាយ ពេលល្ងាច រួចហើយម៉ោង៦ (ពេលរដូវច្រូត) គាត់ត្រូវបោកស្រូវបន្តរហូតដល់ម៉ោង៩-១០ ទើបឈប់សម្រាក ។

ទោះបីយ៉ាងណា ជីវិតរបស់កងទ័ពនៅពេលនោះ រស់នៅបានសុខស្រួល មិនមានអ្វីលំបាកឡើយ ។ អង្គការតែងប្រាប់កងទ័ពថា ឪពុកម្តាយ បងប្អូន កូនចៅ នៅឯសមរភូមិក្រោយ រស់នៅបានសុខសប្បាយណាស់កុំបារម្ភ ។ តែ

ក្រោយឆ្នាំ១៩៧៩ ពេលដែលខ្មែរក្រហមចាញ់សង្គ្រាម ទើប នី បានដឹងថា ប្រជាជនដែលរស់នៅសមរភូមិក្រោយ ត្រូវខ្មែរក្រហមធ្វើបាប គាបសង្កត់ និងកាប់សម្លាប់ ដូច្នេះអ្វីដែលអង្គការបាននិយាយសុទ្ធតែជាពាក្យភូតកុហក ។

ពេលដែលកងទ័ពវៀតណាមវាយចូលមក នៅឆ្នាំ១៩៧៩ ខ្មែរក្រហមមួយចំនួនបានភៀសខ្លួនរត់ទៅរស់នៅក្នុងព្រៃ និងខ្លះទៀតបានរត់ទៅរស់នៅតាមបណ្ដោយព្រំដែនខ្មែរ-ថៃ ។ ចំណែក នី នៅធ្វើកងទ័ពខ្មែរក្រហមនៅខេត្តមណ្ឌលគិរីដដែល ។ នី បាននិយាយថា កងទ័ពខ្មែរក្រហមតែងគេចមិនឲ្យជួបជាមួយកងទ័ពវៀតណាមឡើយ ។ ចាប់ពីពេលនោះមក ជីវិតរបស់គាត់លំបាកវេទនាខ្លាំងណាស់ គ្មានអាហារហូបចុកគ្រប់គ្រាន់ ហើយអាហារប្រចាំថ្ងៃគឺមានតែក្ដួចប៉ុណ្ណោះ ។ កងទ័ពម្នាក់ត្រូវមានកាំភ្លើងមួយដើម ចបជីកមួយ កាំបិតមួយ ដោយចបជីកប្រើសម្រាប់ជីកក្ដួច ដីកដំឡូង យកមកធ្វើជាអាហារ ។

នៅឆ្នាំ១៩៨៧ នី បានទៅរស់នៅស្រុកឃុនហាន ប្រទេសថៃបានមួយរយៈ បន្ទាប់មក នី ក៏បានត្រឡប់មកខេត្តមណ្ឌលគិរីវិញ ។ នៅឆ្នាំ១៩៩៨ កងទ័ពខ្មែរក្រហមដែលនៅសេសសល់ បានធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ។ ក្រោយពេលខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល នី បានផ្លាស់ទីលំនៅមករស់នៅក្នុងភូមិទឹកជុំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ រហូតដល់សព្វថ្ងៃ ។

ចុងក្រោយ នី បានបង្ហាញពីទស្សនៈផ្ទាល់ខ្លួនរបស់គាត់ថា គាត់មិនចង់ឃើញរបបខ្មែរក្រហមកើតមានឡើងជាលើកទីពីរនៅក្នុងប្រទេសកម្ពុជាទៀតទេ ។ នី បានអំពាវនាវដល់កូនខ្មែរគ្រប់រូបឲ្យខិតខំសិក្សារៀនសូត្រ ដើម្បីរួមគ្នាជួយអភិវឌ្ឍប្រទេសកម្ពុជា ឲ្យក្លាយទៅជាប្រទេសមួយដែលមាន សេដ្ឋកិច្ចជឿនលឿន ដូចជាប្រទេសមួយចំនួននៅជិតខាងប្រទេសកម្ពុជាដែរ ។

**គង់ ប៉ូរ៉ាន់**



សិស្សសាលាបឋមសិក្សាក្នុងស្រុកអន្លង់វែង នៅក្នុងពិធីទទួលផ្ទាំងរូបភាពស្ដីពីតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ពីលោកនាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បណ្ឌិត លី សុខឃាង និងក្រុមការងារ ។

# ភាពឈឺចាប់ជំរុញឱ្យខ្ញុំចូលបម្រើយោធា

អ៊ី ចាន់តុល អាយុ៥០ឆ្នាំមានកូនប្រាំនាក់ សព្វថ្ងៃរស់នៅក្នុងភូមិទឹកជុំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ សព្វថ្ងៃ ក្រៅពីលក់ដូរនៅផ្ទះ តុល និងក្រុមគ្រួសារមិនមានដីស្រែចម្ការធ្វើទេ ។ តុល បានរំលឹកនូវរឿងរ៉ាវពីអតីតកាលរបស់គាត់ប្រាប់មកកាន់ខ្ញុំថា នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ គាត់រស់នៅក្នុងខេត្តកំពង់ចាម និងមានបងប្អូន៥នាក់ ។ ក្នុងពេលនោះ តុល ទើបតែមានអាយុប្រហែលជា១១ទៅ១២ឆ្នាំប៉ុណ្ណោះ ខ្មែរក្រហមបានចាត់ឲ្យធ្វើការនៅក្នុងកងកុមារដើម្បីរើសអាចម៍គោ លើកទំនប់ កាប់ទន្ទ្រានខែត្រ ។ តុល បានរៀបរាប់ថា ក្រោយពីរបបខ្មែរក្រហមបានបញ្ចប់ទៅ ក្រុមគ្រួសាររបស់គាត់មិនមានបាត់បង់សមាជិកណាម្នាក់នោះទេ ប៉ុន្តែបងប្អូនជីដូនមួយរបស់គាត់ បានបាត់បង់ជីវិតអស់ប្រមាណជាង១០នាក់ ។

នៅឆ្នាំ១៩៨០ ដោយមានការឈឺចាប់ និងធ្លាប់រស់នៅយ៉ាងលំបាក ព្រមទាំងមើលឃើញពីការធ្វើទារុណកម្ម និងការសម្លាប់ប្រជាជនក្នុងរបបខ្មែរក្រហមបានជំរុញឲ្យ តុល ស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពរដ្ឋាភិបាលថ្មី ដើម្បីវាយបណ្តេញយោធាខ្មែរក្រហម ។ ដោយសារតែ តុល ជាយោធាដែលស្ម័គ្រចិត្ត ដូចនេះគាត់ត្រូវបានថ្នាក់លើទុកចិត្ត និងជ្រើសរើសឲ្យធ្វើជាអ្នកដឹកនាំកងទ័ពមួយ «គ» ដែលមានសមាជិកចំនួនជាង១០០នាក់ ។ កូនទាហានដែលនៅក្រោមបង្គាប់របស់ តុល ស្រឡាញ់រាប់អាន តុល ណាស់ ព្រោះជាញឹកញាប់គាត់តែងតែចុះទៅសួរសុខទុក្ខ និងយកអាសារដល់កូនទាហាន ។

ចាប់ពីឆ្នាំ១៩៨០ តុល បានចល័តកងទ័ពពីតំបន់មួយទៅ



រូបទីពីររាប់ពីឆ្វេង ៖ ហ៊ិន សុចិត្រា និស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ទស្សនកិច្ចទីតាំងដុតសព ប៉ុល ពត នៅលើភ្នំដងរែក ។

តំបន់មួយផ្សេងៗទៀតជាញឹកញាប់ ។ នៅក្នុងអំឡុងឆ្នាំ១៩៩៤ គុល បានផ្លាស់ទៅភូមិភាគ៣ ក្នុងកងពល៤៤ ក្នុងភូមិស្រែខ្ទុង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដើម្បីស៊ើបការណ៍ពីកងទ័ពខ្មែរក្រហម នៅភ្នំឱរ៉ាល់ និងដឹកនាំកម្លាំងទ័ពឡើងទៅវាយជាមួយខ្មែរក្រហម ។ គាត់ក៏បានស៊ើបការណ៍ឲ្យឃ្លាំង៨៦ ដែលមានទីតាំងនៅត្បាតពង ក្បែរថ្នល់ទទឹង ខេត្តកណ្តាល ដែលជាកន្លែងផ្ទុកគ្រាប់ និងអាវុធ ។ ក្នុងឋានៈជាអ្នកស៊ើបការណ៍ ពេលខ្លះ គុល ទៅស៊ើបជាលក្ខណៈទ្រង់ទ្រាយកងទ័ព ហើយពេលខ្លះទៀត គាត់ត្រូវក្លែងភេទធ្វើជាអ្នកដឹកត្រី ឬមាន់ ដើម្បីទៅស៊ើបទីតាំងភូមិសាស្ត្រ និងតាមដានចំនួនកងកម្លាំងរបស់សត្រូវ ។


ផ្ទះរបស់ប្រជាជន នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

នៅអំឡុងឆ្នាំ១៩៩៥ មានយុទ្ធនាការទូទាំងប្រទេសដើម្បីវាយប្រហារកងទ័ពខ្មែរក្រហមដោយរយៈប្រមាណ១-២ខែម្តង ត្រូវចុះវាយម្តងនៅខេត្តកំពង់ចាម ។ រហូតដល់ចុងឆ្នាំ១៩៩៥ និងដើមឆ្នាំ១៩៩៦ គុល បានផ្លាស់ទៅនៅឃុំស្តៅ ស្រុករតនមណ្ឌល ខេត្តប៉ៃលិន ដើម្បីវាយបណ្តេញខ្មែរក្រហមដោយវាយចាប់ពីស្ទឹង រហូតដល់ជាយព្រំដែនថៃ ក្នុងគោលបំណងកុំឲ្យខ្មែរក្រហមឈរជើងបាន ។

ក្រោយសមាហរណកម្មឆ្នាំ១៩៩៨ ស្ថានភាពក្នុងប្រទេសខ្មែរមានភាពល្អប្រសើរទើបនៅឆ្នាំ២០០២ គុល បានផ្លាស់មកឈរជើងនៅខណ្ឌសីមាលេខប្រាំពីរជើងភ្នំដងរែក ស្ថិតក្នុងភូមិត្រពាំងតាវ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដោយគាត់គ្រប់គ្រងកងទ័ពមួយ «យ» មានសមាជិកចាប់ពី២០ ទៅ៣០នាក់ ។ កងរបស់ គុល បានដើរល្បាតចាប់ពីខណ្ឌសីមាលេខ៧ ទៅដល់លេខប្រាំបួន និងដើរល្បាតតាមព្រំដែនខ្មែរ-ថៃ ខ្លាចក្រែងថៃលួចដកបង្គោលព្រំដែន និងលួចឈូសឆាយផ្លូវផ្សេងៗតាមបណ្តោយព្រំដែន ។

ចាប់តាំងពី គុល ផ្លាស់មកឈរជើងនៅអន្លង់វែងមក ស្ថានភាពនៅតាមបណ្តោយព្រំដែនមានសភាពធម្មតា គឺថៃមិនមានធ្វើសកម្មភាពឈ្លានពាននោះទេ ប៉ុន្តែនៅឆ្នាំ២០០៨ ថៃបានធ្វើការវាយប្រហារមកលើប្រទេសកម្ពុជា ទើប គុល ត្រូវផ្លាស់ទៅឈរជើងនៅលើប្រាសាទតាក្របី ដើម្បីការពារកុំឲ្យកងទ័ពថៃធ្វើការឈ្លានពានមកក្នុងទឹកដីកម្ពុជា ។ គុល នៅការពារលើប្រាសាទតាក្របីបានមួយខែ ក៏បានផ្លាស់ឲ្យមកនៅភូមិត្រពាំងតាវ វិញ ។ ទោះបីជីវិតត្រូវរស់នៅចល័តពីកន្លែងមួយទៅកន្លែងមួយ ការបែកពីក្រុមគ្រួសារ និងរស់នៅយ៉ាងលំបាកយ៉ាងណាក៏ដោយ ក៏ គុល មានការសប្បាយចិត្ត និងមានចិត្តក្លាហាន តស៊ូដើម្បីការពារជាតិមាតុភូមិ ។

គុល បានលើកឡើងថា ទោះបីមានការលំបាកបន្តិចក្តី និងមានស្លៀកពាក់មិនហ៊ឺហាដូចកងទ័ពថៃពិតមែន តែកងទ័ពខ្មែរក៏មិនខ្លាច និងទប់ទល់ជាមួយសត្រូវដែលមានគំនិតឈ្លានពានទឹកដីរបស់ខ្លួនឡើយ ។

យ៉ាងណាមិញ ដោយសារសព្វថ្ងៃ ថុល មានវ័យចាស់បន្តិច មិនមានកម្លាំងអាចឡើងភ្នំបាន ព្រមទាំងចង់ផ្លាស់ប្តូរជីវិតចេញពីកងទ័ពដែលគាត់បម្រើអស់ជាច្រើនឆ្នាំមក ទើបនៅឆ្នាំ២០១៤ ថុល បានសម្រេចចិត្តឈប់ធ្វើជាទាហាន ហើយវិលមករស់នៅជួបជុំជាមួយក្រុមគ្រួសាររបស់ខ្លួនវិញ ។

**ហ៊ិន សុចិត្រា**

# អតីតមេភូមិនៅក្នុងតំបន់រំដោះខ្មែរក្រហម

បន្ទាប់ពីរដ្ឋប្រហារ ឆ្នាំ១៩៧០ នៅភូមិចេក ឃុំរការ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ត្រូវបានខ្មែរក្រហមចូលមកធ្វើសកម្មភាពឃោសនា ក្នុងគោលបំណងឲ្យប្រជាជនចូលរួមជាមួយចលនារបស់ក្រុមខ្លួន ដើម្បីវាយដណ្តើមយកអំណាចពីរបបសាធារណរដ្ឋខ្មែរ ។

នៅពេលនោះ ផាន់ ចេប ត្រូវបានខ្មែរក្រហមបានចាត់តាំងឲ្យធ្វើជាមេភូមិចេក និងទប់ស្កាត់ប្រជាជនកុំឲ្យឆ្លងទៅរស់នៅខាងរដ្ឋាភិបាលដែលគ្រប់គ្រងដោយ លន់ នល់ ។

ចេប មានស្រុកកំណើតនៅស្រុកអង្គស្នួល ខេត្តកណ្តាល ។ ចេប បានរៀបការជាមួយ អេង យីម ដែលជាអ្នកស្រុករស់នៅភូមិជាមួយគ្នា នៅឆ្នាំ១៩៧០ ។ ឆ្នាំ១៩៧១ ខ្មែរក្រហមបានចូលមកដល់ភូមិដែល ចេប រស់នៅ ។ មួយឆ្នាំក្រោយមក ខ្មែរក្រហមបានចូលមករស់នៅក្នុងភូមិកាន់តែច្រើន និងបានស្នាក់នៅតាមផ្ទះប្រជាជន មានទាំងគណៈស្រុកឈ្មោះ សំបួរ ជាអ្នកស្រុកមកពីឃុំក្រាំងម្កាក់ និងតាអាន (គណៈស្រុកកណ្តាលស្ទឹង មកពីកំពង់ឆ្នាំង) មកគ្រប់គ្រងតំបន់១៥ ហើយភូមិចេកនៅពេលនោះបានក្លាយជាតំបន់រំដោះ ។ ចេប បានគាំទ្រខ្មែរក្រហម រហូតដល់គាត់ចែករំលែកអាហារឲ្យខ្មែរក្រហមទៀតផង ។


ផាន់ ចេប កំពុងរៀបរាប់ពីប្រវត្តិក្នុងរបបខ្មែរក្រហម ប្រាប់ ផាភរដ្ឋ មេត្តានិស្សិតស័គ្រចិត្តគម្រោងជំរុញឲ្យមានការទទួលខុសត្រូវ ។

ក្រោយមក ចេប បានប្តូរទៅរស់នៅខាងកើតផ្លូវជាតិលេខ ២ ស្ថិតនៅក្នុងតំបន់៣២ ដែលគ្រប់គ្រងដោយ តាម៉ុក ។ ចំណែកប្រជាជននៅភូមិចេក ត្រូវបានខ្មែរក្រហមជម្លៀស(តាំងពីដើមឆ្នាំ១៩៧២) ឲ្យទៅរស់នៅតំបន់រំដោះស្ថិតនៅខាងក្រោយភ្នំស្រង់ ហើយ ចេប នៅធ្វើជាប្រធានភូមិដដែល ។

ឆ្នាំ១៩៧៣ អាមេរិកបានទម្លាក់គ្រាប់បែក ។ ខ្មែរក្រហមបានជម្លៀស ចេប និងអ្នកភូមិដទៃទៀត ឲ្យទៅរស់នៅភូមិសាលាគ្រោះ ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺវិញ ។ ពេលនោះ ចេប បានស្គាល់មនុស្សម្នាក់នៅភូមិត្រាញ់ ហើយមនុស្សម្នាក់នោះបានមកខ្សឹបប្រាប់ ចេប ថា គាត់បានឮគេនិយាយថា ឲ្យតែស្នើអង្គការទៅរស់នៅអង្គតាព្រូច នោះអង្គការប្រាដកជាឲ្យទៅមិនខាន ។ បន្ទាប់មក ចេប ក៏បានស្នើសុំអង្គការទៅអង្គតាព្រួច តែនៅពេលនោះមិនមែនមានតែ ចេប ម្នាក់ទេ ប្រជាជនមួយភូមិក៏បានស្នើសុំទៅទីនោះដែរ ។ តែពេលនោះ ចេប ត្រូវបានឈ្លបឃុំចោទថា ជាខ្មាំងបំផុសបំផុលប្រជាជន ។

នៅឆ្នាំ១៩៧៥ ចេប បានទៅនៅអង្គតាព្រូច ឃុំរការ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ខាងកើតផ្លូវជាតិលេខ៣ ។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ម្តាយរបស់ ចេប បានកើតជំងឺរាកមូល ។ ចេប បានទៅស្នើសុំអង្គរអង្គការពីរបីកំប៉ុង ដើម្បីយក

មកបបរឲ្យម្តាយរបស់គាត់ហូប ប៉ុន្តែ ខ្មែរក្រហមមិនបានឲ្យអង្ករមកគាត់ទេ ថែមទាំងចង់យកគាត់ទៅសម្លាប់ទៀត ។ ចេប បានឲ្យដឹងថា ខ្មែរក្រហមរឹបអូសយកស្រូវចំនួន៦បាវ ដែលគាត់ខំដឹកមក ។

ចេប បានរៀបរាប់ពីព្រឹត្តិការណ៍ដែលខ្មែរក្រហមយកទៅសម្លាប់ថា ក្រោមបញ្ជារបស់មេឃុំ១២ ឈ្មោះ ស្នួង ប្រហែលជាម៉ោង៥ល្ងាច ឈ្លបឃុំឈ្មោះ ណែម ដែលមានការចូលរួមជាមួយឈ្មោះ ម៉ុល, អ៊ុច, ប៊ិច និង នារីម្នាក់ (មិនចាំឈ្មោះ) បានប្រាប់គាត់ឲ្យទៅបររទេះគោដឹកស្រូវនៅវត្ត ពេលទៅដល់ឈ្លបឲ្យគាត់ទៅកើបស្រូវ ទាំងយប់ងងឹត ។ ចេប បានទៅអើតមើល ប៉ុន្តែមិនឃើញស្រូវទេ ។

នៅពេលគាត់ដើរដល់ទ្វារក្រោយស្រាប់តែឈ្លបបានមកភ្ជង់គាត់ឲ្យលើកដៃ ។ ពេលនោះ ចេប មិនបានលើកដៃតាមបញ្ជាទេ ដោយបម្រុងនឹងរត់គេចខ្លួន តែត្រូវឈ្លបដើរមកពីក្រោយវាយគាត់នឹងពូថៅបណ្តាលឲ្យសន្លប់ ។ រយៈពេលពីរបីនាទីក្រោយមកគាត់ក៏បានដឹងខ្លួន ហើយបានរត់គេចទៅពួននៅក្នុងបឹងកំបោក ។ ពេលនោះ ឈ្លបឃុំទាំង៤នាក់ បានយកស្នូចាក់រកសាកសពរបស់ ចេប តែរកមិនឃើញ ។ បន្ទាប់មក ឈ្លបក៏បានបាញ់រះនៅទីនោះជាច្រើនគ្រាប់ទៀត ។

ចេប បានត្រឡប់មកអង្គតាព្រូចវិញ ។ នៅម៉ោងប្រហែល១២យប់ ចេប បានមកសុំផ្ទះបងថ្លៃសម្រាកមួយយប់ ។ តែបងថ្លៃមិនឲ្យសម្រាកទេ ព្រោះខ្លាចឈ្លបចោទប្រកាន់ ។ ចេប បានទៅផ្ទះយាយ លន់ សុំប្រេងកូឡាដើម្បីលាបមុខរបួស ស្រាប់តែព្រឹកឡើង នីសារឈ្មោះ សឿង បានមកភ្ជង់គាត់ម្តងទៀត និងនាំគាត់ទៅអង្គតាព្រូច ហើយមេឃុំក៏បានបញ្ជូនគាត់ទៅខាងភូមិកំពង់ស្រឡូង ឃុំបឹងខ្នា ស្រុកកណ្តាលស្ទឹង ដើម្បីសួរចម្លើយ ។ ខ្មែរក្រហមបានឃុំ ចេប នៅក្នុងគុកសង់ (ពីមុនស្ថិតនៅក្នុងស្រុកកណ្តាលស្ទឹង) រយៈពេលបីថ្ងៃ ។ ក្រោយមក ខ្មែរក្រហមក៏បានដោះលែង ចេប មកវិញ ព្រោះដឹងប្រវត្តិរូបរបស់គាត់ជាប្រជាជន មិនជាប់ពាក់ព័ន្ធនឹងរបបលន់ នល់ ទេ ។

នៅខែឧសភា និងខែមិថុនា ឆ្នាំ១៩៧៥ ចេប បានចូលធ្វើការនៅខាងសិប្បកម្មស្រុក ។ ការងារនៅទីនោះ គឺផលិត ផាលឲ្យប្រជាជនប្រើប្រាស់ ។ ដល់ឆ្នាំ១៩៧៦ ចេប បានទៅនៅខាងគោកត្រប់ ។ ចេប បានឲ្យដឹងថា ពេលធ្វើការនៅខាងសិប្បកម្មស្រុក នៅគោកត្រប់ គាត់ឃើញប្រជាជន១៧មេសាដែលជាអ្នកជំងឺប្រហែលពី៤-១០នាក់ ដែលនៅមានដង្ហើមនៅឡើយ ត្រូវបានខ្មែរក្រហមយកក្រណាត់សមកគ្របមុខ ហើយយកទៅកប់ចោលតែម្តង ។ គោកត្រប់ដំបូងឡើយ មានគណៈស្រុកឈ្មោះ តា០៩ គ្រប់គ្រង ក្រោយមកត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅឆ្នាំ១៩៧៧ ។

នៅឆ្នាំ១៩៧៧ ចេប ត្រូវបានអង្គការចាត់ឲ្យទៅដឹកប្រហុកយកមកឲ្យកងចល័តនៅភូមិប្រយុទ្ធ និងភូមិដាច់ខាត ឃុំឈើខ្មៅ ស្រុកកោះធំ ដែលមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីសំណាក់កងទ័ពខ្មែរក្រហម ។ ឆ្នាំ១៩៧៨ ចេប ត្រូវបានចាត់ឲ្យទៅស្ទូងនៅជិតផ្សារកន្ទួត ។ ចេប មានបងប្រុសម្នាក់ឈ្មោះ ដាន់ រីម ចូលជាកងឈ្លបតាំងពីឆ្នាំ១៩៧២ តាមសេចក្តីអំពាវនាវរបស់សម្តេចសីហនុ ពីទីក្រុងប៉េកាំង ឲ្យកូនចៅអ្នកដែលស្មោះត្រង់នឹងព្រះអង្គឲ្យចូលព្រៃម៉ាកគី ។ ចេប បានរៀបរាប់ពីទំនាក់ទំនងរបស់ខ្លួនជាមួយនឹងបងប្រុសថា ថ្វីត្បិតជាបងប្អូននឹងគ្នាក៏ពិតមែន តែមិនដែលរាប់អានក្នុងនាមជាបងប្អូនឡើយ សូម្បីពេលឪពុកម្តាយស្លាប់ ក៏បងប្រុសម្នាក់នេះមិនទៅចូលរួមធ្វើបុណ្យឪពុកម្តាយដែរ ។ ដាន់ រីម ធ្វើជាប្រធានសហករណ៍ នៅពេលដែល ចេប ត្រូវបានចោទប្រកាន់ថាជាខ្មាំង ។ ពេលដែលឈ្លបបណ្តើរ ចេប នៅតាមផ្លូវពេលយប់ ហើយបានជួបបងប្រុសនៅតាមផ្លូវ បងប្រុសរបស់គាត់បែរជាធ្វើមិនឃើញទៅវិញ ។

បន្ទាប់ពីខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ចេប បានវិលត្រឡប់មករស់នៅជួបជុំជាមួយគ្រួសារវិញ តែ ចេប បានបាត់បង់សមាជិកគ្រួសារចំនួនបីនាក់ គឺឪពុកម្តាយ និងបងស្រីម្នាក់ ។ បច្ចុប្បន្ន ចេប មានកូនចំនួន៦នាក់ ស្រី៤នាក់ និងប្រុស២នាក់ ។ ចេប បានមានប្រសាសន៍ថា អ្វីដែលរបបខ្មែរក្រហមបានបន្សល់ទុកឲ្យគាត់រហូតមកដល់សព្វថ្ងៃនេះគឺ ភាពឈឺចាប់ និងការព្រាត់ប្រាស់ក្រុមគ្រួសារ ហើយជាពិសេសទៀតនោះ ស្លាកស្នាមរបួសដែលគាត់ត្រូវបានឈ្លបឃុំវាយ ធ្វើឲ្យឆ្អឹងក្បាលរបស់គាត់កំពិតដែលធ្វើឲ្យគាត់នៅចងចាំរហូតមក ។

**ជារាជ្ជ មេត្តា**

# សហព្រះរាជអាជ្ញាតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន

នៅម៉ោង៩ព្រឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ប្រធានអង្គជំនុំជម្រះសាលាដំបូង និល ណុន បានបើកកិច្ចដំណើរការនីតិវិធីស្តាប់សវនាការស្តីពីការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០២ ។ ក្រឡាបញ្ជីសវនាការជូនដំណឹងថា គ្រប់ភាគីទាំងអស់មានវត្តមាននៅក្នុងសវនាការ ។

លោកចៅក្រម និល ណុន បានរំឭកឡើងវិញដល់សាធារណជន ក៏ដូចជាគ្រប់ភាគី អំពីកាលវិភាគនៃការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល ។

កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលនឹងត្រូវប្រព្រឹត្តទៅតាមពេលវេលាដូចខាងក្រោម ៖

◆ ដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយថ្ងៃក្នុងការថ្លែងការណ៍

◆ សហព្រះរាជអាជ្ញាមានរយៈពេលពីរថ្ងៃក្នុងការថ្លែងការណ៍

◆ លោក នួន ជា មានរយៈពេលពីរថ្ងៃក្នុងការថ្លែងការណ៍

◆ លោក ខៀវ សំផុន មានរយៈពេលមួយថ្ងៃកន្លះក្នុងការថ្លែងការណ៍

◆ រយៈពេលមួយថ្ងៃត្រូវបានបម្រុងទុកសម្រាប់ការជំទាស់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញា និង

◆ ការជំទាស់បញ្ចប់ និងសេចក្តីថ្លែងការណ៍ចុងក្រោយរបស់ជនជាប់ចោទ ដែលមានរយៈពេល៤ម៉ោងនៅថ្ងៃទី២៣ មិថុនា ។

លោកប្រធានអង្គជំនុំជម្រះ និល ណុន បានថ្លែងថា បន្ទាប់ពី



ជនជាប់ចោទ ខៀវ សំផន នៅក្នុងសាលសវនាការកាត់ទោសសំណុំរឿង០០២ វគ្គ២

សវនាការស្តាប់ការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ បិទបញ្ចប់កិច្ចពិភាក្សាដេញដោលនេះ អង្គជំនុំជម្រះនឹងបិទបញ្ចប់កិច្ចដំណើរការនីតិវិធី ហើយនឹងប្រកាសប្រាប់ដល់សាធារណជនអំពីកាលបរិច្ឆេទនៃការប្រកាសសាលក្រម នៅពេលវេលាសមស្របណាមួយ ។

ជាកិច្ចបន្ទាប់ លោកប្រធានចៅក្រម និល ណុន បានរំឭកដល់គ្រប់ភាគីទាំងអស់ឲ្យនិយាយយឺតៗ និង ច្បាស់ៗ ដើម្បីងាយស្រួលក្នុងការបកប្រែ ។

តាមរយៈរបាយការណ៍ពិនិត្យសុខភាពរបស់គ្រូពេទ្យនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានផ្ញើមកកាន់អង្គជំនុំជម្រះកាលពីព្រឹកបានបញ្ជាក់ប្រាប់ថា ជនជាប់ចោទ នួន ជា មានលទ្ធភាពអាចចូលរួមស្តាប់ក្នុងបន្ទប់សវនាការ បានប្រហែល ២០នាទី ។ ជាមួយគ្នានោះដែរ លោកប្រធានចៅក្រម និល ណុន បានបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា មកកាន់សវនាការ និងបានប្រាប់ទៅជនជាប់ចោទថា ប្រសិនបើជនជាប់មានអារម្មណ៍ថា មិនអាចអង្គុយនៅក្នុងបន្ទប់សវនាការបាន នោះជនជាប់ចោទអាចត្រឡប់ទៅចូលរួមស្តាប់សវនាការនៅបន្ទប់ខាងក្រោមសាលសវនាការបាន ក្រោយពីធ្វើការស្នើសុំមកកាន់អង្គជំនុំជម្រះ ។ សំណើសុំផ្លាស់ទៅកាន់បន្ទប់ខាងក្រោមសវនាការដើម្បីឲ្យ នួន ជា អាចចូលរួមស្តាប់កិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយ ត្រូវបានធ្វើឡើងបន្ទាប់ពីរយៈពេលប្រហែល២៥នាទី ដែល នួន ជា បានចូលរួមស្តាប់នៅក្នុងសាលសវនាការ ។

លោកប្រធានចៅក្រម និល ណុន បានរំឭកដល់ភាគីទាំងអស់អំពីសេចក្តីណែនាំចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៧ ព្រមទាំងបានអានសេចក្តីណែនាំទាំងស្រុងដល់សវនាការ ។

សេចក្តីណែនាំនេះមានបំណងជួយដល់កិច្ចដំណើរការនៃការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ បិទបញ្ចប់កិច្ចពិភាក្សាដេញដោលប្រព្រឹត្តទៅដោយរលូន ។ សេចក្តីណែនាំនេះ ក៏បានលើកឡើងជាចំនុចពិសេស និងជានីតិវិធីសម្រាប់ភាគីអាចថ្លែងនូវសេចក្តីថ្លែងការណ៍ដែលបានមកដោយការធ្វើទារុណកម្មនៅក្នុងការបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ។

លោកប្រធានចៅក្រម និល ណុន បានថ្លែងអំពី ចម្លើយដែលបានដោយការបង្ខិតបង្ខំមិនមានតម្លៃជាភស្តុតាងនៅក្រោមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងនៅក្រោមអនុសញ្ញាប្រឆាំងទារុណកម្ម ។ ឯកសាររាយការណ៍ទាំងឡាយដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម ត្រូវបានធ្វើសម្រាប់ប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម ដូចនឹងភស្តុតាងដែលឯកសាររាយការណ៍ត្រូវបានបង្កើត ។ បន្ថែមពីនេះទៅទៀត អង្គជំនុំជម្រះ បានលើកឡើងអំពីភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មមិនអាចយកមកបានប្រើសម្រាប់បង្ហាញការពិតនៃខ្លឹមសារដែលបានថ្លែងទេ ប៉ុន្តែព័ត៌មានជាសត្យានុម័តជាមួយនឹងចម្លើយសារភាព និងចំណារដែលចារពីអ្នកសួរចម្លើយ ឬថ្នាក់លើរបស់ពួកគេអាចប្រើប្រាស់បាន ។

លោកប្រធានចៅក្រមបានរំឭកម្តងទៀតដែលសម្អាងហេតុរបស់អង្គជំនុំជម្រះនេះទាក់ទងនឹង "ហានិភ័យពិតប្រាកដ" ដែលអំពើទារុណកម្មនៅក្នុងមន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខផ្សេងទៀតត្រូវបានប្រើដើម្បីទទួលបានចម្លើយសារភាព ហើយភាគីណាមួយ ដែលមានបំណងចង់ផ្អែកទៅលើភស្តុតាងទាំងនេះគួរបង្ហាញជាមុនថាឯកសារនោះមិនមែនជាឯកសារដែលបានដោយសារអំពើទារុណកម្មទេ ។ ដោយសារតែជនជាប់ចោទនៅក្នុងសំណុំរឿងត្រូវបានចោទប្រកាន់ពីអំពើទារុណកម្ម ដូច្នេះអង្គជំនុំជម្រះត្រូវតែអនុវត្តបទដ្ឋានខ្ពស់ជាងនេះដើម្បីបង្ហាញភស្តុតាងដោយកំណត់ការកើតឡើងនៃអំពើទារុណកម្ម ។ សេចក្តីសម្រេចពីមុនរបស់អង្គជំនុំជម្រះទាក់ទងនឹងហានិភ័យពិតប្រាកដដែលជាភស្តុតាងទទួលបានពីអំពើទារុណកម្មអាចមានលក្ខណៈខុសគ្នាពីសេចក្តីសន្និដ្ឋានចុងក្រោយ ។

ជាចុងក្រោយ លោកប្រធានចៅក្រម និល ណុន បានអានគោលការណ៍អំពីសេចក្តីសន្និដ្ឋានដែលជាភស្តុតាងស្តាប់ចម្លើយ ហើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមិនមានគ្រោះថ្នាក់ និងការជះឥទ្ធិពលមិនត្រឹមត្រូវពីភស្តុតាងបានដោយសារអំពើទារុណកម្ម លុះដល់ពេលចាំបាច់អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យភាគីទាំងអស់ធ្វើសេចក្តីយោង ដូចជា ព័ត៌មានពេលបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ។ លុះត្រាតែភាគីបង្ហាញឲ្យអង្គជំនុំជម្រះបានសន្មតថា ភស្តុតាងដែលភ្ជាប់មកនោះត្រូវយកមកពិភាក្សាដោយសារភស្តុតាងនោះទទួលបានមកពីការធ្វើទារុណកម្ម ។

លោកប្រធានចៅក្រមបានផ្តល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ្រ អង្គ ។

លោក ពេជ្រ អង្គ បានណែនាំខ្លួន និងបានថ្លែងថា នេះគឺជាថ្ងៃល្អក្នុងការថ្លែងពីការបិទបញ្ចប់កិច្ចពិភាក្សាដេញដោល និងកម្រោងសំណង បន្ទាប់ពីបិទបញ្ចប់ការស្តាប់សវនាការលើភស្តុតាងអស់រយៈពេលជាង២០០ថ្ងៃ ។

លោក ពេជ្រ អង្គ បានពន្យល់ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តំណាងជាក្រុមនៃដើមបណ្តឹងរដ្ឋប្បវេណី ៣.៨៦៧នាក់ និងមកពិភាក្សាបណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ។ ចំណោមនេះ ២.១៩៥ រស់នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត និងអ្នកនៅសល់រស់នៅក្រៅភ្នំពេញ ។ លោកមេធាវី បានកត់សម្គាល់ថា តួលេខចំនួនដើមបណ្តឹងរដ្ឋប្បវេណីសរុបមិនស្មើទេ ព្រោះភាគី១៨១នាក់បានបាត់បង់ជីវិតទៅហើយ រាប់ចាប់ពីពេលតុលាការចាប់ផ្តើម ហើយក្រៅពីនេះ មានបណ្តឹង៣៤បន្តបណ្តឹងជាបណ្តឹងស្នងតំណែង ។ លោក ពេជ្រ អង្គ បានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណី៦៤នាក់បានផ្តល់សក្ខីកម្មនៅសវនាការ ដែល ១០នាក់ក្នុងនោះ មានអាយុ១៦ឆ្នាំនៅក្នុងរបបខ្មែរក្រហម ។ អ្នកទាំងនោះជា អ្នកថ្មីផង និងអ្នកមូលដ្ឋានផង ។

លោកមេធាវីបានសម្គាល់ថា ក្នុងការថែងអំពីវិធាន ២៣ ស្ទួនបួននៃវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យប្តឹងប្រឆាំងនឹងជនជាប់ចោទ ដោយបានជំនួយពីសហព្រះរាជអាជ្ញាសម្រាប់សំណងផ្លូវចិត្ត និងសំណងសមូហភាព ។

លោក ពេជ្រ អង្គ បានថ្លែងទៀតថា នៅក្នុងការបិទបញ្ចប់កិច្ចពិភាក្សាដេញដោល សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងផ្តល់ការបង្ហាញអំពីសក្ខីកម្មមុនសវនាការ ដូច្នេះ ដើម្បីជួយឲ្យសវនាការឃើញពីធាតុផ្សំនៃបទឧក្រិដ្ឋកម្ម និងបង្ហាញពីផលប៉ះពាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ។

លោកមេធាវី បានបង្ហាញនីតិវិធីនៃការធ្វើបទបង្ហាញ ។ ជាដំបូង លោកនឹងពិភាក្សាសក្ខីកម្មដែលទាក់ទងនឹងការដ្ឋានការងារ និងការធ្វើទុក្ខបុកម្នេញមកលើជនជាតិចាម ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចេត វ៉ាន់លី នឹងថ្លែងពីព័ត៌មានដែលទាក់ទងនឹងសហករណ៍ត្រាំកក់ ការធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិក និងមន្ទីរសន្តិសុខក្រាំងតាចាន់ ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហុង គីមសួន នឹងថ្លែងពីមន្ទីរសន្តិសុខ៣កន្លែង និងការបោសសម្អាតផ្ទៃក្នុង ។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ម៉ារី ហ្គីរ៉ូដ នឹងថ្លែងពីការប្រព្រឹត្តមកលើជនជាតិវៀតណាមនៅរបបកម្ពុជាប្រជាធិបតេយ្យ និងការបង្ខំរៀបការ ។ នៅក្នុងវគ្គបញ្ចប់សវនាការ លោកស្រី ហ្គីរ៉ូដ និងលោក ពេជ្រ អង្គ នឹងរាយការណ៍អំពីប្រភពសំណងដែលបានធានាការផ្គត់ផ្គង់ហិរញ្ញវត្ថុនៅក្នុងដំណើរការនេះ ។

លោក ពេជ្រ អង្គ បានសំណូមពរសវនាការអនុញ្ញាតឲ្យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញពីវីដេអូ និងកម្រោងឯកសារក្នុងពេលធ្វើបទបង្ហាញ ។ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានអនុញ្ញាត ប៉ុន្តែអនុញ្ញាតទៅលើអ្វី ដែលធ្លាប់ដាក់មុនសវនាការ ។

## ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង

លោកមេធាវី បានថ្លែងអំពីគោលដៅរបស់សហករណ៍ គឺចង់ផ្តល់អាហារសម្រាប់ការចំណាយខាងក្នុងផង និងការនាំចេញ ។ គោលដៅនេះត្រូវបានសម្រេចយ៉ាងលឿនក្នុងការប្រមូលផលទៅតាមគោលការណ៍៣តោនក្នុងមួយហិកតា ពង្រីកប្រព័ន្ធធារាសាស្ត្រក្នុងប្រទេស និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដូចជា អាកាសយានដ្ឋាន និងអាងទឹក ។ នេះគឺជាសម្អាងហេតុដែលថា គោលបំណងនៃសហករណ៍នេះធ្វើឡើងជាគោលនយោបាយនៃការស្វែងរកការពារប្រឆាំង និងកម្ទេចសត្រូវ ដើម្បីបំបាត់ឯកជនភាពដោយកម្ទេចរចនាបទសង្គម និងជំនួសទៅវិញដោយរបបសមូហភាព និងមិនអនុញ្ញាតឲ្យមាន ប្រយោជន៍ឯកត្តជន ។

លោក ពេជ្រ អង្គ បានពន្យល់ទីមួយ តុលាការត្រូវការការអះអាងថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិកើតមានឡើងនៅការដ្ឋានការងារ និងសហករណ៍ ។ ទីពីរ តុលាការត្រូវការអះអាងថាជនជាប់ចោទអាចត្រូវបានទទួលខុសត្រូវនូវបទឧក្រិដ្ឋកម្មទាំងនោះ ។ គោលបំណងបទបង្ហាញថ្ងៃនេះគឺបង្ហាញអំពីភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវជាជំនួយទៅលើធាតុផ្សំនៃបទឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ ជាពិសេសទៅលើការធ្វើឲ្យទៅជា ទាសករ ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញនយោបាយ ។

លោកមេធាវីបានថ្លែងអំពីភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

វេណីដែលទាក់ទងនឹងទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង ។ ដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់ពីស្ថានភាពដូចជា ការធ្វើការងារហួសកម្លាំង ការកំណត់ទិន្នផលខ្ពស់ កង្វះម្ហូបអាហារ និងកង្វះការថែទាំសុខភាព និងអនាម័យ ។ សក្ខីកម្មរបស់ពួកគេ គឺទាក់ទងទៅនឹងបទឧក្រិដ្ឋកម្មនៃការធ្វើឲ្យទៅជាទាសករ អំពើអមនុស្សធម៌ផ្សេងៗ អំពើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញមកលើ «ប្រជាជន១៧មេសា» ។ សក្ខីកម្មជាច្រើនរបស់ពួកគេបានក្តោបរួមអំពីស្ថានភាពរស់នៅ និងការងាររបស់ពួកគេ ។

លោក ពេជ្រ អង្គ បានថ្លែងថា ការដ្ឋានការងារនីមួយៗមានលក្ខណៈខុសគ្នា ឧទាហរណ៍ នៅទំនប់ត្រពាំងថ្ម ប្រជាជនម្នាក់ៗ បានរៀបរាប់ថាត្រូវបានដាក់ឲ្យធ្វើការងារក្នុងកងចំនួន១០០នាក់ ហើយការគ្រប់គ្រងត្រូវបានប្រើទៅលើពួកគេ ។ នៅទំនប់១មករា ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗបានរៀបរាប់អំពីស្ថានភាពការរស់នៅ និងកង្វះអនាម័យនៅការដ្ឋានការងារដែលមាន៣ផ្នែក ។ នៅព្រលានយន្តហោះកំពង់ឆ្នាំង ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីធ្វើការទាំងគ្មានកម្លាំងដែលនៅក្រោម «ការបញ្ជាទាំងស្រុង» ។

ចំពោះទំនប់ត្រពាំងថ្ម ដើមបណ្តឹងរដ្ឋប្បវេណី ១០១នាក់ត្រូវបានដាក់ឲ្យទទួលទោសទៅតាមបទល្មើសដែលខ្លួនបានប្រព្រឹត្តនៅទីនោះ ។ ក្នុងនោះ ដើមបណ្តឹងរដ្ឋប្បវេណី៤នាក់ បានផ្តល់សក្ខីកម្មទៅលើបទឧក្រិដ្ឋកម្មនៃការដាក់ឲ្យទៅជាទាសករ អំពើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយមកលើ «ប្រជាជនថ្មី» នៅការដ្ឋានការងារ ។ លោកមេធាវី បានកត់សម្គាល់ថា តុលាការនឹងត្រូវតែសម្រេចលើស្ថានភាពនៅទំនប់ត្រពាំងថ្ម ប្រសិនបើទីនោះមានបទដ្ឋានសម្រាប់ការធ្វើឲ្យទៅជាទាសករ និងត្រូវបញ្ចូលជាបទវិភាគនៃការគ្រប់គ្រង សេចក្តីថ្លៃងការណ៍ គ្រួសារ និងការបង្ខំឲ្យទទួលទោស ។

លោក ពេជ្រ អង្គ បានលើកឡើងថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើទំនប់ត្រពាំងថ្ម បានរួមនឹងការលើកឡើងនៃការលំបាកជីវិតប្រចាំថ្ងៃ និងការសម្រេចចំនួនកំណត់ ការប្រជុំដោយថ្នាក់លើ និងការរើសអើងប្រឆាំងនឹង «ប្រជាជនថ្មី» ដោយ «ប្រជាជនមូលដ្ឋាន» ។

លោកមេធាវីបានឲ្យដឹងថា នៅទំនប់១មករា ដើមបណ្តឹងរដ្ឋប្បវេណី៤៧នាក់ ត្រូវបានឲ្យទទួលទោសទៅតាមបទល្មើសដែលខ្លួនបានប្រព្រឹត្តនៅទីនោះ ។ ក្នុងនោះ ដើមបណ្តឹងរដ្ឋប្បវេណី៥នាក់ បានផ្តល់សក្ខីកម្មទៅលើការធ្វើឲ្យជាទាសករ អំពើអមនុស្សធម៌ផ្សេងៗ អំពើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញមកលើ «ប្រជាជនថ្មី» នៅការដ្ឋានការងារ ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មទៅលើស្ថានភាពនៅទំនប់១មករា គឺមានស្ត្រីទាំងអស់ ។ សេចក្តីរាយការណ៍របស់ពួកគេ គឺរួមជាមួយនឹងសេចក្តីអធិប្បាយដែលទាក់ទងអំពីការរើសអើងរបស់ «ប្រជាជនមូលដ្ឋាន» ប្រឆាំងនឹង «ប្រជាជនថ្មី» កង្វះស្បៀងភាព ថ្នាំ និងអនាម័យ ជាពិសេសការរងទុក្ខរបស់ស្ត្រី ដូចជាមិនបានទទួលអាវក្នុង ខោក្នុង ឬក៏ផលិតផលអនាម័យរបស់ស្ត្រីដែលជាជំនួយសម្រាប់ដំណើររដូវ ។ ការគ្រប់គ្រងកម្មករដោយហៅទៅអប់រំម្តងជាពីរដងការកម្រិតនៃការនិយាយទៅនរណាម្នាក់ ទោះបីជាបងប្អូនបង្កើត និងការភ័យខ្លាចក្នុងការសម្តែងភាពសោយស្តាយ ដែលសមាជិកគ្រួសារត្រូវបានសម្លាប់ ។

ដើមបណ្តឹងរដ្ឋប្បវេណី១១រូប ត្រូវបានឲ្យទទួលទោសទៅតាមបទល្មើសដែលខ្លួនបានប្រព្រឹត្តនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ។ ក្នុងនោះ មាន៣នាក់ បានផ្តល់សក្ខីកម្មទៅលើការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗ ។ សេចក្តីរាយការណ៍របស់ពួកគេ គឺរួមជាមួយនឹងសេចក្តីអធិប្បាយទៅលើការកម្រិតពេលវេលា និងទំនាក់ទំនងជាមួយអ្នកដទៃ វិន័យតឹងតែង និងការដែលជំរុញឲ្យរាយការណ៍ពីគ្នាទៅវិញទៅមក ។

លោក ពេជ្រ អង្គ បានកត់សម្គាល់ថា នៅក្នុងសវនាការដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសាកសួរសំណួរអំពីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី៥១រូបផ្សេងទៀត បានសួរសំណួរទៅជនជាប់ចោទតាមរយៈអង្គចៅក្រម ។ (ជនជាប់ចោទបានអនុវត្តសិទ្ធិស្ងៀមនៅ ស្ងៀមមិនឆ្លើយតប) ។

បន្ទាប់មក លោក ពេជ្រ អង្គ បានផ្ទេរវេទិកាបន្តទៅសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចេត វ៉ាន់លី

**សហករណ៍ត្រាំកក់**

លោកស្រី ចេត វ៉ាន់លី បានថ្លែងថា បន្ទាប់ពីការជម្លៀសដោយបង្ខំពីទីក្រុងនៅខែមេសា ឆ្នាំ១៩៧៥ ប្រជាជនខ្មែរត្រូវបានបញ្ជូនទៅធ្វើការនៅជនបទដែលត្រូវគេចាត់ឲ្យនៅក្នុងសហករណ៍ដោយបែងចែកទៅតាមកន្លែង ធ្វើការ និងទៅតាមអាយុ ឋានៈ និងអតីតការងារ ។ ប្រជាជនទាំងអស់ត្រូវតែអនុវត្តតាមគោលការណ៍របស់អង្គការ ហើយជាលទ្ធផលនៃគោលការណ៍បានធ្វើឲ្យប្រជាជនខ្មែររាប់លាននាក់ក្លាយទៅជាទាសករ និងការធ្វើការដោយបង្ខំ ។ ការរងទុក្ខនោះធ្វើឲ្យពួកគេឈឺចាប់រហូតដល់សព្វថ្ងៃ ។

លោកស្រីបានថ្លែងថា បទឧក្រិដ្ឋកម្មនៅរបបខ្មែរក្រហមមិនមែនគ្រាន់តែកើតឡើងនោះទេ គឺពួកគេត្រូវបានឲ្យប្រព្រឹត្តជាផ្នែកមួយនៃគម្រោងការទាំងមូល ដោយក្នុងនោះមាន លោក នួន ជា និង លោក ខៀវ សំផន ។

លោកស្រី វ៉ាន់លី បានរម្លឹកអំពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសហករណ៍ត្រាំកក់ ដែលមាន៧៧ឃុំ ។ ក្នុងខណៈដែលប្រជាជនរស់នៅទីនោះ ពួកគេត្រូវជាកម្មវត្ថុក្នុងការចាប់ខ្លួន និងឃុំឃាំង ។ នេះរួមមានស្ថានភាពនៃការធ្វើការ និងការរស់នៅរបស់ប្រជាជនដែល ត្រូវបានបញ្ជូលទៅទីនោះ ការសម្គាល់ថា ជាសត្រូវ ការអប់រំ និងការចាប់ខ្លួន ឬបាត់ខ្លួនដោយបទល្មើសផ្សេងៗ ។ ដើមបណ្តឹងរដ្ឋប្បវេណី៥២រូប ត្រូវបានទទួលទោសដែលទាក់ទងពីបទល្មើសដែលខ្លួនប្រព្រឹត្តនៅសហករណ៍ត្រាំកក់ ក្នុងនេះមាន១១រូបបានផ្តល់សក្ខីកម្ម ។

ដើមបណ្តឹងរដ្ឋប្បវេណី៣រូបបានផ្តល់ភស្តុតាងដែលភ្ជាប់នឹងជនជាប់ចោទ និងសហករណ៍ត្រាំកក់ ។ ពួកក៏គេបានរៀបរាប់ពីការបាត់បង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួននៅពេលបញ្ជូនទៅសហករណ៍ ការបរិភោគ និងសម្រាករួម និងការសម្លាប់សមាជិកគ្រួសាររបស់ពួកគេ ។ ដើមបណ្តឹងរដ្ឋប្បវេណី៥រូប បានផ្តល់សក្ខីកម្មអំពីស្ថានភាពធ្វើការ និងរស់នៅដែលពួកគេ បានដកពិសោធន៍ និងផលអាក្រក់ដែលពួកគេរងទុក្ខកាលពីវ័យកុមារភាព និងជិទង់ក្នុងរបបនោះ ។ ដើមបណ្តឹងរដ្ឋប្បវេណី ២រូបបានផ្តល់សក្ខីកម្មអំពីការបញ្ជូនរបស់ពួកគេទៅ ត្រាំកក់ និងម៉ោងធ្វើការដោយមិនមានអាហារ និងថ្នាំគ្រប់គ្រាន់ ។ ដើមបណ្តឹងរដ្ឋប្បវេណី ១រូប បានរៀបរាប់ពីការចាប់ខ្លួន និងការឃុំឃាំងរបស់គាត់ ។ ដើមបណ្តឹងរដ្ឋប្បវេណី ១រូបទៀត បានផ្តល់សក្ខីកម្មអំពីការប្រព្រឹត្តអំពើឃោរឃៅ និងការរំលោភបំពានដែលគាត់បានស៊ូទ្រាំ ។

លោកស្រី វ៉ាន់លី បានថ្លែងថាការប្រើប្រាស់អំណាចខុសនៅត្រាំកក់ដែលបណ្តាលឲ្យទៅជាបទឧក្រិដ្ឋកម្មនៃការធ្វើអោយទៅជាទាសករ និងបទល្មើសផ្សេងៗទៀតដែលកើតឡើង នៅទីនោះ ។ ដើម្បីស្វែងរកការធ្វើឲ្យទៅជាទាសករនៅទីនោះ អង្គជំនុំជម្រះត្រូវការចង្អុល បង្ហាញពីចរិតលក្ខណៈបទដ្ឋាននៃការគ្រប់គ្រងដែលបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តទៅលើប្រជាជនទាំងមូល ថែមទាំងរួមជាមួយ បញ្ញាចិត្តសាស្រ្ត ដូចជា ជំរុញបរិយាកាសភ័យខ្លាច គ្រប់គ្រងការងារលើសកម្លាំង និងគ្រប់គ្រងការនិយាយជីវិត និង ផ្លូវភេទ ។ លោកស្រី បានថ្លែងថាបរិយាកាសភ័យខ្លាចរត្រូវបានបង្កើតឡើងដោយការប្រើប្រាស់នៃការអប់រំ ការគ្រប់គ្រងលើប្រជាជនថ្មី ដោយប្រជាជនមូលដ្ឋាន និងការដាក់ទោសសម្រាប់គម្លាតពីរចនាសម្ព័ន្ធដែលបានកំណត់ ។

លោកស្រី វ៉ាន់លី បានសម្គាល់ថា អង្គជំនុំជម្រះត្រូវការកំណត់ប្រសិនបើមានការថែទាំ សុខភាពមិនគ្រប់គ្រង កង្វះអាហារ និងសុខទុក្ខ និងទម្រង់រស់នៅលំបាកដែលនាំទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗ ។ ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញពីថ្នាំដែលមានគុណភាពមិនល្អត្រូវបានប្រើពីរជងដោយគ្រូពេទ្យគ្មានវិជ្ជាជីវៈ ដែលជាលទ្ធផលធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីពិការ និងស្លាប់កូនស្រីរបស់ដើមបណ្តឹង រដ្ឋប្បវេណីដែលមានអាយុ៣ឆ្នាំ ។ **(តទៅលេខក្រោយ)** **រ៉ូនិត អារី**

**អានទស្សនាវដ្តីតាមគេហទំព័រ**

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៏មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ការស្ដារឡើងវិញនូវសម្បត្តិវប្បធម៌ និង សហគមន៍ចាមបន្ទាប់ពីជម្លោះ

ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ ក្នុងអំឡុងពេលនៃជម្លោះត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មអន្តរជាតិ ។ នៅក្នុងបរិបទនេះ “ទ្រព្យសម្បត្តិវប្បធម៌រួមបញ្ចូល ដី អគារ បូជនីយដ្ឋាន សិល្បៈ និងវត្ថុផ្សេងៗទៀត” ដែលមានសារសំខាន់បំផុតសម្រាប់បេតិកភណ្ឌវប្បធម៌របស់មនុស្សគ្រប់រូប ។ ច្បាប់អន្តរជាតិថែមទាំងការពារនៅអ្វីដែលជាវត្ថុអរូបី ដូចជាភាសា ការសម្ដែង និងការប្រណិប័តន៍សាសនា ។ ទាំងអស់នេះត្រូវបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិដែលមានការចាប់អារម្មណ៍នៅក្នុងការធានាថា ទីកន្លែង និងអ្វីដែលមានសារសំខាន់ខាងផ្នែកវប្បធម៌ត្រូវបានការពារ និងអភិរក្សពីជំនាន់មួយទៅជំនាន់មួយ ។ ទោះជាយ៉ាងណាក៏ដោយវាច្បាស់ណាស់ថា សហគមន៍ត្រូវបានរងផលប៉ះពាល់ដោយផ្ទាល់ពីការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌របស់សហគមន៍ ។ ការវាយប្រហារទៅលើសម្បត្តិវប្បធម៌មានន័យថា ជាការវាយប្រហារលើប្រវត្តិសាស្ត្ររបស់សហគមន៍សកម្មភាពវប្បធម៌ សាសនា និងអត្តសញ្ញាណ ។ ភាពសឹករិចរឹលឬការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ អាចជាវិធីមួយដើម្បីលុបបំបាត់ភាពទីទៃពីគ្នា និងភាពខុសគ្នា ។


ជនជាតិចាមនៅឃុំអូរបុស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កំពុងប្រារព្ធពិធីបុណ្យម៉ាឡុត

តើយើងគួរយល់ដឹង និងពន្យល់ពីបុព្វហេតុដែលបង្កផលប៉ះពាល់ដល់សហគមន៍ដោយការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌របស់ខ្លួនយ៉ាងដូចម្ដេច? តើគួរមានច្បាប់ណាមួយដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ដែលបង្កឡើង? សំណួរទាំងនេះគឺជាមូលដ្ឋានរបស់គម្រោងការស្រាវជ្រាវថ្មីមួយដែលបច្ចុប្បន្នកំពុងប្រព្រឹត្តទៅរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមអ្នកស្រាវជ្រាវមកពីសកលវិទ្យាល័យឃ្វីន *(Queen)* នៃទីក្រុងបែលហ្វាស់ ប្រទេសអៀកឡង់ខាងជើង និងសាកលវិទ្យាល័យខេមប្រ៊ីជ **(Cambridge)** ។

គម្រោង “ការស្ដារឡើងវិញនៅសម្បត្តិវប្បធម៌ និងសហគមន៍ បន្ទាប់ពីមានជម្លោះ “បានទទួលជំនួយឧបត្ថម្ភពីមូលនិធិអភិវឌ្ឍរបស់ក្រុមប្រឹក្សាស្រាវជ្រាវនៃចក្រភពអង់គ្លេស ដែលសហការជាមួយគម្រោងស្ដីពីជម្លោះ ឧក្រិដ្ឋកម្ម និងសន្តិសុខ ។ គម្រោងនេះផ្ដោតទៅលើបទពិសោធន៍របស់ក្រុមជនជាតិភាគតិចចាមក្នុងអំឡុងរបបខ្មែរក្រហម ។ គម្រោងនេះស្វែងយល់អំពីផលប៉ះពាល់ដល់ទ្រព្យសម្បត្តិវប្បធម៌ និងបេតិកភណ្ឌវប្បធម៌របស់សហគមន៍ និងដើម្បីរៀនសូត្រអំពីទស្សនៈរបស់សហគមន៍អំពីថាតើបាន

ឆ្លើយតបដោយបៀបណាទៅនឹងការខូចខាតទាំងនេះ ។ ការកាត់ទោសនៃបទឧក្រិដ្ឋទាំងនេះដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិចាមនៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលតុលាការនេះមានភារកិច្ចកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបខ្មែរក្រហម អនុញ្ញាតឲ្យយើងស្វែងរកភាពសមល្មមនៃសំណងដែលសម្រេចដោយតុលាការ និងថាតើវិធានការណ៍ណាមួយបន្ថែមទៀតដែលចាំបាច់ ។ រយៈពេលជាងពីរសប្តាហ៍នៅក្នុងខែមីនា ឆ្នាំ២០១៧ ក្រុមការងារបានធ្វើដំណើរទៅកាន់សហគមន៍ចាមមួយចំនួននៅក្នុងប្រទេសកម្ពុជា ។ យើងបានធ្វើការសម្ភាសជាមួយក្រុមគោលដៅ ដែលមានសមាជិកចំនួន៧៥នាក់ នៅក្នុងសហគមន៍ចាមនៅក្នុងរាជធានីភ្នំពេញ និងបណ្តាខេត្តមួយចំនួនដូចជា ខេត្តកណ្តាល កំពង់ឆ្នាំង និងខេត្តកំពង់ចាម ។ យើងបាននិយាយទៅកាន់មនុស្សជាច្រើនក្រុមនៅក្នុងសហគមន៍ចាម ដើម្បីស្វែងយល់អំពីអត្តសញ្ញាណចាម ប្រវត្តិសាស្ត្រ និងការប្រណិប័តន៍វប្បធម៌សាសនា ។ យើងបានទស្សនាវិហារចាម និងសាលារៀនសាសនាមួយចំនួន ព្រមទាំងជួបជាមួយមេដឹកនាំសាសនា និងសហគមន៍ ។ យើងក៏បានធ្វើការសម្ភាសជាមួយស្ត្រី និងយុវជន ។ លើសពីនេះទៀត យើងបានជួបសម្ភាសជាមួយអង្គការមូស្លីមមេធាវីមួយ និងអ្នកច្បាប់មួយចំនួនដែលធ្វើការទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ។ យើងសូមសម្តែងនូវការដឹងគុណជាខ្លាំងចំពោះសហគមន៍ដែលយើងបានទៅទស្សនា សម្រាប់ការទទួលរាក់ទាក់របស់ពួកគាត់ ក្នុងការផ្តល់បទសម្ភាស និងចំណាយពេលវេលាសម្រាប់ក្រុមការងារ ។

ប្រជាជនចាមគឺជាជនជាតិភាគតិចមួយក្រុម ដែលមានពូជពង្ស និងរាជាណាចក្រចម្ប៉ា (នៅ គ.សទី១៩២-១៨៣២) ។ ជនជាតិចាមបានរស់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីសតវត្សរ៍ទី១៥ ហើយនាពេលបច្ចុប្បន្ននេះ ជនជាតិចាមមានជាង៥សែននាក់ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ។ ជនជាតិចាមភាគច្រើនគឺជាសាសនិកអ៊ីស្លាម បើទោះជាជនជាតិចាមប្រតិបត្តិជំនឿសាសនារបស់ខ្លួនខុសប្លែកគ្នាពីសហគមន៍មួយទៅសហគមន៍មួយក៏ដោយ ។ ជនជាតិចាមភាគច្រើនចូលចិត្តរស់នៅជាក្រុមៗដាច់ដោយឡែកពីអ្នកជិតខាងរបស់ខ្លួនដែលជាអ្នកកាន់ព្រះពុទ្ធសាសនា ។ ខណៈដែលជនជាតិចាមភាគច្រើនរស់នៅតាមបណ្តោយដងទន្លេមេគង្គ ជនជាតិចាមមួយចំនួនអាចត្រូវបានប្រទះឃើញនៅក្នុងបណ្តាខេត្តមួយចំនួននៅទូទាំងប្រទេសកម្ពុជា ។ ជនជាតិចាមជាញឹកញាប់ស្លៀកសម្លៀកបំពាក់ប្រពៃណីអ៊ីស្លាម និងនិយាយភាសាផ្ទាល់របស់ខ្លួនគឺភាសាចាម ទោះបីជាជនជាតិចាមមួយចំនួននិយាយភាសាខ្មែរ ហើយនៅក្នុងករណីមួយចំនួនទៀត និយាយភាសាអង់គ្លេស ឬភាសាអារ៉ាប់ក៏ដោយ ។ ទោះបីជាមានភស្តុតាងខ្លះៗបង្ហាញពីការរើសអើងប្រឆាំងនឹងជនជាតិចាមនៅក្នុងប្រទេសកម្ពុជាមុនរបបខ្មែរក្រហមក៏ដោយ ទម្រង់នៃការរើសអើងដែលផ្តោតលើជនជាតិចាម និងបេតិកភណ្ឌវប្បធម៌បានស្តែងឡើងយ៉ាងច្បាស់ក្នុងអំឡុងពេលរបបខ្មែរក្រហម ។

ក្នុងអំឡុងរបបខ្មែរក្រហម ការប្រណិប័តន៍សាសនា និងវប្បធម៌ត្រូវបានហាមឃាត់ដោយរបបនេះ ។ ការហាមឃាត់នេះមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើសហគមន៍ចាម ដែលមិនអាចនិយាយភាសារបស់ខ្លួន ស្លៀកសម្លៀកបំពាក់ប្រពៃណី ប្រណិប័តន៍សាសនា ឬសូម្បីតែប្រើឈ្មោះចាមរបស់ខ្លួន ។ តាមរយៈគោលនយោបាយរបស់ខ្មែរក្រហមនៃការជម្លៀសដោយបង្ខំ ខ្មែរក្រហមបានបំបែកសហគមន៍ចាម ដោយផ្លាស់ប្តូររបៀបរស់នៅជាក្រុមតាមប្រពៃណីរបស់ជនជាតិចាម ។ របបនេះបានកំណត់គោលដៅសម្បត្តិវប្បធម៌របស់ចាម ដោយធ្វើការរឹបអូស និងបំផ្លាញធាតុផ្សំផ្សេងៗដូចជាសៀវភៅសាសនា សម្លៀកបំពាក់ប្រពៃណី និងសម្លៀកបំពាក់ថ្វាយបង្គំព្រះ ។ វិហារអ៊ីស្លាមត្រូវបានបិទ កម្ទេចចោល ឬប្រើសម្រាប់គោលបំណងផ្សេងទៀត ដូចជាកន្លែងបរិភោគអាហារឃ្លាំងដាក់អង្ករ ឬជាកន្លែងចិញ្ចឹមសត្វជ្រូក ។ សហគមន៍ចាមត្រូវបានបង្ខំអោយធ្វើរឿងជាច្រើនផ្សេងៗទៀត ដែលជាការប្រឆាំងទៅនឹងវប្បធម៌ និងជំនឿរបស់ខ្លួន ។ ឧទាហរណ៍ជនជាតិចាមត្រូវបានបង្ខំឲ្យបរិភោគសាច់ជ្រូក និងស្ត្រីត្រូវបានបង្ខំឲ្យកាត់សក់ខ្លី ដែលជាទង្វើមួយដែលរំលោភបំពាននឹងវប្បធម៌សាសនា ដោយសារវប្បធម៌ចាមឲ្យតម្លៃលើសក់ ដោយសារវាជានិមិត្តរូបនៃសីលធម៌ ។

ជនជាតិចាមជាច្រើនបានតស៊ូប្រឆាំងនឹងការប៉ុនប៉ងរបស់

ខ្មែរក្រហមក្នុងការលុបបំបាត់វប្បធម៌ និងសាសនារបស់ខ្លួន ។ ឪពុកម្តាយព្យាយាមដាក់ឈ្មោះចាមឲ្យកូនរបស់ខ្លួន សូត្រធម៌តិចៗដាក់ត្រចៀកកូនរបស់ខ្លួន និងបង្រៀនកូនៗអំពីវប្បធម៌ និងសាសនារបស់ខ្លួនជាសម្ងាត់ ។ ជនជាតិចាមមួយចំនួនបានបន្តការថ្វាយបង្គំរបស់ខ្លួនជាសម្ងាត់ ហើយស្រ្តីបានប្រើក្រមាដែលខ្មែរក្រហមចែកឲ្យធ្វើជាកន្សែងជំនួស ។ ជនជាតិចាមមួយចំនួនទៀតធ្វើការតស៊ូប្រឆាំងនឹងរបបខ្មែរក្រហមដោយចំហ ហើយដែលគួរឲ្យកត់សម្គាល់បំផុតគឺតាមរយៈការបះបោរមួយចំនួនដែលបានកើតឡើងនៅដើមឆ្នាំនៃរបបខ្មែរក្រហម ។ ឧទាហរណ៍ ការតស៊ូប្រឆាំងនឹងខ្មែរក្រហមនៅក្នុងភូមិទ្រាក្នុងឆ្នាំ១៩៧៣ និងនៅភូមិកោះផលនិងភូមិស្វាយឃ្លាំងក្នុងឆ្នាំ១៩៧៥ ។ ការបះបោរទាំងនេះត្រូវបានបង្ក្រាបដោយហិង្សាដោយរបបខ្មែរក្រហម ។ ចាប់ពីឆ្នាំ១៩៧៧ គោលនយោបាយខ្មែរក្រហមទៅលើជនជាតិចាម បានផ្លាស់ប្តូរយ៉ាងខ្លាំង ដោយគោលនយោបាយនេះមានបំណងលុបបំបាត់សមាជិកក្រុម ។ តាមរយៈការស្រាវជ្រាវមួយចំនួនបានឲ្យដឹងថា ជនជាតិចាមប្រហែល៣៦ភាគរយបានស្លាប់ក្នុងរបបនោះ ។ មេដឹកនាំសាសនា និងគ្រូបង្រៀនសាសនាត្រូវបានកំណត់គោលដៅពិសេសពីព្រោះអ្នកទាំងនេះជាមនុស្សមានចំណេះដឹង ដែលអាចការពារថែរក្សា និងអនុវត្តវប្បធម៌ និងសាសនារបស់ខ្លួន ។

ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិចាមស្តែងឲ្យឃើញនៅក្នុងសំណុំរឿង០០២វគ្គ០២ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជនជាប់ចោទចំនួនពីររូបនៅក្នុងសំណុំរឿង០០២វគ្គ០២ គឺ នួន ជា និង ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញខាងសាសនារបស់ជនជាតិចាម ។ តុលាការបានទទួលស្គាល់នូវការដៅចំពោះទ្រព្យសម្បត្តិវប្បធម៌ចាម និងបេតិកភណ្ឌរបស់ជនជាតិចាមនៅក្នុងបទចោទទាំងពីរ ។ នៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍ការកំណត់គោលដៅនៃវប្បធម៌ ប្រពៃណី និងភាសាចាម ត្រូវបានប្រើដើម្បីបង្ហាញចេតនាដូវចិត្តដាក់លាក់មួយ ដែលត្រូវបានទាមទារឲ្យមាន ដើម្បីបង្ហាញអំពីការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែលមានការប៉ុនប៉ងទុកជាមុន ។ នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តុលាការបានទទួលស្គាល់ការហាមឃាត់មិនឲ្យមានការប្រណិប័តន៍វប្បធម៌ ប្រពៃណី និងភាសាចាមនៅទូទាំង ។ សាលក្រមសម្រាប់សំណុំរឿង០០២វគ្គ២ត្រូវបានរំពឹងនឹងចេញនៅចុងឆ្នាំ២០១៧ ។

សេវាគាំពារជនរងគ្រោះ និងតំណាងផ្នែកច្បាប់ដល់ជនរងគ្រោះ បានយកចិត្តទុកដាក់ចំពោះបទពិសោធន៍របស់ជនជាតិចាមនៅក្នុងសំណើរបស់ពួកគាត់ចំពោះសំណង ។ គម្រោងដែលបានស្នើឡើង រួមបញ្ចូលទាំងខ្សែភាពយន្តឯកសារស្តីពីការបះបោរនៅភូមិស្វាយឃ្លាំង និងការតាំងពិព័រណ៍រូបថតចល័ត ព្រមទាំងការប្រមូលប្រវត្តិសាស្រ្តផ្ទាល់មាត់ ។ លើសពីនេះទៀត ដើម្បីទទួលបានសំណងជាក់លាក់ សហគមន៍ចាមអាចទទួលបានប្រយោជន៍ពីសំណើទូទៅបន្ថែមទៀត ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហានៅតែមានស្តីអំពីទំហំដែលគម្រោងទាំងនេះផ្តល់ឲ្យ ដើម្បីដោះស្រាយចំពោះការខូចខាតដល់សម្បត្តិវប្បធម៌របស់សហគមន៍ចាម ។ នៅក្នុងអំឡុងពេល៤០ឆ្នាំដែលបានកន្លងផុតទៅ សហគមន៍ចាមជាច្រើនដែលយើងបានទស្សនា បានកសាងឡើងវិញនូវវិហារអ៊ីស្លាម និងសហគមន៍របស់ខ្លួន ។ ប៉ុន្តែសហគមន៍ចាមនៅតែមានបំណងចង់បានសំណងដែលផ្តោតលើវិស័យអប់រំ ការទទួលស្គាល់ និងការលើកកម្ពស់ការយល់ដឹងខាងវប្បធម៌ ខណៈពេលដែលសហគមន៍ព្យាយាមងើបចេញពីការធ្វើទុកបុកម្នេញខាងវប្បធម៌ និងសាសនា ។

ក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ ក្រុមការងារគម្រោងនឹងវិភាគលទ្ធផលនៃកិច្ចសម្ភាស និងក្រុមគោលដៅរបស់យើង ។ អ្នកស្រាវជ្រាវនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីបង្កើតសំណើសម្រាប់គម្រោងមួយចំនួនដែលអាចជួយដល់សហគមន៍ ដើម្បីងើបឡើងវិញពីអន្តរាយ ដែលបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ និងបេតិកភ័ណ្ឌវប្បធម៌របស់ជនជាតិចាម ។

ក្រុមការងារសង្ឃឹមថា នឹងវិលត្រឡប់មកប្រទេសកម្ពុជានៅចុងឆ្នាំនេះ ដើម្បីបន្តការងាររបស់យើង ។ ប្រសិនបើអ្នកមានចំណាប់អារម្មណ៍នៅក្នុងការងារនេះឬគិតថា អ្នកមានព័ត៌មានដែលមានការពាក់ព័ន្ធទៅនឹងគម្រោង នេះសូមទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**គីឡៀន, រ៉ូប៊ីន ហិកគី និង លូក ម៉ូហ្វេត**

# ការពង្រឹងនីតិរដ្ឋតាមរយៈការអប់រំផ្នែកច្បាប់

កាលពីពេលថ្មីៗនេះ ខ្ញុំបានសម្ភាសន៍និស្សិតរៀនឆ្នាំទីបួន ចំនួនពីររូប ក្នុងចំណោមនិស្សិត១៥រូប មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងដំណើរទស្សនកិច្ចសិក្សានៅវាលពិឃាតបឹងជើងឯក ដែលជាកម្មវិធីមួយរបស់គម្រោងស្តីអំពីការចូលរួមរបស់ជនរងគ្រោះនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ កម្មវិធីនេះផ្តល់ឱកាសដល់សិស្សានុសិស្ស ព្រមទាំងនិស្សិតបានចូលរួមស្តាប់សវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ និងទស្សនាវាលពិឃាតបឹងជើងឯក ព្រមទាំងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលជាទីតាំងត្រូវបានតុលាការលើកយកជាភ័ស្តុតាងក្នុងការកាត់ទោស ឌុច អតីតប្រធានគុកទួលស្លែង នៅក្នុងរបបខ្មែរក្រហម ។ និស្សិតទាំងពីរនាក់នោះគឺ ម្នាក់ឈ្មោះ ម៉ា ដារីកា កំពុងសិក្សាផ្នែកទំនាក់ទំនងអន្តរជាតិ និងម្នាក់ទៀតឈ្មោះ ហាន់ មួយលីន កំពុងរៀនផ្នែកនីតិសាស្ត្រ ។

ខ្ញុំបានសួរសំណួរមួយចំនួនទៅកាន់ដារីកា និងមួយលីន អំពីចំណាប់អារម្មណ៍ដែលគាត់បានចូលរួមដំណើរទស្សនកិច្ចនេះជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដារីកា និងមួយលីន បានលើកឡើងស្រដៀងគ្នាថា អ្នកទាំងពីរចូលរួមនៅក្នុងកម្មវិធីទស្សនកិច្ចសិក្សានេះជាលើកទីមួយ ។ កម្មវិធីដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំឡើង មានសារប្រយោជន៍សម្រាប់សិស្ស និស្សិតក្នុងការស្វែងយល់អំពីដំណើរកាត់ទោសនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលត្រូវបានបង្កើតឡើងរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។

មិនតែប៉ុណ្ណោះ ដារីកា និងមួយលីន យល់ឃើញថានិស្សិតដែលចូលរួមកម្មវិធីនេះ មិនត្រឹមតែបានស្តាប់សវនាការដោយផ្ទាល់នោះទេ ថែមទាំងបានជួបពិភាក្សាជាមួយ លោក នេត្រ ភក្ត្រា



និស្សិតមកពីសាកលវិទ្យាល័យនីតិសាស្ត្រកំពុងស្តាប់អ្នកនាង សិរិ សាវីណា ប្រធានគម្រោងអប់រំ និងផ្សព្វផ្សាយពីរបបខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និយាយពីរឿងរ៉ាវរបស់អ្នកទោសនៅទួលស្លែង

ដែលជាមន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម អំពីការអភិវឌ្ឍន៍របស់តុលាការ ការអនុវត្តការងារនៅក្នុងតុលាការ របនាសម្ព័ន្ធ និងអង្គភាពនានារបស់តុលាការ ព្រមទាំងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងជាដើម ។

ដារីកា រំឭកថា នៅក្នុងបន្ទប់សវនាការនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលខ្លួនបានចូលស្តាប់ ដារីកា ចាប់អារម្មណ៍ទៅលើការលើកឡើងរបស់មេធាវីការពារមេដឹកនាំខ្មែរក្រហមទាំងខ្មែរ និងបរទេស ដែលបានលើកឡើងនូវទឡ្ហីករណ៍ផ្សេងៗ ដើម្បីដោះបន្ទុកកូនក្តីរបស់គាត់ឲ្យរួចផុតពីការចោទប្រកាន់ ។ ចំណែកឯ មួយលីន ចាប់អារម្មណ៍ថា ជាទូទៅមេធាវីការពារជនជាប់ចោទជួបប្រទះឧបសគ្គច្រើនក្នុងការការពារកូនក្តី ។ ប៉ុន្តែ មេធាវីការពារក្តីរបស់ នួន ជា ហាក់ដូចជា មានភាពវៃឆ្លាតក្នុងការរិះរកវិធីសាស្ត្របន្ធូរបន្ថយទម្ងន់ទោសរបស់កូនក្តី ។ បើទោះបីជាយ៉ាងណាក៏ ដោយ និស្សិតទាំងពីរជឿជាក់ថា មានតែចៅក្រមទេដែលអាចវិនិច្ឆ័យអំពីទោសកំហុសពិតប្រាកដរបស់មេដឹកនាំខ្មែរក្រហម ដើម្បីរកយុត្តិធម៌ជូនប្រជាជន និងជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ។ ទន្ទឹមនឹងនេះ មួយលីន ក៏បានទទួលបទពិសោធន៍បន្ថែមអំពីនីតិវិធីនៅក្នុងសវនាការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទាក់ទងនឹងសវនាការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២ វគ្គ២ ។

ចំណែក ដារីកា បានទទួលនូវបទពិសោធន៍ថ្មីទាក់ទងនឹងវិធីសាស្ត្រនៃការលើកឡើងរបស់មេធាវីការពារក្តីជនជាប់ចោទអំពីបទចោទប្រកាន់ទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ។

នៅខណៈនោះ ផន ប៊ុនថេង ដែលជានិស្សិតឆ្នាំទីបួនផ្នែកច្បាប់ដែលបានចូលរួមស្តាប់ការសម្ភាសរបស់ខ្ញុំជាមួយ ដារីកា និង មួយលីន បានបង្ហាញអំពីចំណាប់អារម្មណ៍របស់ខ្លួនក្នុងការចូលរួមកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា នេះគឺជាលើកដំបូងដែលខ្លួនបានចូលរួមស្តាប់សវនាការនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ការចូលរួមនេះបានផ្តល់ប្រយោជន៍ដល់និស្សិតច្បាប់ទាំងឡាយដែលមានបំណងចង់ឃើញការអនុវត្តច្បាប់ដោយផ្ទាល់ ដើម្បីយល់អំពីដំណើរការកាត់ក្តីនៅក្នុងតុលាការមួយដែលមានការចូលរួមពីភាគីជាតិ និងភាគីអន្តរជាតិ ។ លើសពីនេះទៅទៀត និស្សិតដែលបានចូលរួមកម្មវិធីនេះ ទទួលបានការយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈឯកសារ ដែលបានផ្តល់ឲ្យ និងតាមរយៈការធ្វើបទបង្ហាញរបស់វាគ្មិន ។

បន្ទាប់ពីបានស្តាប់មតិយោបល់របស់ប្អូនៗនិស្សិត ខ្ញុំសង្កេតឃើញថា ការចូលរួមស្តាប់សវនាការដោយផ្ទាល់នៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានផ្តល់ឱកាសដល់សិស្ស និស្សិតបានយល់ដឹងអំពីដំណើរការស្វែងរកយុត្តិធម៌ទាក់ទងនឹងឧក្រិដ្ឋកម្មកាលពីអតីតកាល ដែលបានរួមចំណែកដល់ការពង្រឹងនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា ។ និស្សិតទាំងបីយល់ស្របថា ការពង្រឹងនីតិរដ្ឋអាចសម្រេចបាន គឺអាស្រ័យទៅលើឆន្ទៈរបស់បុគ្គលគ្រប់រូប ។ ជាចុងបញ្ចប់ និស្សិតទាំងបីចង់ក្លាយជាអ្នកអនុវត្តផ្នែកច្បាប់ដែលជាគម្រូល្អមួយរូប ។ **ម៉ែន ពិចិត្រ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# ទស្សនកិច្ចសិក្សារបស់និស្សិតច្បាប់នៅសាលាក្តីខ្មែរក្រហម

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានបើកសវនាការលើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២ វគ្គ០២ ។ សវនាការនៃការធ្វើសេចក្តីសន្និដ្ឋាននេះ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៣ ដល់ទី២៣ ខែមិថុនា ឆ្នាំ២០១៧នេះ ។ ក្នុងអំឡុងពេលសវនាការ អង្គជំនុំជម្រះបានចែកជូនដល់ភាគីមានរយៈពេលផ្សេងៗគ្នា ក្នុងនោះដែរ ភាគីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេល១ថ្ងៃ (ថ្ងៃទី១៣), ភាគីសហព្រះរាជអាជ្ញា មានរយៈពេល២ថ្ងៃ (ថ្ងៃទី១៤ និង១៥), ភាគីមេធាវីការពារក្តី មានរយៈពេល៣ថ្ងៃកន្លះ (ថ្ងៃទី១៦,១៩,២០ និង២១), រសៀលថ្ងៃទី២១ និងព្រឹកថ្ងៃទី២២ ជាការធ្វើសេចក្តីសន្និដ្ឋានតបរបស់ភាគី ហើយនៅថ្ងៃទី២៣ គឺជាការធ្វើសេចក្តីសន្និដ្ឋានចុងក្រោយរបស់ជនជាប់ចោទ ដែលអង្គជំនុំជម្រះប្រគល់ពេលវេលាជូន៤ម៉ោង ក្នុងការធ្វើសេចក្តីសន្និដ្ឋាននេះ ។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ ជាថ្ងៃទីពីរ នៃការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ បិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២ វគ្គ០២ របស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ ។ ជាមួយគ្នានេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានរៀបចំនាំនិស្សិតសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចចំនួន១៥នាក់ (ភាគច្រើនមិនធ្លាប់ចូលរួមស្តាប់សវនាការពីមុនមក) ឲ្យមកចូលរួមស្តាប់សវនាការរយៈពេលមួយថ្ងៃដើម្បីស្វែងយល់ពីកិច្ចដំណើរការនីតិវិធីរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងដើម្បីយកចំណេះដឹងទាំងនេះទៅចែករំលែកជាមួយមិត្តភក្តិ ។ ប៉ុន្តែ មុននឹងចូលរួមស្តាប់សវនាការមុនមួយថ្ងៃ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានអញ្ជើញលោក នេត្រ ភក្ត្រា មន្ត្រីនាំពាក្យនៃសាលាក្តីខ្មែរក្រហម មកធ្វើបទបង្ហាញស្តីពីដំណើរការវិវត្តរបស់សាលាក្តីខ្មែរក្រហមដល់អ្នកដែលបានចូលរួមទាំងអស់ ដើម្បីជាការយល់ដឹងមុននឹងចូលរួមស្តាប់សវនាការផ្ទាល់ ។ ខាងក្រោមជាទស្សនៈយល់ឃើញរបស់និស្សិត បន្ទាប់ពីចូលរួមស្តាប់សវនាការៈ

◆ ប៊ុត ឌីណា ជានិស្សិតឆ្នាំទី១ ផ្នែកច្បាប់ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានឲ្យដឹងថា នេះជាលើកទី១ សម្រាប់ ឌីណា ដែលបានមកចូលរួមស្តាប់សវនាការនៃសាលាក្តីខ្មែរក្រហមនេះ ។ ពេលដែលចូលរួមស្តាប់ បានធ្វើឲ្យ ឌីណា មានការយល់ដឹងអំពីការប្រព្រឹត្តទៅនៃសវនាការដែលមានលក្ខណៈអន្តរជាតិ ដោយមានការចូលរួមពីភាគីអន្តរជាតិ និងខ្មែរ ក៏ដូចជាអាចឲ្យ ឌីណា ស្វែងយល់អំពីនីតិវិធីនៃតុលាការអន្តរជាតិដែរ ។

ឌីណា ធ្លាប់បានដឹងអំពីរបបខ្មែរក្រហមតាមរយៈឪពុកម្តាយនិយាយប្រាប់ ។ តាមអ្វីដែលយាយរបស់ ឌីណា បានប្រាប់ឲ្យដឹងថា ជីតារបស់ ឌីណា ត្រូវបានខ្មែរក្រហមយកទៅរៀនសូត្រ ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក ។ យាយរបស់ ឌីណា សន្មត់ថាតារបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ ដោយសារតែតារបស់ ឌីណា ជាអតីតប្រធានមន្ទីរកសិកម្មខេត្តតាកែវ នៃរបបលន់ នល់ ។

ឪពុកម្តាយរបស់ ឌីណា ក៏បានរម្លឹកពីក្តីលំបាកវេទនាទាំងឡាយដែលបានជួបប្រទះដល់ ឌីណា ។ បន្ទាប់ពីដំណើរទស្សនកិច្ចនេះ ឌីណា នឹងនាំយកនូវព័ត៌មានសំខាន់ៗ និងអ្វីដែលខ្លួនបានស្វែងយល់ក្នុងដំណើរទស្សនកិច្ចនេះទៅចែករំលែកដល់មិត្តរួមថ្នាក់ដែលមិនបានមកចូលរួម ។

ឌីណា ចង់ក្រើនរម្លឹកប្រាប់មិត្តរួមថ្នាក់ថា "យើងកុំគិតថាការចូលរួមស្តាប់សវនាការនេះជារឿងដែលខាតពេលវេលា សម្រាប់យើងជានិស្សិតច្បាប់ យើងគួរតែឆ្លៀតពេលទៅ ចូលរួមស្តាប់មើលនីតិវិធីតុលាការ ដែលជាលក្ខណៈអន្តរជាតិ ប្រព្រឹត្តទៅនៅស្រុកខ្មែរផ្ទាល់ ។ ឌីណា បន្តទៀតថា ក្នុងនាមយើងជានិស្សិត យើងគួរតែសិក្សាអំពីប្រវត្តិសាស្រ្តខ្លះ ព្រោះថាសម័យខ្មែរក្រហម សូម្បី

តែបរទេសក៏ចាប់អារម្មណ៍ បើគេសួរយើងពីសម័យនេះ ក្នុងនាមយើងជាជនជាតិខ្មែរ គួរណាស់តែដឹង កុំឲ្យបរទេសថា យើងមិនដឹងអ្វីសោះអំពីប្រវត្តិសាស្ត្ររបស់ខ្លួនមួយនេះ ។ ជាចុងក្រោយ ឌីណា ក៏មានបណ្ដាំផ្ញើទៅយុវជនទាំងអស់ មិនថាសិស្ស និស្សិត ឬប្រជាពលរដ្ឋខ្មែរ គួរតែយកចិត្តទុកដាក់ពីសម័យខ្មែរក្រហម ព្រោះថាសម័យខ្មែរក្រហម ជាប្រវត្តិសាស្ត្ររបស់យើងគ្រប់គ្នា ជាប្រវត្តិសាស្ត្រមួយដ៏ជូរចត់ ដែលយើងគួរតែចងចាំសម្រាប់កូនខ្មែរជំនាន់ក្រោយ ព្រោះថាក្មេងជំនាន់ក្រោយមិនសូវជាយល់ដឹងអំពីសម័យខ្មែរក្រហមប៉ុន្មានទេ ។

◆ ឃួ ដានីន ជានិស្សិតឆ្នាំទី២ ផ្នែកច្បាប់ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ នេះជាលើកទីមួយសម្រាប់ ដានីន ដែលបានមកចូលរួមស្ដាប់សវនាការនៃតុលាការខ្មែរក្រហម ប៉ុន្តែ ដានីន ធ្លាប់បានតាមដានស្ដាប់តាមវិទ្យុ និងទូរទស្សន៍ ។ បន្ទាប់ពីបានចូលរួមស្ដាប់សវនាការ ដានីន ទទួលបានបទពិសោធន៍ខ្លះៗ ទីមួយ អំពីដំណើរការនីតិវិធីនៃតុលាការអន្តរជាតិ ដែលមានភាគីអន្តរជាតិ និងជាតិ ។ ចំពោះរបបខ្មែរក្រហម ដានីន ធ្លាប់បានដឹងឮតាមរយៈឪពុកម្ដាយ ជីដូនជីតា ដែលតែងតែនិយាយប្រាប់អំពីអ្វីដែលគាត់ទាំងអស់គ្នាបានជួបប្រទះ និងឆ្លងកាត់ ។ ដានីន ពិតជាមានការសោកស្ដាយចំពោះអ្វីដែលបានកើតឡើងក្នុងសម័យនោះ ថ្វីត្បិតតែ ដានីន កើតមិនទាន់ក៏ពិតមែន ប៉ុន្តែដានីនដឹងតាមរយៈចាស់ទុំ និងការសិក្សាស្រាវជ្រាវនៅឯសាលា ។

ចំពោះ ដានីន បន្ទាប់ពីដំណើរទស្សនកិច្ចនេះ ដានីន នឹងផ្សព្វផ្សាយបន្តទៅកាន់គ្រួសារ ក៏ដូចជាមិត្តភក្តិអំពីបទពិសោធន៍ដែលខ្លួនបានសិក្សាស្វែងយល់ក្នុងថ្ងៃនេះ ។ ដានីន នឹងពន្យល់នូវអ្វីដែលខ្លួនបានដឹងមួយៗ ទៅកាន់អ្នកគ្រប់គ្នា ដើម្បីឲ្យអ្នកទាំងអស់ បានយល់អំពីកិច្ចដំណើរការនីតិវិធីនៃតុលាការខ្មែរក្រហម ។ ដានីន យល់ថាការដែលបានមកចូលរួមស្ដាប់សវនាការដោយផ្ទាល់ គឺធ្វើឲ្យខ្លួនមានការយល់ដឹងច្រើនជាង កាលដែលមិនបានចូលរួមស្ដាប់ដោយផ្ទាល់ ។

◆ ស៊ឹម ខួចសុភក្ត្រា ជានិស្សិតឆ្នាំទី៤ ផ្នែកច្បាប់ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានឲ្យដឹងថា នេះជាលើកទីពីរហើយដែលបានមកចូលរួមស្ដាប់សវនាការនៃតុលាការខ្មែរក្រហម ។ សម្រាប់ សុភក្ត្រា មុនដំបូងយល់ថាតុលាការមួយនេះចំណាយពេលយូរ លើសតុលាការធម្មតា ប៉ុន្តែបន្ទាប់ពីស្ដាប់ការធ្វើបទបង្ហាញរបស់មន្ត្រីសាលាក្ដីខ្មែរក្រហមមុនពេលចូលរួមស្ដាប់សវនាការ និងពេលចូលរួមស្ដាប់ដោយផ្ទាល់ សុភក្ត្រា យល់ថា កិច្ចដំណើរការនីតិវិធីយូរ ក៏ព្រោះតែមានជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណីច្រើនសាក្សីក៏ច្រើន និងត្រូវការប្រមូលភស្តុតាងច្រើន ។ សុភក្ត្រា បន្ថែមទៀតថា តុលាការនេះគួរឲ្យចាប់អារម្មណ៍ ព្រោះការកាត់ក្ដី និងដំណើរការនីមួយៗមានភាពច្បាស់លាស់ ។ សម្រាប់ សុភក្ត្រា តុលាការនេះ អាចនឹងផ្ដល់យុត្តិធម៌ ហើយក៏មិនផ្ដល់យុត្តិធម៌ពេញលេញទេ ក៏ព្រោះតែជនជាប់ចោទទាំងអស់មានវ័យចាស់ជរាណាស់ មកដល់ពេលនេះ សំណុំរឿង ០០២ ជនជាប់ចោទពីររូបបានស្លាប់រួចមកហើយ និងបើដំណើរការទៅមុខទៀត ជនជាប់ចោទផ្សេងទៀត អាចនឹងស្លាប់បន្តទៀត ។

អំពីរបបខ្មែរក្រហម សុភក្ត្រា ធ្លាប់បានដឹង និងឮតាមរយៈឪពុកម្ដាយ ចាស់ទុំនិយាយប្រាប់ ។ គ្រួសាររបស់ឪពុកម្ដាយរបស់ សុភក្ត្រា ភាគច្រើន គឺស្លាប់ដោយសារជំងឺ គ្មានថ្នាំព្យាបាល និងការអត់ឃ្លាន ហើយក៏មិនមាននរណាម្នាក់ត្រូវខ្មែរក្រហមយកទៅសម្លាប់ដែរ ។ សុភក្ត្រា បានឲ្យដឹងថា ទោះបីជាឪពុកម្ដាយតែងតែរម្លឹកអំពីរបបខ្មែរក្រហម ប្រាប់ដល់កូនៗ ប៉ុន្តែគាត់មិនដែលបណ្ដុះគំនិតឲ្យកូនៗមានគំនិតគុំគួនជាមួយខ្មែរក្រហមទេ គាត់ទាំងពីរហាក់បីដូចជាចង់បំភ្លេចរឿងរ៉ាវដែលបានកើតឡើងចំពោះគាត់ និងគ្រួសារចោល ។

ដំណើរទស្សនកិច្ចដែល សុភក្ត្រា ចូលរួមនៅពេលនេះ មានការយល់ដឹងច្រើនអំពីតុលាការ អំពីដំណើរការកាត់ក្ដី អំពីសំណងទៅប្រជាពលរដ្ឋជាដើម ។

ក្រៅពីការចូលរួមស្ដាប់សវនាការនៅសាលាក្ដីខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានរៀបចំដំណើរទស្សនកិច្ចដល់និស្សិតទាំងអស់ទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតជើងឯក នៅក្នុងថ្ងៃដដែល ដើម្បីយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមបន្ថែមទៀត ។

**ធាម សារៈមុនិន្ទ និងសោម ប៊ុនថន**

# «សារាណីយ»

**(តចប់)**

ពេលរំដោះបានទឹកដីភ្លាមៗ ខ្មែរក្រហមបោកទាហាន លន់ នល់ ដោយប្រើពាក្យថា «ឲ្យត្រៀមឯកសណ្ឋាន និងពាក់ស័ក្តិ ដើម្បីទទួលសម្តេចឪ» ។ នៅបាត់ដំបង គេប្រមូលទាហាន លន់ នល់ ដាក់សាលាសកល ហើយយកទៅបាញ់ចោលនៅភ្នំតាផ្តៅ (ភ្នំធិបតី) នេះបើយោងតាមសម្តីអ៊ំប្រុសថ្លៃរបស់ខ្ញុំនិយាយប្រាប់ ។ គាត់បានទៅឃើញទាហានទាំងអស់ នោះស្លាប់ផ្កាប់មុខ ទាំងចំណងខ្សែនីឡុងចងជាប់នៅនឹងដៃ ។

ទាក់ទងនឹងល្បិច និងទណ្ឌកម្មនេះ មានមីងម្នាក់ឈ្មោះ តូច ហាន បច្ចុប្បន្នរស់នៅក្បែរវត្ត បាននិយាយបាប្រាប់ខ្ញុំថ្មីៗនេះថា «កាលសម័យ លន់ នល់ ប្តីរបស់គាត់ពាក់ស័ក្តិ៣ គ្រួសាររបស់រស់នៅក្រុងភ្នំពេញ ។ ពេលខ្មែរក្រហមចូលក្រុងភ្នំពេញ គាត់ឃើញមនុស្សម្នា សប្បាយចិត្តណាស់ សិស្សសាលាដោះអាវគ្រវី ដោយអបអរសាទរនឹងជ័យជម្នះនេះ ។ ប៉ុន្មានម៉ោងក្រោយមក ភាពរីករាយ បានប្រែក្លាយទៅជាភាពធ្ងើងឆ្ងល់ ដោយខ្មែរក្រហម បានជម្លៀសប្រជាជនដោយបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញ ។ ប្តីរបស់គាត់ ត្រូវបានខ្មែរក្រហមភ្ជង់ឲ្យដើរជាជួរជាមួយទាហានដទៃទៀតសំដៅទៅមាត់ទន្លេ តែប្តីរបស់គាត់បានរំលៀកខ្លួនគេចចេញ ពេលដែលទាហានខ្មែរក្រហមធ្វេសប្រហែស រវល់តែហេកហាកឃើញស្រីស្អាត ។ តូច ហាន បានបែកពីប្តីរបស់គាត់ ពេលដែលគាត់ចាកចេញពីក្រុងភ្នំពេញតាមផ្លូវជាតិលេខ៥ ។ ពេលនោះ តូច ហាន មានផ្ទៃពោះជិតគ្រប់ខែហើយ ។ ហាន បានជួបជាមួយប្តីវិញនៅជិតព្រែកក្តាម ក្នុងគោលបំណងទៅខេត្តកំពង់ធំ តែឡានដែលឪពុកក្មេករបស់គាត់សុំជិះនោះ បែរជាទៅខេត្តកំពង់ចាមទៅវិញ ។ គាត់បានទៅស្នាក់នៅ ភូមិវត្តបឹងវៀន ក្នុងស្រុកស្ទឹង ត្រង់ ដោយរស់នៅលាយឡំជាមួយនឹងអ្នកមូលដ្ឋាន ។ បើតាមស្តាប់សម្តីរបស់គាត់ឃើញថា ទីនោះមានការលំបាកជាងតំបន់ដែលខ្ញុំរស់នៅ ។ ពេលទៅដល់ដំបូង កម្មាភិបាលខ្មែរក្រហមបានហៅអ្នកថ្មីឲ្យទៅប្រជុំ ហើយសួរថា «បើនរណាធ្លាប់ធ្វើអ្វីត្រូវប្រាប់ឲ្យត្រង់ ព្រោះអង្គការត្រូវការឲ្យទៅបំពេញការងារដែលធ្លាប់ធ្វើនៅភ្នំពេញវិញ» ។ ឪពុកក្មេករបស់ ហាន រិះតែនឹងឆ្លោយប្រាប់គេថា គាត់ធ្លាប់បើកយន្តហោះទៅហើយ តែប្រពន្ធគាត់បានឃាត់ទាន់ ព្រោះគាត់មិនទុកចិត្ត ។ មានអ្នកខ្លះបានឆ្លើយពន្លើសព្រោះចង់បានតំណែង ។ ក្រោយមកមិនបានប៉ុន្មានថ្ងៃផង អ្នកដែលឆ្លើយត្រង់ ត្រូវបាត់ខ្លួនជាបន្តបន្ទាប់ ។ ហាន បានប្រាប់ថា គេដឹកមនុស្សទាំងគ្រួសារនៅក្នុងឡានដែលមានគ្រួបដំបូលជិត អ្នកទាំងនោះត្រូវបានគេប្រាប់ថាឲ្យទៅរស់នៅកន្លែងថ្មី សម្បូរស៊ីចុក ។ ម្តាយក្មេក ហាន បានសុំអង្គការទៅដែរ តែអង្គការថាចាំជើងក្រោយ ។ ជិតដល់ថ្ងៃដួលរលំនៃរបបខ្មែរក្រហម មនុស្សត្រូវបានដឹកចេញពីភូមិកាន់តែច្រើនឡើង ។ ម្នាក់ៗនឹកក្នុងចិត្តថា អ្នកដែលបានទៅមុន ពិតជាបានសុខសប្បាយហើយ ។ ម្តាយរបស់ ហាន បានយកទងម្ជុល ទៅផ្ញើឲ្យគេដាំទុកឲ្យគាត់ផង ដល់ពេលគាត់បានទៅនឹងមានម្ហូបស្រាប់ ។ ទាំងអ្នកចាស់ទាំងអ្នកថ្មីពុំដឹងថា ខ្មែរក្រហមយកអ្នកទាំងអស់នោះទៅសម្លាប់ចោលទេ ។ ថ្ងៃមួយ ឪពុកក្មេករបស់ ហាន បានចូលទៅក្នុងព្រៃជ្រៅបន្តិច ទើបដឹងថា អ្នកដែលអង្គការឲ្យឡើងឡានទៅនោះ គេយកទៅសម្លាប់ ខ្លះកប់មិនទាំងជិតផង ចេញជើងនៅកណ្តាលវាល ។

រឿងចម្លែកមួយទៀតដែលខ្ញុំពុំដែលធ្លាប់ឮគេនិយាយនោះ គឺនៅកន្លែងដែលគាត់រស់នៅនោះ ពេលព្រឹកឡើងឃ្លូវកាម៉ែល ធុងដែកសម្រាប់ដាក់អាហារ ឬធុងដាក់បបរទៅកន្លែងធ្វើការ ។ ប្រុសៗដាក់នឹងបំពង់ឫស្សី ។ ពេលល្ងាចត្រឡប់មកពីធ្វើការងារវិញ ត្រូវដាក់លាមកយកមកជាមួយវិញ ។ ពេលមកដល់ការដ្ឋាន ត្រូវបានគេត្រួតពិនិត្យ បើពុំមានលាមក គេសួររកមូលហេតុ ។ បើអត់មានយកលាមកមកពីបីដងជាប់គ្នា ត្រូវគេកត់សម្គាល់ថា ក្បត់អង្គការខ្លះខ្ចាយមិនសន្សំសំចៃ ។ លាមកដែលយកមកនេះ ត្រូវលាយ

 

ជាមួយនឹងដើម ទន្រ្ទានខេត្ត ហើយយកទៅធ្វើជាជីបាចដាក់ស្រែ ។ ពេលបាចជីនេះម្តងៗ ជីនេះស្អិតជាប់ដៃ មានក្លិនស្អុយឆ្អាប ដែលជាហេតុធ្វើឲ្យគាត់ហូបបបរមិនកើត ។ គាត់បញ្ជាក់ប្រាប់ខ្ញុំថា នេះជារឿងពិតដែលគាត់បានជួបប្រទះ គាត់ស្វាគមន៍ជានិច្ច បើនរណាចង់ដឹងពីរឿងនេះ ។ គាត់បន់ស្រន់ជានិច្ច សូមកុំឲ្យអ្នកជំនាន់ក្រោយជួបប្រទះរឿងសោកសៅដូចគាត់ទៀត សូមឲ្យថែរក្សាសុខសន្តិភាព ។ ការធ្វើជីពីលាមកមនុស្សពិតជាមាននៅកន្លែងផ្សេង តែការដាក់កំហិតបែបនេះ ខ្ញុំសឹងតែពុំជឿ ។ នៅទីកន្លែងដែលគេជម្លៀសខ្ញុំទៅនោះ គេធ្វើបង្គន់រួម ដល់ពេលកំណត់ គេមកសែងធុងយកទៅ ។ ពេលនោះ ចំហាយក្លិនរបស់វា ពិតជាពិបាកទ្រាំណាស់ ចុះទំរាំពួកគាត់កាន់នឹងដៃ ចានដាក់អាហារ និងដាក់លាមកជាមួយគ្នា តើវាបែបណាទៅ? នេះឬដែលគេហៅថា នរកលោកីយ៍? ។

បើនិយាយពីការធ្វើទារុណកម្ម និងការសម្លាប់ ក៏ជារឿងចម្លែកមួយទៀតដែលខ្ញុំពុំធ្លាប់ឮ ។ ខ្ញុំតែងឮថា អាវកនឹងធាងត្នោត ចោះឆ្អឹងជំនីរយកថ្លើមប្រមាត់ វាយនឹងត្បូងចប គល់ឫស្សី ចាប់បោកនឹងគល់ឈើ បោះឡើងទៅលើយកជំពុះទទ្រូ ។ ឥឡូវនេះ ខ្ញុំបានឮគាត់និយាយប្រាប់ថា ពួកអាវខ្មៅបានសម្លាប់មនុស្សដោយស្រោចនឹងទឹកក្តៅ ។ គាត់ បញ្ជាក់ថា ប្អូនថ្លៃជីដូនមួយរបស់គាត់ដែលមានប្តីពាក់ស័ក្តិ៥ពីរបប លន់ នល់ ក្រោយ ពេលយកប្តីទៅសម្លាប់ហើយ ក្រុមគ្រួសារទាំងប៉ុន្មាន ពោលគឺមួយពូជ ត្រូវគេសម្លាប់ដោយស្រោចនឹងទឹកក្តៅ ។ គេយកអ្នកទាំងនោះទៅច្រកក្នុងបាវ ហើយដងទឹកក្នុងខ្ទះដែលកំពុង តែពុះកញ្ជ្រោលស្រោចពីលើ ។ ក្រោយរបបខ្មែរក្រហមដួលរលំ គាត់បានទៅសួរសាច់ញាតិនៅខាងកំពង់ធំជាស្រុកកំណើតខាងប្តីរបស់គាត់ អ្នកភូមិនៅទីនោះក៏បានប្រាប់គាត់ពីរឿងនេះ ។

ខ្ញុំចេះតែឆ្ងល់ថា ហេតុអ្វីបានជាមនុស្សហ៊ានលើកដៃវាយសម្លាប់មនុស្សដូចគ្នាដូចសត្វធាតុ បើថានៅក្នុងសមរភូមិទៅគេលើកកាំភ្លើងបាញ់សត្រូវ តែនេះអ្នកត្រូវសម្លាប់នេះ មិនមែនជាសត្រូវ ខ្លះនៅក្មេងនៅឡើយ ដែលគ្នាពុំទាន់ដឹងក្តី មកពីពួកគេខ្លាចអន្តការឬ? មីង តូច ហាន បានបានបំភ្លឺថា «ប្អូនជីដូនមួយរបស់ម្តាយក្មេងគាត់ម្នាក់ឈ្មោះ តក់ ធ្លាប់បានបួសរៀនចេះដឹងដែរ ម៉េចបានហ៊ានលើកដៃសម្លាប់មនុស្ស? ប្អូនជីដូនមួយគាត់ បានឆ្លើយថា បើស្អែកឡើងសម្លាប់ យប់ហ្នឹងគេឲ្យផឹកស្រាត្រាំប្រម៉ាត់មនុស្ស ពេលសម្លាប់ គាត់មើលឃើញមនុស្សតូចៗប៉ុនមេដៃ ។ ។ ចម្លើយនេះ មិនដឹងថា ខាងចិត្តវិទូ ជីវវិទូ យល់ព្រមដែរឬទេ វាអាចជាបែបនេះមែនឬ? ការផឹកប្រម៉ាត់មនុស្ស វាធ្វើឲ្យមានចិត្តសាហាវមែនឬ?

ការសម្លាប់មនុស្សយកថ្លើម យកប្រម៉ាត់នេះ ខ្ញុំធ្លាប់បានឮគេនិយាយក្រោយរបបខ្មែរក្រហមដួលរលំម្តង គឺខ្មែរក្រហមចោះឆ្អឹងជំនីរអ្នកទោសទាំងរស់ ។ បើថ្លើមវិញ លោតផ្លោតៗពេលដាក់លើខ្ទះឆារ ។ ថ្មីៗនេះ ក្នុងឱកាសបុណ្យកឋិនទានវត្តក្នុងភូមិខ្ញុំ មានស្រ្តីម្នាក់ឈ្មោះ លឿត បានប្រាប់ថា នៅវត្តឯករង្សីក៏មានរឿងបែបហ្នឹងដែរ ។ អ្នកដែលត្រូវគេសម្លាប់យកថ្លើមប្រម៉ាត់នោះ ឈ្មោះ វ៉ាត់ ។ គាត់ជាគ្រូមន្តអាគមខាងស្តោះផ្លុំ ដោះអំពើ ។ គាត់ខឹងនឹងពួកខ្មែរក្រហម ហើយបម្រុងនឹងធ្វើសកម្មភាពបោកគ្រាប់បែកនៅពេលប្រជុំនៅសហករណ៍ ក៏ត្រូវគេចាប់គាត់បានមុន ហើយយកទៅសម្លាប់ដោយខ្វេះយកថ្លើមប្រម៉ាត់ ។

## អវសាន្ត

ទោះបីរបបខ្មែរក្រហមបានដួលរលំទៅហើយជាច្រើនឆ្នាំក្តី ប៉ុន្តែព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើងនាសម័យនោះហាក់ដូចជានៅថ្មីៗដូចជានៅពីក្រោយខ្នងដូច ពាក្យគេថា វាវរអើលខ្នង ។ ខ្ញុំតែងប្រាប់សិស្សថា «ខ្ញុំសំណាងដែរ ដែលកាលណោះនៅតូច ពុំទាន់ចេះគិតវែងឆ្ងាយ ដូចនេះភាពទុក្ខសោកលំបាកវេទនាវាពុំកើតក្នុងអារម្មណ៍ តែបើខ្ញុំជាមនុស្សធំ ហើយមានកូនទៀតនោះ មិនដឹងថា ខ្ញុំរងទុក្ខគ្រាំគ្រាប៉ុនណាទេ ភ័យរន្ធត់បែបណាក្នុងរបបនោះ» ។ ពេលទៅទស្សនកិច្ចនៅបឹងជើងឯក និងគុកទួលស្លែង អ្វីដែលធ្វើឲ្យខ្ញុំរន្ធត់ខ្លាំងទ្រាំទស្សនាបន្តទៀតមិនបាននោះ គឺសម្លៀកបំពាក់កូនក្មេង រូបថត កូនក្មេងដែលមានវ័យប្រហាក់ប្រហែលនឹងកូនខ្ញុំ ។ ខ្ញុំគិតថា ក្នុងស្ថានភាពបែបនោះ តើខ្ញុំ ត្រូវជួយកូនខ្ញុំតាមរបៀបណា? ម្តាយទាំងឡាយឈឺចាប់ប៉ុនណា ពេលឮសំឡេងដង្ហោយហៅរបស់កូនឲ្យជួយ សំឡេងរំអុកខ្សាវៗ ទាររកបាយ រកអាហារ ពេលកូនមានជំងឺមិនអាចនៅមើលថែ គ្មានថ្នាំព្យាបាល ។ ខ្ញុំតែងធ្វើការប្រៀបធៀបខ្លួនឯងទៅក្មេងផ្សេងទៀត ដែលកើតមុនខ្ញុំត្រឹមតែមួយឆ្នាំ-ពីរឆ្នាំ ត្រូវបានគេប្រមូលឲ្យដេករួមនៅរោងធំ នៅលើ

 

សាលា ឈើពេលយប់ព្រលប់ពុកម៉ែមិនដឹង ត្រូវបានគេប្រើឲ្យកាប់ដីលើកទំនប់ទប់ទឹក ។ ខ្ញុំតែងប្រៀបធៀប កូនខ្ញុំនឹងខ្ញុំកាលណោះ ហើយនឹកហួសចិត្ត ព្រោះកូនខ្ញុំមានអាយុប្រាំ-ប្រាំមួយឆ្នាំ ខ្ញុំនៅលើកបី ឱបថើប តែចំណែកខ្ញុំវិញ គេប្រើឲ្យទៅធ្វើការក្នុងចម្ការក្នុងស្រែ រើសអាចម៍គោ ហើយថែមទាំងគ្មានអាហារហូបគ្រប់គ្រាន់ តើរាងកាយរបស់ខ្ញុំកាលណោះ ប៉ុនណា ម៉េចចេះតែធ្វើការកើត ហើយគេប្រើឲ្យដើរហៅក្មេងៗពីផ្ទះមួយទៅផ្ទះមួយទៀត ផ្លូវរអិល ភក់ប៉ប៊ិចប៉ប៉ាច ហើយខ្ញុំនៅតែឆ្ងល់ខ្លួនឯងទៀតថា ម៉េចកាលណោះ ខ្ញុំចេះកុហក មកពីធ្វើការយឺតព្រោះជាប់រវល់ដាំទឹកក្តៅលាងជើងម៉ៅអ៊ំ តែតាមពិត រវល់លីងពោតហូបសោះ ។ រូបភាពមួយទៀតដែលធ្វើឲ្យខ្ញុំចាំមិនភ្លេចដែរ គឺ "ហោប៉ៅអាវ" មិនថាចាស់ ឬក្មេងទេ គឺអាវមានហោប៉ៅធំៗ ។ ក្រោយខ្មែរក្រហមដួលរលំទៅ គេតែងនិយាយចំអន់គ្នាថា អ្នកណាពាក់អាវហោប៉ៅធំជាអាវរបស់អាពត ជាអាវចោរ ។ ខ្ញុំតែងគិតថា បើប្រទេសយើង មិនមានរបបខ្មែរក្រហម តើវាយ៉ាងម៉េច ។ ចាស់ៗសុទ្ធតែបានប្រដៅកូនចៅថា "ឯងបានតែរស់នៅក្នុងរបបខ្មែរក្រហមទេ ឥឡូវបានហូបឆ្អែត រស់ស្រួល មិនប្រឹងរៀនសូត្រ មិនខំធ្វើការរកស៊ី គិតតែពីប្រព្រឹត្តអំពើផ្តេសផ្តាស" ។

គួរឲ្យអាសូរប្រទេសកម្ពុជា ជនជាតិខ្មែរ ដែលក្រោយពីសម័យអង្គរចេះតែទន់ខ្សោយទៅៗជាលំដាប់ប្រទេសកើតសង្គ្រាម សាមគ្គីភាពផ្ទៃក្នុងប្រទេសត្រូវបែកបាក់ ពួកសត្រូវបរទេសតែងមានមហិច្ឆិតាឈ្លានពានទឹកដី ។ បុព្វបុរសយើងបានខិតខំប្រឹងប្រែងទប់ទល់នឹងការឈ្លានពានទឹកដីពីប្រទេសជិតខាង ។ ក្រោយពីសម័យអង្គរ យើងបាត់ម្ចាស់ការក្នុងការការពារប្រទេសដោយខ្លួនឯង ខ្វះឯកភាពជាតិ ចេះតែធ្វើតាមតែធ្វើតាមគេបញ្ជា ។ ប្រទេសកម្ពុជាប្រៀបបានទៅនឹងនំមួយដុំ ដែលគេហែកចែកគ្នាស៊ី ។ ប្រើធម៌ក្តៅមិនបាន គឺប្រើវិធីត្រជាក់ លាបពណ៌ឲ្យខ្មែរប្រចាក់ប្រខាំគ្នា ។ មិនត្រឹមតែបរទេសទេ ដែលលាបពណ៌ឲ្យខ្មែរនោះ សូម្បីតែខ្មែរដូចគ្នាក៏លាបពណ៌ឲ្យគ្នាដែរ ។ មនុស្សធ្លាប់ធ្វើការជាមួយគ្នា តែពេលបម្រើមេកើយខុសគ្នា ហ៊ានលើកអាវុធបាញ់ប្រហារគ្នា ។ ព្រឹត្តិការណ៍នេះ ខ្ញុំនៅចាំមិនភ្លេច តែនឹកឃើញដល់រឿងនេះ ខ្ញុំស្រយុតស្រយង់ចិត្តរកស្មានមិនត្រូវ ។ កាលណោះ ខ្ញុំរៀននៅថ្នាក់ទី៧ នៃសាលាកម្រិតសិក្សាទី២ ឃុំព្រែក គឺនៅថ្ងៃប្រឡងសាក (ខុសពីប្រឡងឆមាស ប្រឡងសាក គឺជាការវាស់កម្រិតយល់ដឹងរបស់សិស្សមុនប្រឡងយកសញ្ញាបត្រ វិញ្ញាសារចេញពីក្រសួងដូចប្រឡងថ្នាក់ជាតិ) ពេលរសៀល ខ្ញុំដើរទៅសាលារៀន ក្រឡេកទៅមុខវត្តស្វាយជ្រុំ ឃើញសេនាជនដែលដឹកនាំដោយឈ្មោះ កឹង ឡើងត្រាក់ទ័រ ដើម្បីទៅការពារត្រាក់ទ័ររបស់មន្ទីរកសិកម្មដែលត្រូវចុះជួយភ្ជួរដីឲ្យកសិករនៅវាលបឹងធំ ។ ក្នុងចិត្តខ្ញុំមានអារម្មណ៍ចម្លែកពិភាល់ក្នុងចិត្តពីសុវត្ថិភាពរបស់ពួកគាត់ ។ ពេលត្រឡប់មកពីប្រឡងវិញ ក៏បានទទួលដំណឹងរន្ធត់មែន ព្រោះសេនាជនទាំងនោះ ត្រូវពួកខ្មាំងខ្មែរក្រហម ពួនស្ទាក់បាញ់ ខ្លះស្លាប់ ខ្លះរស់ មេសេនាជនឈ្មោះ កឹង នោះក៏បានស្លាប់ដែរ ។ រីឯក្រុមខ្មាំងខ្មែរក្រហមដែលលបវាយប្រហារនោះ គឺជាអតីតសេនាជននៅកងជាមួយគ្នានេះឯង ។ ពួកគេរត់ចូលព្រៃ ពុំមែនមានគំនុំជាមួយឈ្មោះ កឹង ឬសេនាជនផ្សេងទេ គឺចាញ់ឃោសនាខ្មែរក្រហម ។ ខ្ញុំចេះតែឆ្ងល់ ហេតុអីបានជាលើកកាំភ្លើងបាញ់គ្នាឯង? ខ្មែរយើងតែងប្រកាន់ទស្សនៈ "ស៊ីបាយអ្នកណា យកអាសារអ្នកហ្នឹង" ។ ទស្សនៈនេះហើយ ដែលធ្វើឲ្យខ្មែរចេះតែឈ្លោះគេជាតិសាសន៍ឯង ។ យើងគួរតែកែប្រែទស្សនៈបែបនេះឲ្យទៅជា "ស៊ីបាយអ្នកណា បម្រើខុត្តមគតិអ្នកនោះ" ឬ "ស៊ីបាយអ្នកណា បម្រើជាតិ បម្រើផលប្រយោជន៍ឲ្យជាតិអ្នកនោះ" ។

សង្គ្រាមចប់ហើយ សង្ឃឹមថាគ្រប់គ្នាបានសុខសប្បាយ ។ តែមិនបានប៉ុន្មានឆ្នាំផង ភ្លេងខ្លងខែកលាន់ឮទ្រហឹង ព្រោះតែជំងឺអេដស៍ ។ អ៊ុនតាក់បានចូលមកស្រុកខ្មែរ ដោយនាំយកមកជាមួយនូវ ការចរចាបទឈប់បាញ់គ្នារវាងខ្មែរ និងខ្មែរ និងជំងឺអេដស៍មកចែកជូនប្រជាជនកម្ពុជា ។ បងថ្លៃស្រីទី២ ក្មួយជីដូនមួយបង្កើត និងប្រសារ បានស្លាប់ចោលកូនឲ្យនៅកំព្រាក៏ដោយសារជំងឺអេដស៍នេះដែរ ។ អេដស៍ជាឃាតករឈាមត្រជាក់ បានមកប្រល័យឆក់យកជីវិតបងស្រីខ្ញុំ ក្រោមសម្រែកឈឺចាប់ ថ្ងូចថ្ងូរគួរឲ្យសង្វេគ ខ្ញុំពិតជាមានការឈឺចាប់ណាស់ ។

នៅភូមិខ្ញុំ ជាតំបន់ប្រទាញប្រទង់គ្នា ។ ថ្ងៃមួយក្នុងឆ្នាំ១៩៨២ ទាហានវៀតណាម ដែលនៅរោងចក្រក្រចៅដូនទាវ បានបាញ់ផ្លោងគ្រាប់កាំភ្លើងដាក់ភូមិខ្ញុំ ដោយមិនបានប្រាប់ដំណឹងជាមុន សូម្បីរត់

រកត្រង់សេក៏មិនទាន់ ។ ក្រោយមក ទើបដឹងថា គេបាញ់ផ្លោង ប្រទ្បាំ ព្រោះឃើញក្មេងៗឃ្វាលគោតាមវាលស្រែ ស្មានតែទាហានខ្មែរក្រហម ។ នៅឆ្នាំ១៩៨៦ ទីតាំងភូមិខ្ញុំត្រូវបង្កើតជាស្រុក ធ្វើបន្ទាយទាហាន ។ លោះពេលតិចណាស់ ដែលអ្នកភូមិត្រូវចេញពីផ្ទះ នៅពេលយប់គេចពីគ្រាប់កាំភ្លើង (បាញ់គ្នា) ។ បោះឆ្នោតហើយក៏នៅតែមិនទាន់ចប់សង្គ្រាម ។ ឆ្នាំ១៩៩៨ ទាហានខ្មែរក្រហមវាយចូលសាលាស្រុក ដុត បំផ្លាញទីតាំងរដ្ឋបាលឆេះសន្ធោរសន្ធៅ ធ្វើឲ្យជីវិតទាហាន និងជនស៊ីវិលស្លាប់ ។ ក្មួយប្រុសជីដូនមួយខ្ញុំម្នាក់បានស្លាប់នៅលើផ្ទះចោលប្រពន្ធកូន ដែលទើបតែមានអាយុបីខែ ព្រោះគ្រាប់កាំភ្លើងបានហើរមកប៉ះចំអំឡុងពេលប្រយុទ្ធគ្នា ។ កាលណោះ ភូមិខ្ញុំមានគ្រោះទឹកជំនន់ទៀត ខ្ញុំពរក្មួយរត់កាត់ទឹកគេចខ្លួនទៅខាងដូនទាវ ។ ម្នាក់ៗគ្មានបានយករបស់របរសំខាន់ជាប់តាមខ្លួនទេ គឺរត់យកតែប្រាស់អាយុ ជាសំណាងដែរដែលខ្មែរក្រហមមិនបានឡើងឆែកឆេរយកអីវ៉ាន់នៅផ្ទះរបស់ខ្ញុំ ។ បងស្រីទីពីរខ្ញុំកំសត់ណាស់ គាត់ជាអ្នកមានគុណសម្រាប់គ្រួសារខ្ញុំ ។ ក្រោយរបបខ្មែរក្រហមដួលរលំ គាត់ជាអ្នករកស្បៀងមកចិញ្ចឹម សមាជិកគ្រួសារខ្ញុំ ដោយដឹក ប្រហុក ត្រីងៀត ត្រីឆ្អើរ ពីភូមិទៅដោះដូរអង្ករនៅខាងស្វាយ ចេក ស្រុកថ្មពួក ជួនណាទៅដល់ព្រំដែនដោយធាក់កង់ទៅមក ។ នៅឆ្នាំ១៩៨៣ គាត់ក៏ចូលធ្វើជាគ្រូបង្រៀនក្មេងៗសាលាមត្តេយ្យ ។ ពេលទំនេរពីបង្រៀន គាត ឆ្លៀតធាក់កង់ទិញត្រសក់ពីខាងព្រែកគ្រប់ តាអួ យកមកលក់ដើម្បីទប់ទល់ប្រាក់ខែដ៏ស្តួចស្តើង ។ **ផាន់ សុផល**



រូបទីមួយរាប់ពីស្តាំ ៖ អ្នកចម្រៀងនៅក្នុងកងសិល្បៈ នៃរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) មកលេងក្រុមគ្រួសារ ។

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 210, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.